សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ការចុះបញ្ជីម៉ាកនៅកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **អន ប៊ុនឆៃ**
**ចៅ វ៉ាន់ដា**

សាស្ត្រាចារ្យណែនាំ
លោក **ភាន់ សុទ្ធប៉ូលីន**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ១៩

ឆ្នាំចូលសិក្សា ២០១៥
ឆ្នាំសរសេរសារណា ២០១៩

## សេចក្តីថ្លែងអំណរគុណ

កិច្ចការដែលជោគជ័យទាំងឡាយរមែងកើតឡើងដោយការខិតខំប្រឹងប្រែងតស៊ូ និងជំនះរាល់ឧបសគ្គចំពោះមុខដោយខ្លួនឯងផ្ទាល់ ហើយទន្ទឹមនឹងនេះផងដែលនោះគឺការជួយជ្រោមជ្រែងពីមនុស្សដែលនៅជុំវិញខ្លួនយើងផងដែរ។ នៅក្នុងឱកាសនេះផងដែរពួកយើងខ្ញុំទាំងពីរមានឈ្មោះ **អន ប៊ុនឆៃ** និង **ចៅ វ៉ាន់ដា** ដែលជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី១៩ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមយកវេលានេះដើម្បីថ្លែងអំណាអរគុណដល់អ្នកមានគុណទាំងអស់ ដើម្បីសម្តែងពីការគោរពដឹងគុណយ៉ាងជ្រាលជ្រៅដល់អ្នកមានគុណទាំងអស់ដែលមានដូចតទៅ៖

ខ្ញុំបាទ អន ប៊ុនឆៃ សូមធ្វើគារវកិច្ចសម្តែងនូវកតញ្ញូតាធម៌ជូនចំពោះលោកឪពុក សាយ សំអាត និងអ្នកម្តាយ ជាត់ សៀកម៉េង ដែលតែងតែជួយបង្ហាត់បង្រៀនប្រៀនប្រដៅខ្ញុំតាំងពីតូចរហូតដល់ធំ ហើយលោកទាំងពីរផងដែរនោះបានជួយទំនុកបម្រុងទាំងស្មារតី ទាំងការសិក្សា និងសម្ភារៈ តាំងពីដើមរហូតមក ដែលមិនដែលត្អូញត្អែលពីការលំបាកនោះឡើយ។

ខ្ញុំបាទ ចៅ វ៉ាន់ដា សូមធ្វើគារវកិច្ចសម្តែងនូវកតញ្ញូតាធម៌ជូនចំពោះលោកឪពុក ហេង ចៅវ៉ា និងអ្នកម្តាយ សួន ណារី ដែលតែងតែជួយបង្ហាត់បង្រៀនខ្ញុំតាំងពីតូចរហូតមកដល់ពេលបច្ចុប្បន្ននេះ ហើយលោកទាំងពីរផងដែរនោះតែងតែជួយទំនុកបម្រុងទាំងស្មារតី ទាំងការសិក្សា និងសម្ភារៈ តាំងពីដើមរហូតមក ដែលទោះបីជាលោកទាំងពីរមានការលំបាកយ៉ាងណាក៏លោកទាំងពីរនៅតែបន្តការទំនុកបម្រុងដោយមិនរុញរានោះដែល។

ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានអនុញ្ញាតឱ្យយើងខ្ញុំបានសរសេរសារណាបញ្ចប់ការសិក្សា។

ឯកឧត្តម រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ដែលបានអនុញ្ញាតឱ្យយើងខ្ញុំបានចុះស្រាវជ្រាវឯកសារនៅនាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្ម។

ឯកឧត្ត ម លោកជំទាវ លោក លោកស្រី ដែលជាសាស្ត្រាចារ្យទាំងអស់ ដែលបានយកចិត្តទុកដាក់ក្នុងការបង្រៀនរហូតមក និងបានផ្តល់ជាអនុសាសន៍យ៉ាងល្អៗ ព្រមទាំងបានចងក្រងសៀវភៅជាច្រើន ដែលជាផ្លូវសម្រាប់អ្នកស្រាវជ្រាវ និងបានជួយសម្រួលដល់និស្សិតទាំងអស់ក្នុងការសិក្សា។

លោកសាស្ត្រាចារ្យ កាន់ សុទ្ធប៉ូលីន ដែលជាសាស្ត្រាចារ្យមួយរូបផ្នែក «កម្មសិទ្ធិបញ្ញា» និងជាសាស្ត្រាចារ្យដឹកនាំយើងខ្ញុំសរសេរសារណា ដែលលោកគ្រូបានផ្តល់ជាដំបូន្មានណែនាំ និងកែលម្អរសារណាមួយនេះតាំងពីចំណុចចាប់ផ្តើម រហូតដល់សារណានេះបានបញ្ចប់ដោយស្អាតរ។

មន្ត្រី ដែលធ្វើការនៅនាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្មទាំងអស់ ជាពិសេស មន្ត្រីនៅការិយាល័យចុះបញ្ជីម៉ាក ដែលបានចែករំលែកចំណេះដឹង បទពិសោធន៍ និងបានពន្យល់ពីចំណុចខ្វះខាត ព្រមទាំងបានផ្តល់ភាពកក់ក្តៅដល់យើងខ្ញុំទាំងពីរ។

រៀមច្បង និងអ្នកសិក្សាស្រាវជ្រាវ ជំនាន់មុនៗ ដែលបានខិតខំស្រាវជ្រាវរហូតបន្សល់ទុកសៀវភៅដល់ប្អូនៗជំនាន់ក្រោយ ក៏ដូចជាខ្ញុំផងដែល។

មិត្តភក្តិ និងមិត្តរួមថ្នាក់ ទាំងអស់ ដោយអ្នកទាំងអស់គ្នាតែងតែជួយជ្រោមជ្រែង ជួយអោយជាកម្លាំងចិត្ត និងតែងតែជួយគ្រប់បញ្ហាទាំងអស់នៅពេលដែលខ្ញុំជួបការលំបាក។

ជាចុងក្រោយនេះដែរ យើងខ្ញុំសូមគោរពថ្លែងអំណរគុណ និងសូមបួងសួងដល់វត្ថុស័ក្តិសិទ្ធិទាំងអស់នៅក្នុងលោក សូមឱ្យអ្នកមានគុណទាំងអស់ដែលបានរៀបរាប់ដូចខាងលើនេះ ព្រមទាំងក្រុមគ្រួសារ ឱ្យទទួលបានជោគជ័យចម្រុងចម្រើនគ្រប់ភារកិច្ចទាំងឡាយ និងសូមឱ្យពួកគាត់ជួបតែពុទ្ធពរទាំងបួនប្រការគឺ អាយុវណ្ណៈ សុខៈ ពលៈ និងបដិភានៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

បន្ទាប់ពីបានសិក្សាអស់រយៈពេលបួនឆ្នាំកន្លង នៅក្នុងសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានធ្វើឱ្យខ្ញុំមានចំណេះដឹងក្នុងការសិក្សាស្រាវជ្រាវជាច្រើន។ ម្យ៉ាងវិញទៀតដើម្បី អោយការសិក្សារបស់ខ្ញុំកាន់តែជោគជ័យ នឹងឈានទៅរកការបញ្ចប់ជាស្ថាពរ ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ។ សារណាបញ្ចប់ការសិក្សាមួយនេះ ធ្វើឡើងក្នុងគោលបំណងស្វែងយល់ពីការអនុវត្តន៍ជាក់ស្តែង បន្ទាប់ពីធ្លាប់បានរៀនទ្រឹស្តីកន្លងមកដើម្បីមើលថាតើមានភាពខុសគ្នាត្រង់ចំណុចណាខ្លះ។

ដោយមើលឃើញពីសារៈប្រយោជន៍វិស័យពាណិជ្ជកម្មទាក់ទងទៅនឹងកម្មសិទ្ធិបញ្ញា នៅព្រះរាជាណាចក្រកម្ពុជា កំពុងតែមានភាពរីកចម្រើនគួឱ្យកត់សម្គាល់ ម៉្យាងវិញទៀតវិស័យសេដ្ឋកិច្ចក៏រីកលូតលាស់ពីមួយថ្ងៃទៅមួយថ្ងៃ ហើយក៏បានទាក់ទាញអ្នកវិនិយោគជាច្រើនទាំងក្នុងស្រុក និងក្រៅស្រុក។ បច្ចុប្បន្ននៅព្រះរាជាណាចក្រកម្ពុជា មានអ្នកវិនិយោគទន់ជាច្រើនដែលបានមកធ្វើជំនួញ នៅព្រះរាជាណាចក្រកម្ពុជា ធ្វើឱ្យមានការប្រកួតប្រជែងទំនិញយ៉ាងខ្លាំងក្នុងវិស័យពាណិជ្ជកម្ម។ ដោយសង្កេតឃើញថា ម៉ាកគឺអាចសម្គាល់ និងបែកចែងភាពខុសគ្នានៃទំនិញនីមួយៗបាន ដែលជាផ្នែកមួយមានសារៈសំខាន់ ទើបពួកខ្ញុំសម្រេចចិត្តជ្រើសរើសប្រធានបទស្តីពី **ការចុះបញ្ជីម៉ាកនៅកម្ពុជា** ដែលជាផ្នែកមួយនៃកម្មសិទ្ធិបញ្ញាមកសិក្សាស្រាវជ្រាវបន្ថែម។

យ៉ាងណាមិញទោះបីជាមានការខិតខំប្រឹងប្រែងយកចិត្តទុកដាក់ ដើម្បីឲ្យការសិក្សាស្រាវជ្រាវនេះ សម្រេចទៅបានល្អប្រកបដោយភាពជោគជ័យ ប៉ុន្តែវាក៏នៅមានចំណុចខ្វះខាតមួយចំនួនផងដែរ។ ជាងនេះទៅទៀត ខ្ញុំសង្ឃឹមថាវាជាផ្នែកមួយជួយផ្តល់ ជាគំនិតយោបល់ដល់ អ្នកដែលកំពុងសិក្សាធ្វើការទាក់ទង នឹងផ្នែកនេះ និងជាមេរៀនសម្រាប់សិស្សនិស្សិត អ្នកសិក្សាស្រាវជ្រាវមួយចំនួនដែលមានបំណងចង់ស្វែងយល់ទៅលើវិស័យកម្មសិទ្ធិបញ្ញាដើម្បីឲ្យការសិក្សា និងការងាររបស់ខ្លួនទទួលបានជោគជ័យ។

ខ្ញុំបាទសូមទទួលរាល់ការរិះគន់ទាំងឡាយពីសំណាក់សិស្សានុសិស្ស និងមិត្តអ្នកអានទាំងអស់ ដើម្បីឲ្យប្រធានបទមួយនេះកាន់តែប្រសើរ និងជាប្រយោជន៍សម្រាប់អ្នកជំនាន់ក្រោយ និងសូមអភ័យទោសរាល់កំហុសឆ្គង ដែលបានកើតមានឡើងក្នុងការសរសេរសារណាបញ្ចប់ការសិក្សាមួយនេះ។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........ ១

## ជំពូកទី១
## ទិដ្ឋភាពទូទៅស្តីពីការចុះបញ្ជីម៉ាក

**ផ្នែកទី១៖ លក្ខណៈរបស់ម៉ាក** ........ ៣
១.១ និយមន័យ ........ ៤
១.១.១ ម៉ាក Traditional Mark (ម៉ាកធម្មតា) ........ ៥
១.១.២ ម៉ាក Non-Traditional Mark ........ ៦
១.១.៣ ម៉ាកសមូហភាព ........ ៦
១.១.៤ ម៉ាកបញ្ជាក់គុណភាពទំនិញ (Certification Mark) ........ ៦
១.២ មុខងារនៃម៉ាក ........ ៧
១.៣ អត្ថប្រយោជន៍នៃម៉ាកដែលបានចុះបញ្ជី ........ ៨
១.៣.១ អត្ថប្រយោជន៍ចំពោះសង្គម ........ ៨
១.៣.២ អត្ថប្រយោជន៍ចំពោះម្ចាស់ម៉ាក ........ ៩
ក. ការទទួលបានសិទ្ធិផ្តាច់មុខលើម៉ាក ........ ៩
ខ. ការទទួលបានសិទ្ធិប្រឆាំងនឹងការរំលោភបំពានលើម៉ាក ........ ១០
១.៣.៣ អត្ថប្រយោជន៍ចំពោះអ្នកប្រើប្រាស់ ........ ១០
១.៤ ម៉ាកដែលអាចចុះបញ្ជីបាន ........ ១១
**ផ្នែកទី២៖ ម៉ាកដែលមិនអាចចុះបញ្ជីបាន** ........ ១១
២.១ ម៉ាកដែលហាមឃាត់មិនឱ្យចុះបញ្ជីក្រោមបញ្ញត្តិអន្តរជាតិ ........ ១១
២.១.១ អនុសញ្ញាទីក្រុងប៉ារីស ១៨៨៣ ស្តីពីកិច្ចការពារកម្មសិទ្ធិឧស្សាហកម្ម ........ ១២
២.១.២ កិច្ចព្រមព្រៀង TRIPS ១៩៩៤ ........ ១២
២.១.៣ កិច្ចព្រមព្រៀងអន្តរជាតិពាក់ព័ន្ធផ្សេងទៀត ........ ១២
២.២ ម៉ាកដែលហាមឃាត់មិនឱ្យចុះបញ្ជីក្រោមបញ្ញត្តិជាតិ ........ ១២
២.២.១ ម៉ាកដែលធ្វើឱ្យមានការភ័ន្តច្រឡំ ........ ១៣
ក. ម៉ាកដែលមិនអាចបែងចែកលក្ខណៈខុសគ្នានៃទំនិញ ឬសេវា ........ ១៤

ខ. ម៉ាកដែលនាំឲ្យសាធារណៈជន ឬមជ្ឈដ្ឋានពាណិជ្ជកម្មភ័ន្តច្រឡំទៅនឹងប្រភពភូមិសាស្ត្រទំនិញ ឬសេវា ........................................ ១៤
គ. ម៉ាកដែលដូចគ្នា ឬប្រហាក់ប្រហែលគ្នានឹងម៉ាកដែលបានចុះបញ្ជីរួច........................ ១៥
ឃ. ម៉ាកដែលដូចគ្នា ឬប្រហាក់ប្រហែលគ្នានឹងម៉ាកល្បី........................................ ១៦
ឃ.១ ម៉ាកល្បីដែរមិនបានចុះបញ្ជី ........................................ ១៧
ឃ.២ ម៉ាកល្បីដែរបានចុះបញ្ជី........................................ ១៨
២.២.២ ម៉ាកដែលច្បាប់ហាមឃាត់ពិសេស ........................................ ១៨
ក. ម៉ាកដែលផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ សីលធម៌ ឬប្រពៃណីល្អរបស់ជាតិ .. ១៨
ខ. ម៉ាកដែលប៉ះពាល់ដល់សញ្ញា នៃស្ថាប័នជាតិ និងអន្តរជាតិ ........................................ ១៩

## ជំពូកទី២

## ការចុះបញ្ជីម៉ាក

**ផ្នែកទី១ នីតិវិធីនៃការដាក់ពាក្យស្នើសុំចុះបញ្ជី** ........................................ ២០
១.១ ការដាក់ពាក្យស្នើសុំ........................................ ២១
១.១.១ ការដាក់ពាក្យស្នើសុំផ្ទាល់ ........................................ ២១
ក. អ្នកស្នើសុំជារូបវន្តបុគ្គល ........................................ ២១
ខ. អ្នកស្នើសុំជានីតិបុគ្គល ........................................ ២២
គ. ភ្នាក់ងារតំណាង ........................................ ២២
១.១.២ ការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកតាមរយៈប្រព័ន្ធអេឡិចត្រូនិច........................ ២៤
ក. អ្នកដាក់ពាក្យស្នើសុំ ........................................ ២៤
ខ. ការដាក់ពាក្យស្នើសុំ ........................................ ២៤
១.១.៣ ការដកពាក្យស្នើសុំ........................................ ២៥
១.២ សំណុំឯកសារចាំបាច់ក្នុងការដាក់ពាក្យស្នើសុំ ........................................ ២៥
១.២.១ ពាក្យសុំ........................................ ២៥
ក. គំរូពាក្យស្នើសុំ ........................................ ២៥
ខ. ភាសាប្រើប្រាស់ក្នុងឯកសារដាក់ពាក្យស្នើសុំ ........................................ ២៦
១.២.២ ឯកសារចាំបាច់ផ្សេងទៀត........................................ ២៦
ក. គំរូម៉ាក........................................ ២៦
ខ. សម្លេងអាន និងការបកប្រែអត្ថន័យរបស់ម៉ាក ........................................ ២៧

គ. បញ្ជីទំនិញ ឬសេវានៃម៉ាកដែលស្នើសុំចុះបញ្ជី ២៧
១.៣ អាជ្ញាធរមានសមត្ថកិច្ចក្នុងការដាក់ពាក្យស្នើសុំ ២៧
១.៤ កម្រៃសេវា ២៨
**ផ្នែកទី២ ៖ ការត្រួតពិនិត្យ និងការសម្រេចលើពាក្យស្នើសុំចុះបញ្ជីម៉ាក** ២៨
២.១ ការត្រួតពិនិត្យលើពាក្យស្នើសុំចុះបញ្ជីម៉ាក ២៩
២.១.២ ការត្រួតពិនិត្យមើលលក្ខខណ្ឌទម្រង់នៃពាក្យស្នើសុំចុះបញ្ជីម៉ាក ២៩
២.១.៣ ការត្រួតលើខ្លឹមសារនៃម៉ាក ២៩
ក. កាត្រួតពិនិត្យខ្លឹមសារនៃម៉ាក (ជោគជ័យ) ២៩
ខ. ការត្រួតពិនិត្យខ្លឹមសារដែលមានបញ្ហា ៣០
២.២ ការសម្រេចលើការស្នើសុំចុះបញ្ជីម៉ាក ៣១
២.២.១ ការបដិសេធចំពោះការចុះបញ្ជី ៣២
ក. ការជំទាស់លើពាក្យស្នើសុំ ៣២
ខ. ការអនុវត្តជំទាស់ក្នុងការចុះបញ្ជីដោយម្ចាស់ម៉ាក ៣២
គ. ការជំទាស់ក្នុងការចុះបញ្ជីម៉ាកដោយអ្នកទទួលសិទ្ធិ ៣៣
ឃ. ការជំទាស់ក្នុងការចុះបញ្ជីម៉ាកដោយមន្ត្រីកាន់កាប់បញ្ជី ៣៣
២.២.២ ការយល់ព្រមចុះបញ្ជីម៉ាក ៣៤
ក. ការចេញវិញ្ញាបនបត្រចុះបញ្ជីម៉ាក ៣៤
ខ. ការផ្សព្វផ្សាយជាសាធារណៈ ៣៥
គ. បណ្ដឹងជំទាស់លើម៉ាក ៣៥
**សេចក្ដីសន្និដ្ឋាន** ៣៧
**អនុសាសន៍** ៣៩
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

នាពេលបច្ចុប្បន្នមានទំនិញជាច្រើន ដែលកំពុងធ្វើចរាចរណ៍នៅលើទីផ្សារនៃព្រះរាជាណាចក្រកម្ពុជា។ ហើយទំនិញទាំងអស់នោះ ភាគច្រើនគឺត្រូវបាននាំចូលពីបណ្តាលប្រទេសនានាលើសកលលោកហើយទំនិញខ្លះក៏បានបង្កើតឡើងនៅក្នុងស្រុកផងដែរ។ រាល់ទំនិញដែលបានផលិត និងបង្កើតឡើងដើម្បីបំពេញតម្រូវការ របស់មនុស្សដែលរស់នៅក្នុងសង្គមយើងសព្វថ្ងៃ ដូចជា គ្រឿងឧបភោគបរភោគ សំលៀកបំពាក់ ស្បែងជើង កាបូប ទូរស័ព្ទ និងរបស់ប្រើប្រាស់ដទៃជាច្រើនផ្សេងទៀត។ សម្រាប់ប្រទេសកម្ពុជាដែលជាប្រទេសកំពុងអភិវឌ្ឍន៍មួយ មិនថាវិស័យឧស្សាហ៍កម្ម សិប្បកម្ម ឬវិស័យអប់រំ ជាពិសេសគឺវិស័យពាណិជ្ជកម្ម កាន់តែមានសន្ទុះកើនឡើងជាបណ្តើរៗ ស្របពេលជាមួយគ្នានេះយើងឃើញថា សម្រាប់វិស័យពាណិជ្ជកម្ម គឺមានទំនិញថ្មីៗជាច្រើនរបស់សហគ្រាស តាមបណ្តាលក្រុមហ៊ុនផ្សេងៗ ដែលធ្វើចរាចរណ៍ប្រកួតប្រជែងនៅលើទីផ្សារ ដើម្បីទាក់ទាញអតិថិជនឲ្យជួយជាវនូវទំនិញទាំងនោះ។ លើសពីនេះទៅទៀតដើម្បីបំពេញរាល់តម្រូវការរបស់អតិថិជនដែលមានមិនឈប់មិនឈរ ក្រុមហ៊ុនមួយចំនួន ទាំងក្នុងស្រុក ឬក្រៅស្រុក បានបង្កើតឈ្មោះ មុខទំនិញ សេវា ឬសញ្ញាសម្គាល់នៃទំនិញនីមួយៗ ដែលយើងហៅថា "ម៉ាក" ដើម្បីឲ្យអតិថិជនងាយកំណត់សម្គាល់នូវទំនិញដែលខ្លួនបានប្រើប្រាស់។ ហើយ "ម៉ាក" ត្រូវបានគេប្រើសម្រាប់សម្គាល់នូវទំនិញ ឬសេវារបស់សហគ្រាសមួយ។ ម៉ាកត្រូវបានគេបង្កើតឡើង ឬច្នៃប្រឌិត ដោយម្ចាស់ម៉ាកក៏ដោយ តែការបង្កើតឬច្នៃប្រឌិតនោះ មិនត្រូវធ្វើឡើងតាមអំពើចិត្តនោះទេ ពោលគឺត្រូវគោរពតាមគោលការណ៍នៃច្បាប់ស្តីពីម៉ាក ។

ម៉ាកគឺជាសញ្ញាដែលមើលឃើញ អាចសម្គាល់លក្ខណៈខុសគ្នានៃទំនិញ ឬសេវាសហគ្រាសនីមួយៗ។[1] ដោយសារតែមានការប្រកួតប្រជែងលើទីផ្សារ រាល់មុខទំនិញទាំងអស់ដែលចរាចរណ៍លើទីផ្សារត្រូវកំណត់ ឈ្មោះ សញ្ញា ឬសេវា ដែលយើងហៅថា"ម៉ាក" ឲ្យបានច្បាស់លាស់ដើម្បីជៀសវាងរាល់ការក្លែងបន្លំទំនិញទាំងឡាយដែលកើតមានឡើង។ ដូច្នេះថាតើគួរធ្វើដូចម្តេចដើម្បីបង្កើតម៉ាកមួយឲ្យស្របច្បាប់ និងទទួលការការពារពីច្បាប់ នៅពេលមានការក្លែងបន្លំទាំងឡាយដែលកើតមានឡើងចំពោះម៉ាករបស់ខ្លួន? ម្យ៉ាងទៀតសម្រាប់ការស្នើសុំចុះបញ្ជីម៉ាកមួយឲ្យមានប្រសិទ្ធិភាពតើយើងគួធ្វើដូចម្តេច?

ដោយសារតែមានការបារម្មណ៍លើការដាក់ឈ្មោះម៉ាកតាមទំនើងចិត្ត និងដើម្បីជៀសវាងរាល់ការលួចបន្លំម៉ាក ទើបរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានបង្កើតស្ថាប័នមួយដែរ

[1] មាត្រា២ ចំណុច ក នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើប្រកួតប្រជែងមិនស្មោះត្រង់, ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០២

ទទួលបន្ទុកចុះបញ្ជីម៉ាកដែលស្ថានប័ននោះមានឈ្មោះថា នាយកដ្ឋានកម្មសិទ្ធិបញ្ញា ដែលមានទីស្នាក់ការនៅក្រសួងពាណិជ្ជកម្ម។ ការចុះបញ្ជីម៉ាកគឺជាលក្ខខណ្ឌដ៏សំខាន់មួយសម្រាប់ម្ចាស់ម៉ាកក្នុងការពារសិទ្ធិរបស់ពួកគាត់ស្របច្បាប់។ ហើយគ្រប់ការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក ត្រូវគោរពលក្ខខណ្ឌ និងច្បាប់ មានដូចជា ប្រកាសសរបស់ក្រសួង ឬ ច្បាប់ស្តីពីម៉ាក។ គ្រប់ម៉ាកទាំងអស់ដែលចរាចរណ៍លើទីផ្សានៃព្រះរាជាណាចក្រកម្ពុជា ដាច់ខាតត្រូវមកចុះបញ្ជីនៅក្រសួងពាណិជ្ជកម្មជាមុនសិន ដើម្បីជៀសវាងរាល់បញ្ហាដែលកើតមានឡើងដែលនាំឲ្យខូចប្រយោជន៍។

ដោយយល់ឃើញថា ការចុះបញ្ជីម៉ាក វាធ្វើឲ្យកើតសិទ្ធិដល់ម្ចាស់ម៉ាក ក្នុងការពារម៉ាករបស់ខ្លួន និងមានសិទ្ធិប្តឹងទៅលើជនណាម្នាក់ដែលបានរំលោភបំពានមកលើម៉ាករបស់ខ្លួន។ ដូចនេះហើយទើបពួកខ្ញុំជ្រើសរើសយកប្រធានបទស្តីពី "ការចុះបញ្ជីម៉ាកនៅកម្ពុជា" មកសិក្សាស្រាវជ្រាវដោយលើកយក បែបបទ និងគោលការណ៍ នៃការដាក់ពាក្យស្នើសុំចុះបញ្ជី ពីដំណាក់កាលដំបូងរហូតដល់ការសម្រេច លើពាក្យស្នើសុំ ក៏ដូចជានីតិវិធីមួយចំនួនដែលកើតមានឡើងនៅពេលដាក់ពាក្យស្នើសុំចុះបញ្ជី របស់នាយកដ្ឋានកម្មសិទ្ធិបញ្ញា។

សារៈសំខាន់នៃការសិក្សាស្រាវជ្រាវនៃប្រធានបទ ផ្តល់ប្រយោជន៍យ៉ាងច្រើនពីការចុះបញ្ជីម៉ាកមួយនៅប្រទេសកម្ពុជាឲ្យជាក់ច្បាស់ ក៏ដូចជាលើកស្ទួយវិស័យសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា។ ម៉ាកដែលធ្វើចរាចរណ៍នៅលើទីផ្សារ ក្នុងព្រះរាជាណាចក្រកម្ពុជាមានភាពរីកចម្រើនគួឲ្យកត់សម្គាល់ ដូច្នេះដើម្បីឲ្យម៉ាកមួយទទួលបានការការពារពីច្បាប់ តើគួធ្វើដូចម្តេច? ម្យ៉ាងទៀតថាតើមានបញ្ហាអ្វីខ្លះដែលកើតមាននៅពេលចុះបញ្ជី ថាតើគួដោះស្រាយបញ្ហាដោយរបៀបណា? ប្រសិនបើចុះបញ្ជីរួចរាល់ថាតើម្ចាស់សិទ្ធិទទួលបានអត្ថប្រយោជន៍អ្វីខ្លះ? ដើម្បីដោះស្រាយរាល់បញ្ហាទាំងនេះ ខ្ញុំបាទសូមលើកយកប្រធានបទមួយ និយាយពី "**ការចុះបញ្ជីម៉ាកនៅកម្ពុជា**" ដែលមានរចនាសម្ព័ន្ធនៃការស្រាវជ្រាវដូចតទៅ៖ ***ទិដ្ឋភាពទូទៅស្តីពីការចុះបញ្ជីម៉ាក*** និយាយអំពីលក្ខណៈរបស់ម៉ាក និងម៉ាកដែលមិនអាចចុះបញ្ជីបាន ក្នុងជំពូកទី១ និង ***ការចុះបញ្ជីម៉ាក*** និយាយអំពី លក្ខខណ្ឌក្នុងការដាក់ពាក្យស្នើសុំចុះបញ្ជី និងការសម្រេចលើពាក្យស្នើសុំ ក្នុងជំពូកទី២។

# ជំពូកទី១៖ ទិដ្ឋភាពទូទៅស្ដីពីការចុះបញ្ជីម៉ាក

ក្រោមទម្រង់ជាសញ្ញាសម្គាល់ ម៉ាកគឺត្រូវបានគេប្រើប្រាស់ដើម្បីកំណត់នូវអត្តសញ្ញាណដោយឡែកនៃផលិតផលណាមួយ ដែលអាចជាទំនិញ ឬសេវា របស់សហគ្រាសណាមួយ នាពេលដែលផលិតផលនោះត្រូវបានផលិតឡើង ឬត្រូវបានយកទៅធ្វើពាណិជ្ជកម្ម។ ទោះយ៉ាងណាក៏ដោយ ម៉ាកទាំងអស់សុទ្ធតែពុំអាចទទួលបានការការពារដោយស្វ័យប្រវត្តិនោះទេ។ ក្នុងលក្ខខណ្ឌដើម្បីអាចទទួលស្គាល់នូវសិទ្ធិស្របច្បាប់លើសញ្ញាសម្គាល់បែបនេះបាន ផលិតករ ឬពាណិជ្ជករ ឬអ្នកផ្ដល់ទាំងឡាយ ចាំបាច់ត្រូវយកម៉ាករបស់ខ្លួន ដែលចង់ឱ្យទទួលបានការការពារ ទៅស្នើសុំការទទួលស្គាល់ពីរដ្ឋជាមុន នៅក្រោមទម្រង់ជាការស្នើសុំចុះបញ្ជីម៉ាក។[2] នៅក្នុងន័យនេះ រដ្ឋអាចទទួលព្រមចុះបញ្ជី កាលណាបើម៉ាកនោះ មានគុណសម្បត្តិគ្រប់គ្រាន់អាចចុះបញ្ជីបាន ហើយនិងអាចបដិសេធមិនចុះបញ្ជីជូនបានដែរ កាលបើម៉ាកនោះពុំបានបំពេញនូវរាល់លក្ខខណ្ឌកំណត់ដោយច្បាប់គ្រប់គ្រាន់ទេ។[3] នៅក្នុងករណីនេះ ម្ចាស់ម៉ាកនឹងពុំអាចមានសិទ្ធិលើម៉ាកនោះបានឡើយ ហើយក៏នឹងពុំមានសិទ្ធិប្រើប្រាស់ម៉ាកនោះផងដែរ។ ដូចន័យដែលបាននិយាយខាងលើនេះអ្នកទាំងឡាយណា ដែលមានបំណងចង់មានសិទ្ធិប្រើប្រាស់លើម៉ាកទាំងអស់ គួរគប្បីស្គាល់ឱ្យបានច្បាស់អំពីលក្ខណៈរបស់ម៉ាក និងស្គាល់ពីម៉ាកដែលច្បាប់ហាមឃាត់មិនឱ្យធ្វើការចុះបញ្ជីម៉ាក ដើម្បីអាចប្រើប្រាស់ម៉ាកមួយដោយស្របតាមផ្លូវច្បាប់បាន។ ដើម្បីអាចយល់ដឹងលើម៉ាកដែលមិនអាចចុះបញ្ជីបាន(ផ្នែកទី២) យើងត្រូវសិក្សាអំពីលក្ខណៈរបស់ម៉ាកជាមុនសិន(ផ្នែកទី១)។

## ផ្នែកទី១៖ លក្ខណៈរបស់ម៉ាក

លក្ខណៈរបស់ម៉ាក ទាំងអស់បានបញ្ញាត្តិយ៉ាងច្បាស់នៅក្នុងច្បាប់ស្ដីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ និងអនុក្រឹត្យស្ដីពីការអនុវត្តច្បាប់ស្ដីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ និងលិខិតបទដ្ឋានដែលពាក់ព័ន្ធមួយចំនួនទៀត។ ម៉ាកគឺជាសញ្ញាសម្រាប់សម្គាល់ទំនិញ ឬសេវា។ ម៉ាកអាចមានលក្ខណៈជា ពាក្យ អក្សរ រូបភាព រូបសញ្ញា (ឡូហ្គោ) និមិត្តសញ្ញា ពណ៌ បង្គុំនៃពណ៌ ឬបង្គុំនៃសញ្ញាទាំងនេះ។ ហើយមុខងាររបស់ម៉ាក គឺដើម្បីអនុញ្ញាតឱ្យអតិថិជនអាចសម្គាល់ និងធ្វើការបែងចែកអត្តសញ្ញាណនៃទំនិញ ឬសេវារបស់សហគ្រាសមួយ ជាមួយនឹងទំនិញ ឬសេវារបស់សហគ្រាសដែលជាដៃគូប្រកួតប្រជែង។ ការប្រើប្រាស់ម៉ាក គឺដើម្បីសម្គាល់នូវគុណភាពនៃទំនិញ ឬសេវារបស់សហគ្រាសផងដែរ។[4]

[2] សៀវភៅ នីតិកម្មសិទ្ធិបញ្ញា លោកកាន់ សុទ្ធប៉ូលីន, បោះពុម្ពលើកទី២, ឆ្នាំ២០១៤ ទំព័រ ៩៧

[3] ច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាមនិងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, ៧ កុម្ភៈ ឆ្នាំ២០០២, មាត្រា១០ ចំណុច ក

[4] សៀវភៅ នីតិកម្មសិទ្ធិបញ្ញាកម្ពុជា លោកនី វិចិត្រ, បោះពុម្ពលើកទី១ ឆ្នាំ២០១៣, ទំព័រ ១៨២

## ១.១ និយមន័យ

ម៉ាកគឺជាសញ្ញាដែលមើលឃើញ ហើយអាចសំគាល់លក្ខណៈខុសគ្នានៃទំនិញ ឬសេវានៃសហគ្រាសនីមួយៗ។ ចំពោះម៉ាកដែលប្រើប្រាស់សម្រាប់ទំនិញហៅថាពាណិជ្ជសញ្ញា ហើយម៉ាកដែលប្រើប្រាស់សម្រាប់សម្គាល់សេវា ហៅថា សេវាសញ្ញា។[5] ម៉ាកទាំងពីរប្រភេទនេះត្រូវបានគេហៅជារួមថាជា ម៉ាក។ អតិថិជនទូទៅ អាចធ្វើការកត់សម្គាល់យ៉ាងងាយស្រួលនូវប្រភេទនៃម៉ាក ជាពាណិជ្ជសញ្ញា ឬសេវាសញ្ញា ដោយផ្អែកទៅលើទំនិញ ឬសេវាដែលពាក់ព័ន្ធនឹងម៉ាកនោះ។

ឧទាហរណ៍៖ ម៉ាក APPLE ជាពាណិជ្ជសញ្ញាដែលត្រូវបានប្រើប្រាស់លើផលិតផលអេឡិចត្រូនិក។

ឧទាហរណ៍៖ ម៉ាក DHL ជាសេវាសញ្ញាត្រូវបានប្រើប្រាស់សម្រាប់ផ្តល់សេវាដឹកជញ្ជូន។

យោងតាមនិយមន័យនៃច្បាប់ស្តីម៉ាករបស់ព្រះរាជាណាចក្រកម្ពុជា អ្វីដែលអាចទុកជាម៉ាកបានគឺជាសញ្ញាដែលអាចមើលឃើញ។[6] និយាយម្យ៉ាងទៀត ច្បាប់ទទួលស្គាល់តែសញ្ញាដែលមើលឃើញប៉ុណ្ណោះ ដែលអាចចុះបញ្ជីជាម៉ាកបាន ហើយសញ្ញាដែលមិនអាចមើលឃើញ មិនអាចត្រូវបានចាត់ទុកថាជាម៉ាកក្រោមច្បាប់របស់ប្រទេសកម្ពុជាឡើយ។ ម្យ៉ាងវិញទៀត ម៉ាកមានគោលដៅសម្រាប់សម្គាល់ភាពខុសគ្នានៃទំនិញ ឬសេវានៃសហគ្រាសប៉ុណ្ណោះ។[7] នោះមានន័យថាមានតែនីតិបុគ្គល ឬក្រុមហ៊ុនពាណិជ្ជកម្ម ប៉ុណ្ណោះដែលអាចក្លាយជាម្ចាស់ម៉ាក យោងតាមច្បាប់របស់កម្ពុជា។ ប៉ុន្តែទោះបីជាច្បាប់ចែងយ៉ាងដូច្នេះក៏ដោយ ក្នុងករណីអនុវត្តទាំងរូបវន្តបុគ្គលទាំងនីតិបុគ្គលអាចជាម្ចាស់ម៉ាក។[8]

នៅប្រទេសកម្ពុជាយើងបើតាមច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ គេការពារតែទៅលើម៉ាកដែលអាចមើលឃើញតែប៉ុណ្ណោះ។[9] ប៉ុន្តែនៅបណ្តាលប្រទេសមួយចំនួនទៀតលើពិភពលោក ច្បាប់នៃរដ្ឋមួយចំនួនការពារលើម៉ាកដែលពុំអាចមើលឃើញ មានជាអាទិ៍ សំឡេង ក្លិន រសជាតិ។ល។ ដូចនេះម៉ាកត្រូវបានបែងចែកដូចតទៅ៖ ម៉ាក Traditional Mark ម៉ាក Non-Traditional Mark ម៉ាកសមូហភាព ឬម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ម៉ាកបញ្ជាក់គុណភាពទំនិញ (Certification Mark)។[10]

---

[5] ច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាមនិងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, ៧ កុម្ភៈ ឆ្នាំ២០០២, មាត្រា២ ចំណុច ក
[6] ច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាមនិងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, ៧ កុម្ភៈ ឆ្នាំ២០០២, មាត្រា២ ចំណុច ក
[7] ច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាមនិងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, ៧ កុម្ភៈ ឆ្នាំ២០០២, មាត្រា២ ចំណុច ក
[8] សៀវភៅ នីតិកម្មសិទ្ធិបញ្ញាកម្ពុជា លោកនី វិចិត្រ, បោះពុម្ពលើកទី១ ឆ្នាំ២០១៣, ទំព័រ ១៨៥
[9] ច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាមនិងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, ៧ កុម្ភៈ ឆ្នាំ២០០២, មាត្រា២ ចំណុច ក
[10] សៀវភៅ នីតិកម្មសិទ្ធិបញ្ញាកម្ពុជា លោកនី វិចិត្រ, បោះពុម្ពលើកទី១ ឆ្នាំ២០១៣, ទំព័រ ១៨៥

**១.១.១ ម៉ាកដែលមានលក្ខណៈធម្មតា** ( Traditional Mark )

ម៉ាកដែលមានលក្ខណៈធម្មតា មានដូចជា ឈ្មោះ(ឈ្មោះពិត ឬឈ្មោះសិប្បនិម្មិត) អក្សរ លេខ រូបភាព និមិត្តសញ្ញា ឡូហ្គោ ពាក្យ បង្គុំនៃពណ៌ ឬបង្គុំនៃសញ្ញាទាំងនេះ។[11]

ឧទាហរណ៍៖

ម៉ាកជាពាក្យ

ម៉ាកជាអក្សរ

ម៉ាកជាលេខ



ម៉ាកជាការរួមគ្នានៃពាក្យនិងលេខ

ម៉ាកជារូបសញ្ញា

ម៉ាកជាការរួមគ្នានៃអក្សរនិងរូបសញ្ញា

ម៉ាកជាបង្គុំនៃពណ៌



ម៉ាកជាឈ្មោះ

ម៉ាកជាហត្ថលេខា



[11] សៀវភៅ នីតិកម្មសិទ្ធិបញ្ញាកម្ពុជា លោកនី វិចិត្រ, បោះពុម្ពលើកទី១ ឆ្នាំ២០១៣, ទំព័រ ១៨៥

**១.១.២ ម៉ាក** Non-Traditional Mark

ម៉ាក Non-Traditional សំដៅទៅលើម៉ាកផ្សេងក្រៅពី Traditional Mark។ ម៉ាក Non-Traditional មានជាអាទិ៍ សំឡេង ក្លិន ឬរសជាតិ។ នៅបណ្ដាប្រទេសមួយចំនួន ច្បាប់ជាតិបញ្ញត្តិអំពីកិច្ចការពារម៉ាក Non-Traditional នេះ។[12]

ឧទាហរណ៍៖ ក្រមកម្មសិទ្ធិបញ្ញានៃប្រទេសបារាំង បានបញ្ញត្តិការពារលើម៉ាកដែលជាសំឡេង។ ម៉ាកជាសំឡេងមាន សំឡេងភ្លេង ឬឃ្លាភ្លេង។

បើយើងបកស្រាយផ្ទុយមកវិញ មានន័យថាសញ្ញាដែលមិនអាចមើលឃើញ ច្បាប់ម៉ាកមិនទទួលឱ្យចុះបញ្ជីដើម្បីទទួលបានការការពារឡើយ។ សម្រាប់ប្រទេសកម្ពុជា បញ្ហាដែលចោទឡើងគឺ ក្នុងក្របខណ្ឌនៃកិច្ចការពារម៉ាក យោងតាមមាត្រា ២៦ នៃច្បាប់ម៉ាក ចំពោះម៉ាកល្បី ទោះបីបានចុះបញ្ជី ឬមិនបានចុះបញ្ជីក៏ដោយ ត្រូវបានការពារក្រោមច្បាប់ម៉ាករបស់ប្រទេសកម្ពុជា។

**១.១.៣ ម៉ាកសមូហភាព ឬម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ**

ម៉ាកសមូហភាព គឺជាសញ្ញាដែលមើលឃើញសំដៅប្រើក្នុងការដាក់ពាក្យសុំចុះបញ្ជី ហើយអាចសម្គាល់នូវប្រភពដើមនៃទំនិញឬសេវា ឬសម្គាល់នូវចរិត លក្ខណៈរួមដទៃទៀត គិតទាំងគុណភាពនៃទំនិញឬសេវា របស់សហគ្រាសផ្សេងៗគ្នា ដែលប្រើសញ្ញានោះ ក្រោមការគ្រប់គ្រងរបស់ម្ចាស់ម៉ាកសមូហភាពដែលបានចុះបញ្ជី។[13] ច្បាប់ស្ដីពីម៉ាកសម្គាល់ទីតាំងភូមិសាស្ត្រក៏បានចែងថា ម៉ាកសម្គាល់ទីតាំងភូមិសាស្ត្រ ក៏អាចសំដៅដល់ឈ្មោះ សញ្ញាសម្គាល់ ឬរូបភាពផ្សេងៗទៀត ដែលមានលក្ខណៈញែកដាច់ដែលជាឈ្មោះ ឬតំណាងឱ្យប្រភពដើមនៃតំបន់ភូមិសាស្ត្រមួយ សម្រាប់កំណត់អត្តសញ្ញាណទំនិញដែលមានប្រភពក្នុងភូមិសាស្ត្រនោះ ដែលបានផ្ដល់ជាមូលដ្ឋានគ្រឹះដល់គុណភាព កិត្តិសព្ទ ឬចរិតលក្ខណៈផ្សេងទៀតនៃទំនិញដែលកើតចេញពីតំបន់ភូមិសាស្ត្រនោះ។

**១.១.៤ ម៉ាកបញ្ជាក់គុណភាពទំនិញ** ( Certification Mark )

ម៉ាកបញ្ជាក់គុណភាពទំនិញ (ឬផលិតផល) សំដៅទៅលើសញ្ញាដែលបញ្ជាក់ពីភាពអនុលោមនៃផលិតផលមួយ តាមការតម្រូវនៃស្តង់ដារផលិតផលមួយ មានសញ្ញាបញ្ជាក់គុណភាព សុវត្ថិភាព និងចុះបញ្ជីផលិតផល។ ម៉ាកប្រភេទនេះបុគ្គលណាក៏មានសិទ្ធិប្រើប្រាស់ដែរ ដោយគ្រាន់តែគោរពតាមលក្ខខណ្ឌតម្រូវដោយច្បាប់ស្ដីពីស្តង់ដារ សម្រាប់ផលិតផលឧស្សាហកម្ម។ វាពុំមានសិទ្ធិផ្ដាច់មុខសម្រាប់បុគ្គលណាមួយជាក់លាក់នោះទេ។ សញ្ញាទាំងនោះមានបីប្រភេទ[14]៖

---

[12] សៀវភៅ នីតិកម្មសិទ្ធិបញ្ញាកម្ពុជា លោកនី វិចិត្រ, បោះពុម្ពលើកទី១ ឆ្នាំ២០១៣, ទំព័រ ១៨៨

[13] ច្បាប់ស្ដីពី ម៉ាក ពាណិជ្ជនាមនិងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, ៧ កុម្ភៈ ឆ្នាំ២០០២, មាត្រា២ ចំណុច ខ

[14] ប្រកាសរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល លេខ១១២ ចុះថ្ងៃទី១១ កុម្ភៈ ឆ្នាំ២០០៤ ស្ដីពីសញ្ញាសម្គាល់ស្តង់ដារឧស្សាហកម្មកម្ពុជា។

| | |
|---|---|
| សញ្ញាបញ្ជាក់គុណភាពទំនិញ | CS 00x-00y |
| សញ្ញាបញ្ជាក់សុវត្ថិភាពទំនិញ | CS 00x-00y |
| សញ្ញាបញ្ជាក់ពីការចុះបញ្ជីផលិតផល | XXYYY/ZZ<br>សញ្ញាចុះបញ្ជីផលិតផល |

ម៉ាកទាំងបីខាងលើនេះ ត្រូវស្ថិតនៅក្រោមក្របខណ្ឌដោយឡែកស្របតាមច្បាប់ស្តីពី ស្តង់ដារកម្ពុជា ពោលគឺមិនស្ថិតនៅក្រោមច្បាប់ម៉ាកឡើយ។

### ១.២ មុខងារនៃម៉ាក

មុខងារសំខាន់របស់ម៉ាក គឺដើម្បីអនុញ្ញាតឱ្យអតិថិជនអាចសម្គាល់ និងធ្វើការបែងចែករវាងទំនិញ ឬសេវារបស់សហគ្រាសដែលជាដៃគូប្រកួតប្រជែង។ ការប្រើប្រាស់ម៉ាក គឺដើម្បីសម្គាល់នូវគុណភាពនៃទំនិញ ឬសេវារបស់សហគ្រាសផងដែរ។ ដូចនេះហើយ ម៉ាកមានមុខងារយ៉ាងសំខាន់សម្រាប់សហគ្រាសប្រកួតប្រជែង[15]៖

- ទាក់ទាញអតិថិជន និងពង្រឹងយុត្តិសាស្រ្តផ្សព្វផ្សាយទីផ្សារ។
- កំណត់អំពីរូបភាព និងកេរ្តិ៍ឈ្មោះរបស់សហគ្រាស។
- បង្កើនភាពទុកចិត្តពីសំណាក់អ្នកប្រើប្រាស់ ដែលបង្កើតបានជាមូលនីធិពាណិជ្ជកម្មដ៏រឹងមាំសម្រាប់សហគ្រាស។
- កំណត់អំពីគុណភាពនៃទំនិញ ឬសេវា និងទំនុកចិត្តរបស់អ្នកប្រើប្រាស់លើទំនិញ ឬសេវាដែលពាក់ម៉ាកនោះ។
- ផ្តល់ការលើកទឹកចិត្តដល់សហគ្រាសដើម្បីពង្រីកការវិនិយោគ និងពង្រឹងគុណភាពនៃទំនិញ ឬសេវាដែលពាក់ម៉ាកនោះដែលជាលទ្ធផលវានឹងផ្តល់តម្លៃ និងភាពល្បីនៃម៉ាកនោះត្រឡប់មកវិញចំពោះម្ចាស់ម៉ាក។

[15] សៀវភៅ នីតិកម្មសិទ្ធិបញ្ញាកម្ពុជា លោកនី វិចិត្រ, បោះពុម្ពលើកទី១ ឆ្នាំ២០១៣, ទំព័រ ១៨៣

## ១.៣ អត្ថប្រយោជន៍នៃម៉ាកដែលបានចុះបញ្ជី

ការចុះបញ្ជីម៉ាក ផ្តល់អត្ថប្រយោជន៍ជាច្រើនដល់ម្ចាស់ម៉ាក។ ការចុះបញ្ជីម៉ាក គឺជាការយកម៉ាកដែលខ្លួនមានស្រាប់ទៅចុះបញ្ជី ដើម្បីឱ្យម៉ាកនោះទទួលបានការការពារពីច្បាប់ ប្រឆាំងនឹងការប្រកួតប្រជែងមិនស្មោះត្រង់។ ការចុះបញ្ជីម៉ាកគឺបានផ្តល់លក្ខណៈពិសេសជាច្រើនដល់ទៅម្ចាស់ម៉ាក ដែលម្ចាស់ម៉ាកអាចជៀសផុតពីការលួចបន្លំ និងជម្លោះលើការប្រើប្រាស់ម៉ាកដូចគ្នា ឬស្រដៀងគ្នា។ ហើយប្រទេសកម្ពុជាក៏បានចូលរួមពិធីសារ Madrid កាលពីខែមីនា ឆ្នាំ២០១៥ ដោយកិច្ចព្រមព្រៀងនេះចូលជាធរមានកាលពីខែមិថុនា ឆ្នាំ២០១៥។ ស្ថិតក្រោមពិធីសារMadrid ម៉ាកដែលបានចុះបញ្ជីនៅកម្ពុជា ត្រូវបានទទួលស្គាល់ដោយសមាជិកកិច្ចព្រមព្រៀងទាំងអស់ ចំនួន ៩៨ ដែលគ្របដណ្តប់លើប្រទេសចំនួន១១៤។[16] ហើយចំពោះការផ្តល់សេវាចុះបញ្ជីម៉ាកនៅព្រះរាជាណាចក្រកម្ពុជា គឺស្របតាមស្តង់ដារអន្តរជាតិដែលអង្គការកម្មសិទ្ធបញ្ញាពិភពលោកបានផ្តល់នូវប្រព័ន្ធ IPAS ប្រើប្រាស់ជាមួយកុំព្យូទ័រដែលពិនិត្យម៉ាកតាមជំហាននីមួយៗ ដែលរួមមានអត្ថន័យ សម្លេងអាន រូបភាពមើលឃើញ និងធ្វើការប្រៀបធៀបមុខទំនិញ និងសេវាដែលដូច ឬប្រហាក់ប្រហែល ឬមានទំនាក់ទំនងគ្នាយ៉ាងជិតស្និត។ ទន្ទឹមនេះ ត្រូវពិនិត្យមើលពាក្យស្លាក ពាក្យទូទៅ ប្រភេទ បរិមាណ គុណភាព និងចំណុចផ្សេងៗជាច្រើនទៀតតាមស្តង់ដារអន្តរជាតិ។[17] ដូចនេះការចុះបញ្ជីម៉ាកនេះ គឺបានផ្តល់អត្ថប្រយោជន៍យ៉ាងច្រើនដល់ទៅសង្គម ម្ចាស់ម៉ាក និងអ្នកប្រើប្រាស់។

### ១.៣.១ អត្ថប្រយោជន៍ចំពោះសង្គម

វាជាការប្រសើរចំពោះសង្គម នៅពេលដែលមានការចុះបញ្ជីម៉ាក ព្រោះថារដ្ឋអាចទទួលបាននូវកម្រៃរដ្ឋបាលពីការចុះបញ្ជីម៉ាក និងកម្រៃរដ្ឋបាលពាក់ព័ន្ធនានា ដូចជាការបញ្ជាក់អំពីការប្រើប្រាស់ ឬមិនប្រើប្រាស់ ការផ្លាស់ប្តូរផ្សេងៗ ការលុបម៉ាកចេញពីបញ្ជី ការចុះបញ្ជីសារឡើងវិញ និងការបោះពុម្ពផ្សាយ។[18] មួយវិញទៀតការចុះបញ្ជីម៉ាកនេះបង្ហាញឱ្យឃើញនូវសកម្មភាពនៃការប្រកួតប្រជែងដោយស្មោះត្រង់ក្នុងវិស័យពាណិជ្ជកម្ម ដែលផ្តល់ទំនុកចិត្តដល់វិនិយោគិនបរទេស ក្នុងការមកបណ្តាក់ទុននៅព្រះរាជាណាចក្រកម្ពុជា ដែលវាជាផ្នែកមួយក្នុងការអភិវឌ្ឍន៍វិស័យសេដ្ឋកិច្ច ឱ្យមានភាពរីកចម្រើនឡើង។ តាមរយៈការចុះបញ្ជីម៉ាកនេះ រដ្ឋអាចគ្រប់គ្រង និងដោះស្រាយនូវរាល់បញ្ហានានាដែលទាក់ទិនទៅនឹងម៉ាកបានល្អ ដោយផ្អែកលើភស្តុតាងនានាដែលមានតម្កល់ទុកនៅនាយកដ្ឋានកម្មសិទ្ធិបញ្ញា និងនាយកដ្ឋានចុះបញ្ជីនៃក្រសួងពាណិជ្ជកម្ម។

---

[16] សម្តីរបស់លោកលោក ប៉ាន សូរស័ក្តិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម កាលពីថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការប្រព័ន្ធចុះបញ្ជីម៉ាកតាមប្រព័ន្ធអេឡិចត្រូនិក

[17] គេហទំព័រ http://www.service.gov.kh/service/101433

[18] ប្រកាសអន្តរក្រសួងស្តីពីតម្លៃរដ្ឋបាលក្នុងការចុះបញ្ជីម៉ាក និងកម្រៃរដ្ឋបាលពាក់ព័ន្ធនានា ឆ្នាំ២០០៧

**១.៣.២ អត្ថប្រយោជន៍ចំពោះម្ចាស់ម៉ាក**

ការការពារម៉ាក ដែលបានចុះក្នុងបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា នឹងប្រឆាំងលើការប្រកួតប្រជែងមិនស្មោះត្រង់លើការបង្កើត ការប្រើប្រាស់ម៉ាក និងជាពិសេសជួយជំរុញ និងការពារសហគ្រាសធុនតូច និងមធ្យម សមាគមន៍ផលិតករឱ្យផលិតទំនិញបានច្រើន ដើម្បីបម្រើដល់តម្រូវការក្នុងប្រទេស និងអាចឈានឡើងដល់ការនាំចេញ និងទាក់ទាញដល់វិនិយោគពីបរទេស។ ដោយការចុះបញ្ជីម៉ាកនឹងធ្វើឱ្យម៉ាកនោះមានអនុភាពគតិយុត្តិ ជាហេតុដែលនាំឱ្យម្ចាស់ម៉ាកមានសិទ្ធិ និងបានផ្តល់អត្ថប្រយោជន៍ជាច្រើនដល់ម្ចាស់ម៉ាកផ្ទាល់តែម្តង។ ចំពោះសិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក ត្រូវបានគេទទួលស្គាល់តាមរយៈការចុះបញ្ជី មានន័យថាគឺការចុះបញ្ជីម៉ាក ម្ចាស់ម៉ាកនឹងមានសិទ្ធិប្រឆាំងនូវរាល់ការរំលោភបំពាននានា និងមានសិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាករបស់ខ្លួន។

**ក. ការទទួលបានសិទ្ធិផ្តាច់មុខលើម៉ាក**

សិទ្ធិផ្តាច់មុខនៃម៉ាកចំពោះម្ចាស់ម៉ាក គឺជាសកម្មភាពមួយដែលម្ចាស់ម៉ាកអាចធ្វើអ្វីបានតាមដែលខ្លួនចង់ធ្វើ ដែលកុំឱ្យតែការធ្វើសកម្មភាពនោះវាប៉ះពាល់ទៅដល់អ្នកដទៃ ហើយស្ថិតនៅក្រោមទម្រង់ដែលអាចញែកដាច់ពីគ្នានៃម៉ាក។ ហើយចំពោះសិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាកគឺត្រូវបានទទួលស្គាល់តាមរយៈការចុះបញ្ជី។[19] ហេតុដូចនេះដើម្បីជៀសវាងការលួចបន្លំ ជម្លោះលើការប្រើប្រាស់ម៉ាកដូចគ្នា ឬស្រដៀងគ្នា រូបវន្តបុគ្គល នីតិបុគ្គល អាជីវករ សហគ្រិនទាំងអស់គួរតែយកម៉ាករបស់ខ្លួនទៅធ្វើការចុះបញ្ជី ដើម្បីទទួលបានសិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាករបស់ខ្លួន ដូចខាងក្រោម[20]៖

- ចំពោះម៉ាកដែលទាក់ទងនឹងទំនិញ ឬសេវាដែលបានចុះបញ្ជីរួចហើយ ការប្រើប្រាស់ម៉ាកនោះដោយជនណាមួយក្រៅពីម្ចាស់ដើមនៃម៉ាក ត្រូវមានការយល់ព្រមពីម្ចាស់ម៉ាកដើមជាមុនសិន។
- ម្ចាស់ដើមនៃម៉ាកមានសិទ្ធិប្តឹងទៅតុលាការប្រឆាំងនឹងជនណាម្នាក់ ដែលប្រើប្រាស់ដោយរំលោភនូវម៉ាករបស់ខ្លួន ដោយគ្មានការយល់ព្រម ពីម្ចាស់ដើមៗក៏មានសិទ្ធិប្តឹងផងដែរចំពោះការប្រើប្រាស់នូវសញ្ញាដែលប្រហាក់ប្រហែលនឹងម៉ាកដែលខ្លួនបានចុះបញ្ជីរួចហើយ និងការប្រើប្រាស់ម៉ាកដែលទាក់ទិនទៅនឹងទំនិញ និងសេវាដែលប្រហាក់ប្រហែល ទៅនឹងទំនិញ ឬសេវានៃម៉ាកដែលចុះបញ្ជីរួចហើយនោះ ហើយដែលអាចបណ្តាលឱ្យមានការភ័ន្តច្រឡំជាសាធារណៈ។

[19] ច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាមនិងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, ៧ កុម្ភៈ ឆ្នាំ២០០២, មាត្រា ៣

[20] គេហទំព័រ http://www.service.gov.kh/service/101433

- ការខកខានមិនបានចុះបញ្ជីការពារម៉ាកអាចនាំដល់ផលវិបាកនានាដូចជា មិនអាចទប់ស្កាត់ ឬប្ដឹងទៅអាជ្ញាធរមានសមត្ថកិច្ចប្រឆាំងនឹងអ្នកប្រើប្រាស់ម៉ាកដែលដូច ឬស្រដៀងនឹងម៉ាករបស់ខ្លួនដោយគ្មានការអនុញ្ញាត ឬលំបាកក្នុងការផ្ទេរសិទ្ធិប្រើប្រាស់ម៉ាករបស់ខ្លួនទៅអ្នកដទៃជាដើម។

ការចុះបញ្ជីម៉ាក នឹងធ្វើឱ្យម្ចាស់ម៉ាកមានសិទ្ធិផ្ដាច់មុខក្នុងការប្រើប្រាស់ម៉ាករបស់ខ្លួនដោយស្របច្បាប់ ដែលទទួលបានការការពារដែលមានរយៈពេលកំណត់ និងការពារពីអំពើប្រកួតប្រជែងមិនស្មោះត្រង់ណាមួយដែលកើតមានថែមទៀតផង។ មួយវិញទៀតម្ចាស់ម៉ាកក៏មានសិទ្ធិឱ្យតតិយជនប្រើប្រាស់ម៉ាករបស់ខ្លួនផងដែរ តាមរយៈការផ្ដល់អជ្ញាប័ណ្ណ ឬហ្វ្រេនឆាយជាដើម។

**ខ. ការទទួលបានសិទ្ធិប្រឆាំងនឹងការរំលោភបំពានលើម៉ាក**

កាលណាបើម្ចាស់ម៉ាកបានយកម៉ាករបស់ខ្លួនទៅចុះបញ្ជី ម្ចាស់ដើមនៃម៉ាកមានសិទ្ធិប្ដឹងទៅតុលាការ ប្រឆាំងនឹងជនណាម្នាក់ ដែលប្រើប្រាស់ដោយរំលោភនូវម៉ាករបស់ខ្លួន។ អំពើដែលចាត់ទុកថាជាអំពើដែររំលោភបំពានទៅលើម៉ាក គឺជាការប្រព្រឹត្តទាំងឡាយណាដែលធ្វើឡើងនៅកំឡុងពេលសុពលភាពនៃម៉ាក របស់ម្ចាស់ម៉ាកដែលបានចុះបញ្ជីនៅកម្ពុជា ដោយជនណាម្នាក់ក្រៅពីម្ចាស់នោះ និងមិនមានការអនុញ្ញាតពីម្ចាស់ម៉ាក។[21] ម្ចាស់ម៉ាកក៏មានសិទ្ធិប្ដឹងចំពោះការប្រើប្រាស់នូវសញ្ញា ដែលដូច ឬប្រហាក់ប្រហែលទៅនឹងម៉ាកដែលខ្លួនដែលបានចុះបញ្ជីរួច និងការប្រើប្រាស់ម៉ាកដែលទាក់ទិនទៅនឹងទំនិញ និងសេវា ដែលប្រហាក់ប្រហែលទៅនឹងទំនិញ ឬសេវានៃម៉ាកដែលបានចុះបញ្ជីរួចហើយនោះ ហើយដែលអាចបណ្ដាលឱ្យមានការភ័ន្តច្រឡំជាសាធារណៈ។[22]

**១.៣.៣ អត្ថប្រយោជន៍ចំពោះអ្នកប្រើប្រាស់**

ពេលដែលម៉ាកមួយបានចុះបញ្ជីរួច ម៉ាកនោះនឹងទទួលបានការការពារតាមផ្លូវច្បាប់ដោយគ្មានបុគ្គលណាម្នាក់ អាចយកម៉ាកនោះទៅប្រើប្រាស់ ឬធ្វើអាជីវកម្ម ដោយគ្មានការអនុញ្ញាតយល់ព្រមពីម្ចាស់ម៉ាកនោះបានឡើយ។ វាបានធ្វើឱ្យមានភាពងាយស្រួលដល់អ្នកប្រើប្រាស់ ក្នុងការទិញទំនិញដែលពិតប្រាកដ ដែលធានាឱ្យបានទំនិញដែលសុទ្ធល្អ ព្រោះគ្មានការលួចបន្លំពីសហគ្រាសណាមួយផ្សេងទៀតនោះទេ។ ម្យ៉ាងវិញទៀតសូម្បីតែ ម៉ាកដែលមានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងម៉ាកនោះក៏គ្មានដែរ ដែលសាធារណៈជននឹងងាយស្រួលក្នុងការទិញទំនិញ និងធានាឱ្យបាននូវទំនិញដែលពិតប្រាកដដោយគ្មានការភ័ន្តច្រឡំ។[23]

---

[21] ច្បាប់ស្ដីពី ម៉ាក ពាណិជ្ជនាមនិងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, ៧ កុម្ភៈ ឆ្នាំ២០០២, មាត្រា២៤

[22] ច្បាប់ស្ដីពី ម៉ាក ពាណិជ្ជនាមនិងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, ៧ កុម្ភៈ ឆ្នាំ២០០២, មាត្រា១១ ចំណុច ខ

[23] សារណាបញ្ចប់ការសិក្សា នីតិវិធីនៃការចុះបញ្ជី និងការដោះស្រាយវិវាទស្ដីពីម៉ាក លោក ប៉ែន វីរៈឧត្ដម និងលោក ផន សុគន្ធា ឆ្នាំ២០១៣

### ១.៤ ម៉ាកដែលអាចចុះបញ្ជីបាន

ក្នុងការចុះបញ្ជីម៉ាក មុននឹងដាក់ពាក្យសុំ យើងគួរតែពិនិត្យមើលថា តើសញ្ញានោះមិនទាន់ត្រូវបានដាក់ពាក្យស្នើសុំ ឬមិនទាន់ចុះបញ្ជីម៉ាក សម្រាប់ទំនិញឬសេវាដូចគ្នាដោយនរណាម្នាក់ផ្សេងទៀតទេ។ ហើយព័ត៌មាននេះយើងអាចរកបាន ដោយការស្រាវជ្រាវនៅនាយកដ្ឋានកម្មសិទ្ធិបញ្ញា តាមរយៈគេហទំព័រ www.cambodiaip.gov.kh/tmsearch ឬ www.wipo.int/branddb/kh/en ។[24]

ហើយមុននឹងដាក់ពាក្យស្នើសុំទៅនាយកដ្ឋានកម្មសិទ្ធិបញ្ញា ដើម្បីទទួលបានការការពារម៉ាករបស់យើងនៅកម្ពុជា យើងគួរតែប្រាកដថាសញ្ញាដែលអ្នកកំពុងគ្រោងប្រើជាម៉ាកនៅកម្ពុជានោះមិនត្រូវបានដកចេញពីការការពារដោយច្បាប់ម៉ាកទេ។[25]

ដូចនេះដើម្បីទទួលបានការការពារទៅលើម៉ាក មួយ យើងត្រូវយកម៉ាករបស់ខ្លួនដែលទៅចុះបញ្ជី ដោយការចុះបញ្ជីនេះ គឺត្រូវគោរពតាមនីតិវិធីត្រឹមត្រូវដែលបានកំណត់ ទើបអាចចុះបញ្ជីបាន។ ដូច្នេះនិយាយជារួមមក ម៉ាកមួយដែលអាចចុះបញ្ជីបាន គឺជាគ្រប់សញ្ញាសម្គាល់ដែលមើលឃើញទាំងអស់ ដែលលើកលែងតែសញ្ញាសម្គាល់ដែលជាម៉ាកដែលមិនអាចចុះបញ្ជីបាន ដូចមានចែងនៅក្នុងមាត្រា៤ នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០២។[26]

## ផ្នែកទី២៖ ម៉ាកដែលមិនអាចចុះបញ្ជីបាន

យ៉ាងណាក៏ដោយការប្រើប្រាស់ម៉ាកណាមួយដោយពុំបានយកទៅចុះបញ្ជីឱ្យបានត្រឹមត្រូវតាមច្បាប់តម្រូវ នឹងពុំអាចទាមទារបាននូវសិទ្ធិឱ្យមានការការពារពីច្បាប់នោះទេ នៅពេលដែលមានការរំលោភបំពានលើសិទ្ធិប្រើប្រាស់ម៉ាករបស់ខ្លួន ពីសំណាក់ជនខិលខូចទាំងឡាយ។[27] ចំពោះការចុះបញ្ជីម៉ាក ម្ចាស់នៃម៉ាកត្រូវតែប្រាកដថាសញ្ញាដែលខ្លួនបានដាក់ស្នើសុំចុះបញ្ជីម៉ាកនោះ ត្រូវតែបានបំពេញទៅតាមលក្ខខណ្ឌដែលច្បាប់បានកំណត់។ ហើយច្បាប់ជាតិ ព្រមទាំងបញ្ញត្តិអន្តរជាតិ ក៏បានបញ្ញាត្តិយ៉ាងច្រើនអំពីម៉ាកដែលមិនអាចចុះបញ្ជីបាន ដែលម៉ាកទាំងនោះសុទ្ធតែត្រូវបានហាមឃាត់។

### ២.១ ម៉ាកដែលហាមឃាត់មិនឱ្យចុះបញ្ជី ក្រោមបទបញ្ញាត្តិអន្តរជាតិ

នៅក្នុងក្របខ័ណ្ឌអន្តរជាតិ បទប្បញ្ញត្តិនៃអនុសញ្ញាអន្តរជាតិទាំងឡាយខាងក្រោមនេះចែងអំពីលក្ខខណ្ឌហាមឃាត់មួយចំនួនក្នុងការចុះបញ្ជីម៉ាក។

---

[24] ARISE + IPR សហការជាមួយនាយកដ្ឋានកម្មសិទ្ធិបញ្ញា, ពិធីសារទីក្រុងម៉ាឌ្រីដ, ខែធ្នូ ឆ្នាំ២០១៨

[25] ARISE + IPR សហការជាមួយនាយកដ្ឋានកម្មសិទ្ធិបញ្ញា, ពិធីសារទីក្រុងម៉ាឌ្រីដ, ខែធ្នូ ឆ្នាំ២០១៨

[26] សៀវភៅ នីតិកម្មសិទ្ធិបញ្ញា លោកកាន់ សុទ្ធប៉ូលីន, បោះពុម្ពលើកទី២, ឆ្នាំ២០១៤ ទំព័រ ១០៥

[27] សៀវភៅ នីតិកម្មសិទ្ធិបញ្ញា លោកកាន់ សុទ្ធប៉ូលីន, បោះពុម្ពលើកទី២, ឆ្នាំ២០១៤ ទំព័រ ១២៥

**២.១.១ អនុសញ្ញាទីក្រុងប៉ារីស ១៨៨៣ ស្តីពីកិច្ចការពារកម្មសិទ្ធិឧស្សាហកម្ម**

អនុសញ្ញាទីក្រុងប៉ារីសហាមឃាត់បណ្តាប្រទេសសមាជិកមិនឱ្យចុះបញ្ជីម៉ាកណា ដែលមានលក្ខណៈដូចទៅនឹងសញ្ញាជាតិ ឬទង់ជាតិនៃរដ្ឋសមាជិកនៃសហគមន៍អឺរ៉ុប ឬអង្គការអន្តរជាតិណាមួយដែលប្រទេសជាសមាជិក។[28] ដូចគ្នាដែរ មាត្រានេះមានវិសាលភាពអនុវត្តចំពោះសញ្ញា ទាំងឡាយណាដែលត្រូវបានអនុម័តឡើងដោយបណ្តារដ្ឋសមាជិក ឬដោយអង្គការអន្តរជាតិនោះ។

**២.១.២ កិច្ចព្រមព្រៀង TRIPS ១៩៩៤**

កិច្ចព្រមព្រៀង TRIPS បានបញ្ញត្តិហាមឃាត់មិនឱ្យចុះបញ្ជីម៉ាកណា ដែលមានលក្ខណៈដូចគ្នាទៅនឹងម៉ាកសម្គាល់ភូមិសាស្ត្រទំនិញសម្រាប់ស្រាទំពាំងបាយជូរ និងសម្រាប់គ្រឿងស្រវឹង។[29]

**២.១.៣ កិច្ចព្រមព្រៀងអន្តរជាតិពាក់ព័ន្ធផ្សេងទៀត**

ក្រៅពីកិច្ចព្រមព្រៀង និងអនុសញ្ញាអន្តរជាតិខាងលើ មានកិច្ចព្រមព្រៀងអន្តរជាតិពិសេសផ្សេងទៀត ដែលបានកំណត់លក្ខខណ្ឌហាមឃាត់ក្នុងការចុះបញ្ជីម៉ាកនូវសញ្ញាមួយចំនួនដូចជា៖

- អនុសញ្ញាទីក្រុង ហ្សឺណែវ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ១៩០៦ ហាមឃាត់ការចុះបញ្ជីម៉ាកដែលជាពាក្យ និងសញ្ញារបស់កាកបាតក្រហម "RED CROSS"។[30]
- អនុសញ្ញា Naiobi ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ១៩៨១ ហាមឃាត់ការចុះបញ្ជីនូវសញ្ញាកង និងសញ្ញាផ្សេងទៀតនៃសញ្ញាកីឡាអូឡាំពិច។
- លិខិតរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោកមួយចំនួនទៀត ដែលបានភ្ជាប់នូវគំរូ ឬសញ្ញា ឬរូបភាពនៃសញ្ញាទង់ជាតិ ឬសញ្ញាជាតិរបស់ប្រទេសសមាជិកនានាដែលត្រូវបានហាមឃាត់មិនអនុញ្ញាតឱ្យចុះបញ្ជីជាម៉ាកនៅក្នុងបណ្តាប្រទេសសមាជិក។

## ២.២ ម៉ាកដែលហាមឃាត់មិនឱ្យចុះបញ្ជី ក្រោមច្បាប់ជាតិ

មិនមែនគ្រប់ម៉ាកទាំងអស់ សុទ្ធតែអាចចុះបញ្ជីដើម្បីទទួលបានការការពារពីច្បាប់នោះទេ នៅក្នុងនោះមានម៉ាកមួយចំនួនដែលច្បាប់មិនអនុញ្ញាត្តិឱ្យធ្វើការចុះបញ្ជី ដោយយោងតាមច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ មានម៉ាកមួយចំនួនដែលមិនអាចចុះបញ្ជីបាន[31]៖

- ម៉ាកដែលមិនអាចសំគាល់លក្ខណៈខុសគ្នានៃទំនិញ ឬសេវា របស់សហគ្រាសមួយទៅនឹងសហគ្រាសមួយផ្សេងទៀត។

[28] អនុសញ្ញាទីក្រុងប៉ារីសស្តីពីកិច្ចការពារកម្មសិទ្ធិឧស្សាហកម្ម ២០ មីនា ១៨៨៣, មាត្រា ៦ស្ទួនទី២(ter)
[29] កិច្ចព្រមព្រៀង ស្តីពីទិដ្ឋភាពពាណិជ្ជកម្ម ទាក់ទងនឹងកម្មសិទ្ធិបញ្ញា(កិច្ចព្រមព្រៀង TRIPS) ឆ្នាំ១៩៩៤, មាត្រា ២៣
[30] អនុសញ្ញាទីក្រុង ហ្សឺណែវ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ១៩០៦ មាត្រា ២៣
[31] ច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាមនិងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, ៧ កុម្ភៈ ឆ្នាំ២០០២, មាត្រា៤

- ម៉ាកដែលបណ្ដាលឲ្យមានការប៉ះពាល់ដល់សណ្ដាប់ធ្នាប់សាធារណៈ សីលធម៌ ឬប្រពៃណីល្អរបស់ជាតិ។
- ម៉ាកដែលអាចនាំឲ្យសាធារណជន ឬមជ្ឈដ្ឋាន ពាណិជ្ជកម្មភ័ន្តច្រឡំទៅនឹងប្រភពភូមិសាស្រ្តនៃទំនិញ ឬសេវាពាក់ព័ន្ធ ឬធាតុដើម ឬលក្ខណៈខាងក្រៅរបស់ទំនិញ ឬសេវានោះ។
- ម៉ាកដែលដូចគ្នា ឬត្រាប់តាម ឬមានចំណុចណាមួយដូច សញ្ញាជាតិ ទង់ជាតិ និងនិមិត្តរូបផ្សេងៗ ឈ្មោះ ឬឈ្មោះសង្ខេប ឬអក្សរកាត់នៃឈ្មោះ ឬសញ្ញា ឬត្រាជាផ្លូវការ ដែលអនុម័តដោយរដ្ឋណាមួយ អង្គការអន្តររដ្ឋាភិបាល ឬអង្គការដែលបង្កើតដោយអនុសញ្ញាអន្តរជាតិមួយលើកលែងតែមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច នៃរដ្ឋនោះ ឬអង្គការនោះ។
- ម៉ាកដែលដូចគ្នា ឬប្រហាក់ប្រហែល ដែលនាំឲ្យច្រឡំគ្នានឹងម៉ាក ឬពាណិជ្ជនាមមួយដែលល្បីក្នុងព្រះរាជាណាចក្រកម្ពុជា ឬបង្កើតពីការបកប្រែនៃម៉ាក ឬពាណិជ្ជនាមដែលល្បីនោះ សម្រាប់ទំនិញ ឬសេវាដូចគ្នា ឬប្រហាក់ប្រហែលគ្នានៃសហគ្រាសមួយទៀត។
- ម៉ាកដែលដូចគ្នា ឬប្រហាក់ប្រហែល ដែលនាំឲ្យច្រឡំគ្នានឹងម៉ាក ឬពាណិជ្ជនាមមួយដែលល្បី ឬបង្កើតពីការបកប្រែនៃម៉ាក ឬពាណិជ្ជនាមដែលល្បីនោះ ហើយដែលបានចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា សម្រាប់ទំនិញ ឬសេវាដែលមិនដូចគ្នា ឬមិនប្រហាក់ប្រហែលគ្នាដោយការប្រើប្រាស់ម៉ាកនោះធ្វើឲ្យខូចប្រយោជន៍របស់ម្ចាស់នៃម៉ាកល្បី។
- ម៉ាកដែលដូចគ្នា ឬស្ទើរតែដូចគ្នាទាំងស្រុងទៅនឹងម៉ាក ដែលជាកម្មសិទ្ធិរបស់ម្ចាស់ផ្សេងដែលបានចុះបញ្ជីរួច ឬបានដាក់ពាក្យស្នើសុំចុះបញ្ជីមុន ឬបានទទួលអាទិភាពចុះបញ្ជីមុននៅឯបរទេស ចំពោះទំនិញ ឬសេវាដូចគ្នា ឬទំនិញ ឬសេវា ដែលពាក់ព័ន្ធគ្នាយ៉ាងជិតស្និទ្ធ។

### ២.២.១ ម៉ាកដែលធ្វើឱ្យមានការភ័ន្តច្រឡំ

ក្នុងលក្ខខណ្ឌចម្បងនៃច្បាប់ស្ដីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ គឺមានគោលបំណងក្នុងការការពារសិទ្ធិស្របច្បាប់របស់ម៉ាក ដែលម្ចាស់ម៉ាកបានចុះបញ្ជីក្នុងបញ្ជីម៉ាក និងផ្ដល់ការការពារប្រឆាំងនឹងការប្រកួតប្រជែងមិនស្មោះត្រង់ លើការបង្កើត ការប្រើប្រាស់ម៉ាកនិងពាណិជ្ជនាម របស់ពាណិជ្ជករ ឬសហគ្រាសនានា ក្នុងការធ្វើពាណិជ្ជកម្មរបស់ពួកគេ។[32] ហេតុនេះចំពោះការប្រើប្រាស់ម៉ាក គឺមិនត្រូវឱ្យមានការភ័ន្តច្រឡំ ទៅលើប្រភេទនៃទំនិញ ឬសេវា រវាងសហគ្រាសមួយទៅសហគ្រាសមួយទៀតនោះទេ។ ដូចនេះម៉ាកដែលអាចបណ្ដាលឲ្យសាធារណៈជន ឬមជ្ឈដ្ឋានពាណិជ្ជកម្ម មានការភ័ន្តច្រឡំទៅលើប្រភេទនៃទំនិញ ឬសេវា គឺជាម៉ាកដែលមិនអាចចុះបញ្ជីបាននោះទេ។

[32] ច្បាប់ស្ដីពី ម៉ាក ពាណិជ្ជនាមនិងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, ៧ កុម្ភៈ ឆ្នាំ២០០២, មាត្រា១

**ក. ម៉ាកដែលមិនអាចបែងចែកលក្ខណៈខុសគ្នានៃទំនិញ ឬសេវា**

ម៉ាកដែលមិនអាចបែងចែកលក្ខណៈខុសគ្នានៃទំនិញ ឬសេវា គឺជាម៉ាកដែលមិនអាចចុះបញ្ជីបាននោះទេ។[33] ក្នុងន័យនេះយើងអាចនិយាយបានថា គឺអាចជាម៉ាកដែលស្តែងឡើងក្រោមទម្រង់មិនអាចបែងចែក ឬមិនអាចសម្គាល់អំពីលក្ខណៈដាច់ដោយឡែកនៃទំនិញ ឬសេវាបាន (ឧទាហរណ៍៖ ម៉ាកដែលស្តែងឡើងក្រោមទម្រង់ជាពណ៌លាតមួយផ្ទាំង ដោយគ្មានបញ្ជាក់សញ្ញាអ្វីបន្ថែម) ម៉ាកដែលជាទំនិញ ឬសេវានោះតែម្តង (ឧទាហរណ៍៖ ម៉ាក ស្វាយ សម្រាប់ទំនិញជាផ្លែស្វាយ ឬម៉ាកឡានសម្រាប់ផលិតផលជារថយន្ត) ឬជាម៉ាកដែលគ្រាន់តែជាការពិពណ៌នានូវលក្ខណៈនៃទំនិញ ឬសេវាណាមួយ (ឧទាហរណ៍៖ ម៉ាក ផ្អែម សម្រាប់ផលិតផលជា ស្ករ ឬស្ករត្នោត ឬទឹកឃ្មុំ...)។[34]

ការមិនអាចបែងចែកបាននេះ គឺត្រូវពឹងផ្អែកលើការយល់ឃើញរបស់សាធារណជន ឬក៏មជ្ឈដ្ឋានពាណិជ្ជកម្ម ពោលគឺសំដៅដល់ការកំណត់របស់អតិថិជន ដែលជាអ្នកប្រើប្រាស់ផ្ទាល់នោះតែម្តង។ ក្នុងន័យនេះបណ្តាលម៉ាកដែលចាត់ទុកថាមិនអាចបែងចែកភាពខុសគ្នានៃទំនិញ ឬសេវារបស់សហគ្រាសមួយ ទៅនឹងសហគ្រាសមួយផ្សេងទៀតបាន ដូចដែលបានបញ្ជាក់ខាងលើនេះ គឺអាចនឹងត្រូវបានចាត់ទុកថាអាចបែងចែកភាពខុសគ្នាបានវិញ កាលណាបើម៉ាកទាំងនោះ ត្រូវបានស្តែងឡើងក្រោមលក្ខណៈពិសេសណាមួយ ដែលនឹងអាចនាំឱ្យអតិថិជននៅក្នុងប្រទេសកម្ពុជាយើង អាចសម្គាល់ភាពខុសគ្នានៃទំនិញ ឬសេវានោះ ពីសហគ្រាសមួយទៅសហគ្រាសមួយផ្សេងទៀតបាន។[35]

**ខ. ម៉ាកដែលនាំឲ្យសាធារណៈជន ឬមជ្ឈដ្ឋានពាណិជ្ជកម្មភ័ន្តច្រឡំទៅនឹងប្រភពភូមិសាស្ត្រទំនិញ ឬសេវា**

ម៉ាកដែលនាំឱ្យសាធារណៈជន ឬមជ្ឈដ្ឋានពាណិជ្ជកម្មភ័ន្តច្រឡំទៅនឹងប្រភពភូមិសាស្ត្រទំនិញ ឬសេវា គឺជាម៉ាកដែលមិនអាចចុះបញ្ជីបាននោះទេ។[36] ក្នុងន័យនេះម៉ាកទាំងឡាយណាដែលធ្វើឱ្យមានការភ័ន្តច្រឡំទៅលើចំណុចធំៗ៣ ដូចជា៖

- ប្រភពភូមិសាស្ត្រនៃទំនិញ៖ ក្នុងន័យនេះការដាក់ឈ្មោះម៉ាកមិនអាចដាក់បានទេ បើសិនជាម៉ាកនោះធ្វើឱ្យអ្នកប្រើប្រាស់មានការភ័ន្តច្រឡំទៅលើប្រភពនៃកន្លែងផលិតទំនិញ ឬតំបន់នៃកន្លែងផលិតទំនិញ ដោយហេតុថាការពិតទំនិញនោះមិនមានប្រភពមកពីទីនោះទេ។

[33] ច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាមនិងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, ៧ កុម្ភៈ ឆ្នាំ២០០២, មាត្រា៤ ចំណុច ក

[34] សៀវភៅ នីតិកម្មសិទ្ធិបញ្ញា លោកកាន់ សុទ្ធប៉ូលីន, បោះពុម្ពលើកទី២, ឆ្នាំ២០១៤ ទំព័រ ១០៦

[35] សៀវភៅ នីតិកម្មសិទ្ធិបញ្ញា លោកកាន់ សុទ្ធប៉ូលីន, បោះពុម្ពលើកទី២, ឆ្នាំ២០១៤ ទំព័រ ១០៣

[36] ច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាមនិងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, ៧ កុម្ភៈ ឆ្នាំ២០០២, មាត្រា៤ ចំណុច គ

ឧទាហរណ៍៖ ម៉ាក ម្រេច ដែលមានប្រភពដាំដុះពីខេត្តក្រចេះ ប៉ុន្តែគាត់បានដាក់ម៉ាកសញ្ញា ម្រេចរបស់គាត់ជាម៉ាក ម្រេចកំពត ។ ធ្វើបែបនេះ ម្រេចនេះគឺមិនអាចចុះបញ្ជីបានទេព្រោះថាវាធ្វើឱ្យមានការភ័ន្តច្រឡំថាម្រេចនោះជាផលិតផលរបស់ម្រេចខេត្តកំពត។

- ធាតុដើមនៃទំនិញ៖ ក្នុងន័យនេះម៉ាកទាំងអស់មិនអាចដាក់ឈ្មោះដែលធ្វើឱ្យសាធារណជនទូទៅ ឬអ្នកធ្វើពាណិជ្ជកម្មមានការភ័ន្តច្រឡំថាម៉ាកនោះមានសារធាតុដើមពិសេសណាមួយដែលជាក់ស្តែងទំនិញនោះមិនមានសារធាតុនោះឡើយ។

ឧទាហរណ៍៖ សញ្ញាថា អ៊ីយ៉ូត សម្រាប់ផលិតផលអំបិលដែលពុំមានលាយសារធាតុអ៊ីយ៉ូត។ ដោយមិនមានសារធាតុអ៊ីយ៉ូត ដូចសញ្ញាបានដាក់ ដែលធ្វើឱ្យមានការច្រឡំទៅលើសារធាតុនៃទំនិញ។

- លក្ខណៈខាងក្រៅរបស់ទំនិញ ឬសេវា៖ ក្នុងន័យនេះ រាល់ទំនិញ ឬសេវាទាំងអស់មិនត្រូវមានរូបរាងដូចគ្នា ឬប្រហាក់ប្រហែលគ្នាទៅនឹងទំនិញដែលបានចុះបញ្ជីរួចហើយនោះទេ ព្រោះវាអាចបណ្តាលឱ្យមានការភ័ន្តច្រឡំ។

ឧទាហរណ៍៖ ម៉ាកទូរស័ព្ទ OPPO និង ម៉ាកទូរស័ព្ទ iPhone បើមើលតែសំបកក្រៅគឺវាមានលក្ខណៈស្ទើតែដូចគ្នា។







OPPO iPhone

## គ. ម៉ាកដែលដូចគ្នា ឬប្រហាក់ប្រហែលគ្នានឹងម៉ាកដែលបានចុះបញ្ជីរួច

ម៉ាកដែលដូចគ្នា ឬប្រហាក់ប្រហែលគ្នានឹងម៉ាកដែលបានចុះបញ្ជីរួចគឺជាម៉ាកដែលមិនអាចចុះបញ្ជីបាននោះទេ។[37] ក្នុងន័យនេះគឺម៉ាកដែលបានចុះបញ្ជីរួចហើយ ហើយរួមបញ្ចូលទាំងម៉ាកបានដាក់ពាក្យស្នើសុំចុះបញ្ជីមុននៅនាយកដ្ឋានកម្មសិទ្ធិបញ្ញា ឬម៉ាកដែលបានទទួលអាទិភាពចុះបញ្ជីមុននៅឯបរទេស ចំពោះទំនិញ ឬសេវាដូចគ្នា។

[37] ច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាមនិងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, ៧ កុម្ភៈ ឆ្នាំ២០០២, មាត្រា៤ ចំណុច ឆ

ឧទាហរណ៍៖ ម៉ាក Amazing Café ដែលមានលក្ខណៈដូច ឬស្ទើរតែមានលក្ខណៈដូចគ្នាទៅនឹងម៉ាក Amazon Café ដែលបានចុះបញ្ជីរួច។

Amazing Café




Amazon Café




ចំពោះគោលការណ៍ឯកទេសកម្មនៃម៉ាកវិញ ម៉ាកមួយ ត្រូវបានការពារឱ្យតែចំពោះទំនិញ ឬសេវាដែលស្ថិតនៅក្នុងវិស័យតែមួយដូចគ្នាទៅនឹងទំនិញ ឬសេវាដែលបានចុះបញ្ជីនោះប៉ុណ្ណោះ។ ឧទាហរណ៍៖ សញ្ញា «Walker» ដែលបានចុះបញ្ជីជាម៉ាកចំពោះតែទំនិញជាស្បែកជើងប៉ុណ្ណោះ ដូចនេះឯកទេសកម្មគឺនៅតែក្នុងវិស័យស្បែកជើងប៉ុណ្ណោះ គឺទំនេរសម្រាប់ទំនិញនៅក្នុងវិស័យផ្សេងៗ ដូចជា ផ្លែឈើ គ្រឿងអេឡិចត្រូនិច រថយន្ត...។[38]

តាមច្បាប់កម្ពុជា គោលការណ៍នៃកិច្ចការពារតាមដែនដី ម៉ាកមួយអាចនឹងទទួលបានកិច្ចការពារលើដែនដីនៃប្រទេសបាន លុះត្រាតែម៉ាកនោះបានចុះបញ្ជីស្របតាមច្បាប់នៃប្រទេសនោះ។ គោលការណ៍នេះ ក៏ត្រូវបានអនុវត្តនៅក្នុងច្បាប់នៃប្រទេសកម្ពុជាផងដែរ ពោលគឺភាពផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាកដែលទទួលបានតាមរយៈការចុះបញ្ជីនៅប្រទេសកម្ពុជា។ ក្នុងលក្ខខណ្ឌមួយដែលម៉ាកនោះដាក់ពាក្យចុះបញ្ជីមុនគេនៅប្រទេសកម្ពុជា នឹងទទួលបានកិច្ចការពារមុន ដោយឡែកម៉ាកដែលមានលក្ខណៈដូច ឬស្រដៀងនឹងម៉ាកដែលបានចុះបញ្ជីរួចហើយ វាមិនត្រូវបានអនុញ្ញាតឱ្យចុះបញ្ជីនោះទេ ករណីនេះត្រូវបានគេហៅថា គោលការណ៍នៃការចុះបញ្ជីមុន។[39]

**ឃ. ម៉ាកដែលដូចគ្នា ឬប្រហាក់ប្រហែលគ្នានឹងម៉ាកល្បី**

ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ នៃព្រះរាជាណាចក្រកម្ពុជា បានប្រកាសទទួលស្គាល់នូវកិច្ចការពារម៉ាកដែលល្បី ទោះបីជាម៉ាកនោះបានចុះបញ្ជី ឬមិនបានចុះបញ្ជីក៏ដោយ។[40] ក៏ប៉ុន្តែច្បាប់យើងមិនបានបញ្ជាក់ពីការកំណត់ម៉ាកណាដែល

[38] សៀវភៅ នីតិកម្មសិទ្ធិបញ្ញា លោកកាន់ សុទ្ធប៉ូលីន, បោះពុម្ពលើកទី២, ឆ្នាំ២០១៤ ទំព័រ ១១៤
[39] សៀវភៅ នីតិកម្មសិទ្ធិបញ្ញាកម្ពុជា លោកនី វិចិត្រ, បោះពុម្ពលើកទី១, ឆ្នាំ២០១៣, ទំព័រ ១៩៨
[40] ច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាមនិងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, ៧ កុម្ភៈ ឆ្នាំ២០០២, មាត្រា៤ ចំណុច ង, ច

អាចហៅជាម៉ាកល្បីឱ្យបានច្បាស់លាស់នោះទេ។ នៅក្នុងន័យទូទៅនៃពាក្យ ម៉ាកមួយនឹងត្រូវចាត់ទុកថាល្បី កាលបើម៉ាកនោះត្រូវបានគេដឹងឮ និងស្គាល់ជាទូទៅ។[41] តែបើយោងតាមមាត្រា២ នៃអនុសាសន៍រួមទាក់ទងនឹងបទប្បញ្ញាត្តិស្តីពីកិច្ចការពារម៉ាកល្បី ឬ Joint Recommendation Concerning Provisions on the Protection of Well-Known Marks ដែលប្រទេសកម្ពុជាយើងជាហត្ថលេខីមួយដែរនោះ បានកំណត់លក្ខខណ្ឌមួយចំនួន ដើម្បីចាត់ទុកថាជាម៉ាកល្បី គឺ[42]៖

- កម្រិតនៃការដឹងឬស្គាល់ម៉ាក ក្នុងផ្នែកនៃសាធារណជនដែលពាក់ព័ន្ធ។
- រយៈពេល វិសាលភាព និងតំបន់ភូមិសាស្ត្រ នៃការប្រើប្រាស់ម៉ាក។
- រយៈពេល វិសាលភាព និងតំបន់ភូមិសាស្ត្រ នៃការផ្សព្វផ្សាយម៉ាក រួមមានការផ្សាយពាណិជ្ជកម្ម ឬការផ្សព្វផ្សាយជាសាធារណៈ និងការដាក់បង្ហាញទំនិញ ឬសេវាដែលបំពាក់ម៉ាក នៅពិព័រណ៍ពាណិជ្ជកម្ម ឬពិព័រណ៍នានា។
- រយៈពេល និងតំបន់ភូមិសាស្ត្រនៃការចុះបញ្ជី និងការស្នើសុំចុះបញ្ជីណាមួយនៃម៉ាក ត្រឹមកម្រិតដែលបង្ហាញពីការប្រើប្រាស់ ឬការស្គាល់ម៉ាក។
- កំណត់ត្រាការអនុវត្តសិទ្ធិម៉ាកដែលជោគជ័យ ជាពិសេសត្រឹមកម្រិតដែលម៉ាកត្រូវបានស្គាល់ថាល្បីដោយអជ្ញាធរមានសមត្ថកិច្ច។
- តម្លៃដែលទាក់ទងម៉ាក។

### ឃ.១ ម៉ាកល្បីដែរមិនបានចុះបញ្ជី

ជាគោលការណ៍ ម៉ាកមួយដែលល្បី នឹងទទួលបានការការពារពីច្បាប់ស្តីពីម៉ាក បើទោះបីជាម៉ាកនោះ ពុំត្រូវបានយកទៅចុះបញ្ជីក៏ដោយ។ នេះដោយហេតុថាច្បាប់ស្តីពីម៉ាកបានផ្តល់តម្លៃខ្ពស់ដល់អ្វីដែលហៅថាភាពល្បីនៃម៉ាកមួយ។ ប៉ុន្តែតាមមាត្រា៤ ចំណុច ង នៃច្បាប់ស្តីពីម៉ាក បានចែងថាម៉ាកដែលដូចគ្នា ឬប្រហាក់ប្រហែល ដែលនាំឲ្យច្រឡំគ្នានឹងម៉ាក ឬពាណិជ្ជនាមមួយដែលល្បីក្នុងព្រះរាជាណាចក្រកម្ពុជា ឬបង្កើតពីការបកប្រែនៃម៉ាក ឬពាណិជ្ជនាមដែលល្បីនោះ សម្រាប់ទំនិញ ឬសេវាដូចគ្នា ឬប្រហាក់ប្រហែលគ្នានៃសហគ្រាសមួយទៀត។ ក្នុងន័យនេះគឺម៉ាកល្បីនៃទំនិញ ឬសេវាណាមួយ ដែលមិនបានចុះបញ្ជី នឹងមានទទួលបានកិច្ចការពារពីច្បាប់ តែសម្រាប់ប្រភេទនៃទំនិញ ឬសេវាដូចគ្នា ឬប្រហាក់ប្រហែលគ្នាទៅនឹងទំនិញ ឬសេវានៃម៉ាកល្បីនោះ និងតែសម្រាប់ភាពល្បីល្បាញ ដែលត្រូវបានវាស់ស្ទង់ត្រឹមវិសាលភាពដែនដីនៃរដ្ឋមួយតែប៉ុណ្ណោះ។[43]

---

[41] សៀវភៅ នីតិកម្មសិទ្ធិបញ្ញា លោកកាន់ សុទ្ធប៉ូលីន, បោះពុម្ពលើកទី២, ឆ្នាំ២០១៤ ទំព័រ ១១៨

[42] អនុសាសន៍រួមទាក់ទងនឹងបទប្បញ្ញាត្តិស្តីពីកិច្ចការពារម៉ាកល្បី ខែកញ្ញា ឆ្នាំ១៩៩៩

[43] សៀវភៅ នីតិកម្មសិទ្ធិបញ្ញា លោកកាន់ សុទ្ធប៉ូលីន, បោះពុម្ពលើកទី២, ឆ្នាំ២០១៤ ទំព័រ ១១៩

**ឃ.២ ម៉ាកល្បីដែរបានចុះបញ្ជី**

ដូចរៀបរាប់បង្ហាញនៅខាងលើហើយថាម៉ាកល្បី គឺជាម៉ាកដែលអាចទទួលបានប្រយោជន៍ពីការការពារនៃច្បាប់កម្ពុជា ដោយពុំបាច់ចុះបញ្ជីនោះឡើយ។ តែប្រសិនបើម៉ាកប្រភេទនេះត្រូវបានចុះបញ្ជី នោះអត្ថប្រយោជន៍ដែលទទួលបានពីការចុះបញ្ជីក៏មានច្រើនទៅតាមនោះផងដែរ បើប្រៀបធៀបទៅនឹងម៉ាកល្បីដែលមិនបានចុះបញ្ជី។ ដើម្បីចែងបន្ថែមពីលើអត្ថប្រយោជន៍ដែលផ្ដល់ចំពោះម៉ាកល្បីដែលមិនបានចុះបញ្ជី មាត្រ៤ ចំណុច ច បានចែងដោយមិនខ្វល់ពីគោលការណ៍ឯកទេសកម្មគឺ ម៉ាកដែលដូចគ្នា ឬប្រហាក់ប្រហែល ដែលនាំឲ្យច្រឡំគ្នានឹងម៉ាក ឬពាណិជ្ជនាមមួយដែលល្បី ឬបង្កើតពីការបកប្រែនៃម៉ាក ឬពាណិជ្ជនាមដែលល្បីនោះ ហើយដែលបានចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា សម្រាប់ទំនិញ ឬសេវាដែលមិនដូចគ្នា ឬមិនប្រហាក់ប្រហែលគ្នា ដោយការប្រើប្រាស់ម៉ាកនោះធ្វើឲ្យខូចប្រយោជន៍របស់ម្ចាស់នៃម៉ាកល្បី។ ដូចនេះការផ្ដល់ផលប្រយោជន៍ពិសេសដល់ម៉ាកល្បីដែលបានចុះបញ្ជី គឺមិនចំណុះនឹងគោលការណ៍ឯកទេសសកម្មនោះឡើយ។

**២.២.២ ម៉ាកដែលច្បាប់ហាមឃាត់ពិសេស**

ការហាមឃាត់ពិសេសដោយច្បាប់នេះ អាចធ្វើឡើងចំពោះសញ្ញាសម្គាល់ដែលជាម៉ាកណាមួយ ដោយឈរលើភាពផ្ទុយពីសណ្ដាប់ធ្នាប់សាធារណៈ សីលធម៌ និងប្រពៃណីល្អរបស់កម្ពុជាផងក៏បាន ឬដោយហេតុថាម៉ាកនោះ ដូចគ្នា ឬប្រហាក់ប្រហែលទៅនឹងសញ្ញាសម្គាល់របស់ជាតិ ឬអង្គការអន្តរជាតិនានាផងទៀតក៏បាន។[44]

**ក. ម៉ាកដែលផ្ទុយនឹងសណ្ដាប់ធ្នាប់សាធារណៈ សីលធម៌ ឬប្រពៃណីល្អរបស់ជាតិ**

នៅត្រង់ចំណុចនេះ មាត្រា៤ ចំណុច ខ បានចែងថា ម៉ាកដែលបណ្ដាលឱ្យប៉ះពាល់ដល់សណ្ដាប់ធ្នាប់សាធារណៈ សីលធម៌ ឬប្រពៃណីល្អរបស់ជាតិ គឺជាម៉ាកដែលមិនអាចចុះបញ្ជីបាន។ ប៉ុន្តែនៅចំណុចនេះយើងពិតជាលំបាកក្នុងការកំណត់ថា តើម៉ាកបែបណាមួយដែលអាចបណ្ដាលឱ្យពាល់ដល់សណ្ដាប់ធ្នាប់សាធារណៈ សីលធម៌ ឬប្រពៃណីល្អរបស់ជាតិណាស់ ព្រោះដោយហេតុថាអំពើទាំងនោះត្រឹមតែអាចបកស្រាយបានតាមរយៈបរិបទនៃវិធាន និងស្ថានភាពជាក់ស្ដែងក្នុងសង្គមប៉ុណ្ណោះ។

- សណ្ដាប់ធាប់សាធារណៈ៖ ជាម៉ាកទាំងឡាយណាដែលប៉ះពាល់ដល់សន្តិសុខ សុវត្ថិភាព ភាពត្រឹមត្រូវ ភាពល្អស្អាត ឬអនាម័យ និងបង្កឱ្យមានភាពអនាធិបតេយ្យនានានៅក្នុងសង្គមជាតិ។

ឧទាហរណ៍៖ ម៉ាកជនពាល។

[44] សៀវភៅ នីតិកម្មសិទ្ធិបញ្ញា លោកកាន់ សុទ្ធប៉ូលីន, បោះពុម្ពលើកទី២, ឆ្នាំ២០១៤ ទំព័រ ១០៧

- សីលធម៌៖ ជាម៉ាកទាំងឡាយណាដែលមានការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់សង្គម ដែលមានពាក្យអសុរោះ រូបអះអាភាស ដែលធ្វើឱ្យសីលធម៌សង្គមធ្លាក់ចុះ។

ឧទាហរណ៍៖ ម៉ាកប្រុសស្រោត។

- ប្រពៃណី៖ ជាម៉ាកទាំងឡាយណាដែលប៉ះពាល់ទៅដល់ជំនឿ សាសនា ភេទ ដែលបង្ហាញតាមរយៈរូបភាព ពាក្យ និងអត្ថន័យ ដែលបង្កប់ន័យមិនល្អ។

ឧទាហរណ៍៖ ម៉ាកប្រុសប្រពន្ធពីរ។

**ខ. ម៉ាកដែលប៉ះពាល់ដល់សញ្ញា នៃស្ថាប័នជាតិ និងអន្តរជាតិ**

ម៉ាកណាដែលយករូបសញ្ញា និមិត្តសញ្ញា ឬឈ្មោះរបស់ស្ថាប័នជាតិ និងអន្តរជាតិមកធ្វើជាម៉ាក ដើម្បីសម្គាល់ទំនិញ ឬសេវារបស់ខ្លួន នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ឬមន្ត្រីកាន់កាប់បញ្ជីមិនទទួលឱ្យចុះបញ្ជីនោះទេ ព្រោះវាអាចធ្វើឱ្យប៉ះពាល់ដល់ស្ថាប័នទាំងនោះ។ ប៉ុន្តែការហាមឃាត់នេះ អាចនឹងត្រូវបានលើកចោលវិញ កាលបើអាជ្ញាធរជារដ្ឋ ឬជាអង្គការអន្តរជាតិដែលជាម្ចាស់សិទ្ធិលើឈ្មោះ ឬសញ្ញាសម្គាល់នោះ សម្រេចអនុញ្ញាតអាចឱ្យប្រើប្រាស់ឈ្មោះ ឬសញ្ញារបស់ខ្លួន ដើម្បីធ្វើជាម៉ាកបាននោះ។[45] ការសុំការអនុញ្ញាតពីអាជ្ញាធរម្ចាស់ឈ្មោះ ឬសញ្ញាសម្គាល់នេះ ត្រូវតែធ្វើឡើងនៅមុនពេលចុះបញ្ជី ឬត្រូវបង្ហាញការអនុញ្ញាតរបស់រដ្ឋ ឬអង្គការអន្តរជាតិនោះ ទៅមន្ត្រីចុះបញ្ជីម៉ាក ទើបមន្ត្រីនោះទទួលព្រមចុះបញ្ជីជូនបាន។[46]

[45] អនុសញ្ញាទីក្រុងប៉ារីសស្តីពីកិច្ចការពារកម្មសិទ្ធិឧស្សាហកម្ម ២០ មីនា ១៨៨៣

[46] សៀវភៅ នីតិកម្មសិទ្ធិបញ្ញា លោកកាន់ សុទ្ធប៉ូលីន, បោះពុម្ពលើកទី២, ឆ្នាំ២០១៤ ទំព័រ ១១០

## ជំពូកទី២ ការចុះបញ្ជីម៉ាក

គ្រប់ការចុះបញ្ជីម៉ាកជាតិទាំងអស់ត្រូវតែអនុវត្តតាមបញ្ញាត្តិច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើប្រកួតប្រជែងមិនស្មោះត្រង់[47] និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និង អំពើប្រកួតប្រជែងមិនស្មោះត្រង់[48] និងលិខិតបទដ្ឋាននានាដែលពាក់ព័ន្ធទៅនឹងការចុះបញ្ជីនៃព្រះរាជាណាចក្រកម្ពុជា។ ក្នុងការស្នើសុំចុះបញ្ជីយោងតាមច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើប្រកួតប្រជែងមិនស្មោះត្រង់ មាត្រា៥៨ និងមាត្រា៥៩ និងអនុក្រឹត្យស្តីពី ការអនុវត្តច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើប្រកួតប្រជែងមិនស្មោះត្រង់ មាត្រា៧ និងមាត្រា១៦ រាល់សំណុំឯកសារដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក។[49] ហើយការចុះបញ្ជីម៉ាកនៅព្រះរាជាណាចក្រកម្ពុជាមានរយៈពេល០៦ ទៅ០៩ខែ ឬលើសពីរយៈពេលនេះ ក្នុងករណីមានភាគីទីបីទំនាស់ ឬការទទួលពាក្យមានការកើនឡើងច្រើន ឬការកែតម្រូវពាក្យស្នើសុំរបស់អ្នកដាក់ពាក្យ បើប្រៀបធៀបទៅនឹងការចុះបញ្ជីម៉ាកនៅបណ្តាលប្រទេសអាស៊ាន មានរយៈពេលចាប់ពី ៦ខែ ទៅ ១២ខែ ចំណែកឯនៅសហរដ្ឋអាមេរិក មានរយៈពេល ១២ខែ ទៅ១៨ខែ។[50] ហើយចំពោះការចុះបញ្ជីគឺត្រូវបានបែងចែកជាពីរផ្នែក ធំៗគឺ នីតិវិធីនៃការដាក់ពាក្យស្នើសុំចុះបញ្ជី នៅក្នុងផ្នែកទី១ និង ការត្រួតពិនិត្យនិងការសម្រេចលើពាក្យស្នើសុំក្នុងផ្នែកទី២។

### ផ្នែកទី១៖ នីតិវិធីនៃការដាក់ពាក្យស្នើសុំចុះបញ្ជី

ការស្នើសុំចុះបញ្ជីម៉ាក ការសុំប្តូរអាស័យដ្ឋាននៃម្ចាស់ម៉ាក និងការបញ្ជាក់ឡើងវិញនូវការប្រើប្រាស់ ឬមិនប្រើប្រាស់ ត្រូវធ្វើឡើងនៅក្រសួងពាណិជ្ជកម្ម។ ហើយនិងត្រូវបង់កម្រៃផ្សេងៗតាមការកំណត់នៅក្នុងសេចក្តីប្រកាសរួមរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម។ ហើយសិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក ត្រូវបានទទួលស្គាល់តាមរយៈការចុះបញ្ជីម៉ាក ដោយអនុលោមតាមបទប្បញ្ញនៃច្បាប់នេះ[51] មានន័យថា ម្ចាស់ម៉ាក ត្រូវបំពេញតាមលក្ខខណ្ឌក្នុងការស្នើសុំចុះបញ្ជីម៉ាក ដែលបានកំណត់ដោយក្រសួងពាណិជ្ជកម្ម។ ជាមួយគ្នាផងដែរ នីតិវិធីក្នុងការចុះបញ្ជីម៉ាក ត្រូវតែអនុលោមតាមច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ក៏ដូចជាអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់។

[47] ច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាមនិងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, ៧ កុម្ភៈ ឆ្នាំ២០០២

[48] អនុក្រឹត្យស្តីពី ការអនុវត្តច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើប្រកួតប្រជែងមិនស្មោះត្រង់ ឆ្នាំ២០០៦

[49] សេចក្តីជូនដំណឹង របស់ក្រសួងពាណិជ្ជកម្ម ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៥

[50] គេហទំព័រ http://www.service.gov.kh/service/101434

[51] ច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាមនិងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, ៧ កុម្ភៈ ឆ្នាំ២០០២, មាត្រា៣

### ១.១ ការដាក់ពាក្យស្នើសុំ

ការដាក់ពាក្យចុះបញ្ជីម៉ាក ត្រូវអនុលោមតាមត្រា៩ នៃច្បាប់ស្តីពី ពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់។ ម៉ាកដែលមិនបានរួមបញ្ចូលក្នុងមាត្រា៩ នៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ សុទ្ធតែជាម៉ាកដែលអាចចុះបញ្ជីបាន ពីព្រោះមាត្រា៩ នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើប្រកួតប្រជែងមិនស្មោះត្រង់បានចែងយ៉ាងច្បាស់អំពីប្រភេទម៉ាកដែលមិនអនុញ្ញាតឲ្យចុះបញ្ជី។[52] ទោះជាយ៉ាងណាក៏ច្បាប់ មិនបានតម្រូវថាម្ចាស់នៃម៉ាកត្រូវតែមកធ្វើការចុះបញ្ជីនោះទេ ប៉ុន្តែការអាក់ខានមិនបានចុះបញ្ជីនោះនឹង ធ្វើឲ្យម្ចាស់ម៉ាកមានការខូចប្រយោជន៍នៅពេល ដែលមានការរំលោភបំពានមកលើម៉ាករបស់ខ្លួន ព្រោះម្ចាស់ម៉ាកគ្មានសិទ្ធិទាមទារឲ្យច្បាប់ការពារ ឬសិទ្ធិនៅក្នុងការទទួលបានកិច្ចការពារប្រឆាំងទៅនឹង ជនដែលប្រព្រឹត្តបំពានលើម៉ាកនោះទេ។ ហើយចំពោះដំណាក់កាលនេះវាគឺជាដំណាក់កាលដំបូងបំផុតនៃការចុះបញ្ជីម៉ាក ដែលអ្នកដាក់ពាក្យសុំត្រូវចុះទៅកាន់ការិយាល័យរដ្ឋបាលដែលទទួលចុះបញ្ជីម៉ាក នៅនាយកដ្ឋានកម្មសិទ្ធបញ្ញា នៃក្រសួងពាណិជ្ជកម្មដើម្បីទទួលបានគំរូពាក្យសុំដើម្បីស្នើសុំចុះបញ្ជីម៉ាក។[53]

#### ១.១.១ ការដាក់ពាក្យស្នើសុំផ្ទាល់

បុគ្គលគ្រប់រូបគឺអាចមានសិទ្ធិក្នុងការដាក់ពាក្យស្នើសុំ ចុះបញ្ជីម៉ាករួមទាំង រូបវន្តបុគ្គល នីតិបុគ្គល និងភ្នាក់ងារតំណាង។ ប៉ុន្តែអ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក លើកលែងតែជនបរទេស ឬអ្នកស្នើសុំ ដែលមានទីលំនៅអចិន្ត្រៃយ៍ ឬទីតាំងប្រកបអាជីវកម្មសំខាន់ស្ថិតនៅក្រៅព្រះរាជាណាចក្រកម្ពុជា ត្រូវតែមានតំណាងភ្នាក់ងារម៉ាក ដែលមានទីលំនៅ និងកំពុងប្រកបអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។[54]

#### ក. អ្នកស្នើសុំជារូបវន្តបុគ្គល

រូបវន្តបុគ្គល គឺសំដៅទៅលើបុគ្គល ដែលមានសមត្ថភាពតាមផ្លូវច្បាប់ដែលអាចក្លាយជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ច។ រូបវន្តបុគ្គលដែលដាក់ពាក្យមក ត្រូវបញ្ជាក់នាមត្រកូល និងនាមខ្លួនរបស់បុគ្គលនោះ និងមានអាសយដ្ឋានរបស់អ្នកដាក់ពាក្យស្នើសុំ ត្រូវតែបញ្ជាក់ឲ្យបានច្បាស់លាស់ដើម្បីបំពេញតម្រូវការជាធម្មតារបស់មន្ត្រីដល់ការបញ្ជូនតាមប្រៃសណីយ៍។ ក្នុងករណីណាក៏ដោយ អាសយដ្ឋាន ត្រូវមានការបញ្ជាក់ផងដែរ នូវលេខផ្ទះ ទូរស័ព្ទ និងទូរសារ។[55]

---

[52] ច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាមនិងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, ៧ កុម្ភៈ ឆ្នាំ២០០២, មាត្រា៩

[53] របាយការណ៍ស្រាវជ្រាវបញ្ចប់ការសិក្សា ការចុះបញ្ជីកម្មសិទ្ធិបញ្ញានៅកម្ពុជា ដោយ លោក លាម លិះ ឆ្នាំ២០១៩

[54] ច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាមនិងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, ៧ កុម្ភៈ ឆ្នាំ២០០២, មាត្រា៥៨

[55] អនុក្រឹត្យស្តីពី ការអនុវត្តច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើប្រកួតប្រជែងមិនស្មោះត្រង់ ឆ្នាំ២០០៦, មាត្រា៥ (១)

**ខ. អ្នកស្នើសុំជានីតិបុគ្គល**

ដែលហៅថានីតិបុគ្គល គឺជាក្រុមមនុស្ស មូលនិធិ អង្គភាព អង្គការ ក្រុមហ៊ុន ដែលមានបុគ្គលភាពគតិយុត្តិ។ សម្រាប់នីតិបុគ្គលដែលដាក់ពាក្យស្នើសុំចុះបញ្ជី ត្រូវបញ្ជាក់ដោយឈ្មោះពេញលេញ ជាផ្លូវការរបស់នីតិបុគ្គលនោះ និងអាសយដ្ឋាន ត្រូវមានការបញ្ជាក់ផងដែរនៅ ទូរស័ព្ទ និង ទូរសារ។[56]

ឯកសារដែលដាក់មកត្រូវចុះហត្ថលេខា ក្នុងនាមជាក្រុមហ៊ុនសហកម្មសិទ្ធិមួយ ត្រូវមានឈ្មោះរបស់ម្ចាស់ភាគហ៊ុនទាំងអស់ ជាឈ្មោះពេញលេញ និងត្រូវចុះហត្ថលេខា ដោយម្ចាស់ភាគហ៊ុនទាំងអស់ ឬដោយម្ចាស់ភាគហ៊ុនណាមួយ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដើម្បីចុះហត្ថលេខា ដោយមានបញ្ជាក់ថាម្ចាស់ភាគហ៊ុននោះចុះហត្ថលេខា ក្នុងនាមក្រុមហ៊ុនសហកម្មសិទ្ធិមួយ ឬដោយតតិយជនណាម្នាក់ដែលមន្ត្រី កាន់កាប់បញ្ជីទទួលស្គាល់ថា ជននោះត្រូវបានអនុញ្ញាតឲ្យចុះហត្ថលេខាលើឯកសារនោះ។[57]

**គ. ភ្នាក់ងារតំណាង**

ចាប់តាំងពីឆ្នាំ១៩៩៧ រហូតមកដល់ឆ្នាំ២០០២ យើងពុំឃើញមានបទដ្ឋានគតិយុត្តណាមួយកំណត់អំពីភ្នាក់ងារតំណាងម្ចាស់ម៉ាកក្នុងការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកទេ។ នៅឆ្នាំ២០០២ ច្បាប់ម៉ាកត្រូវបានអនុម័តដែលជំពូក ទី១៣ នៃច្បាប់នេះ អនុញ្ញាតឲ្យមានភ្នាក់ងារតំណាងស្របច្បាប់ក្នុងការចុះបញ្ជីម៉ាកនៅកម្ពុជា ប្រសិនបើម្ចាស់ម៉ាកពុំមានទីលំនៅ ឬពុំប្រកបអាជីវកម្មនៅកម្ពុជាទេ។[58] ប្រាំបួនឆ្នាំបន្ទាប់ពីការអនុម័តច្បាប់ម៉ាកនៅឆ្នាំ២០០២ (រហូតដល់ខែមករា ឆ្នាំ២០១១) យើងពុំឃើញមានប្រកាសស្តីពីការតែងតាំងភ្នាក់ងារតំណាងម្ចាស់ម៉ាក ក្នុងការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក ចេញពីក្រសួងពាណិជ្ជកម្មឡើយ។ បញ្ហាចោទថា តើម្ចាស់ម៉ាកនៅឯបរទេស អាចដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកនៅកម្ពុជាដោយរបៀបណា? ឬតើនរណាអាចជាភ្នាក់ងារតំណាងម្ចាស់ម៉ាកនៅបរទេសក្នុងការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកនៅកម្ពុជា?

អវត្តមាននៃប្រកាសរបស់ក្រសួងពាណិជ្ជកម្ម ស្តីពីភ្នាក់ងារតំណាងក្នុងការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកនៅកម្ពុជា ពុំមែនជាឧបសគ្គចំពោះម្ចាស់ម៉ាកនៅឯបរទេស ក្នុងការចុះបញ្ជីម៉ាកនៅកម្ពុជាទេ។ យោងតាមមាត្រា៤ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥

[56] អនុក្រឹត្យស្តីពី ការអនុវត្តច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើប្រកួតប្រជែងមិនស្មោះត្រង់ ឆ្នាំ២០០៦, មាត្រា៥ (១)
[57] អនុក្រឹត្យស្តីពី ការអនុវត្តច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើប្រកួតប្រជែងមិនស្មោះត្រង់ ឆ្នាំ២០០៦, មាត្រា៦(១)
[58] មាត្រា ៥៨ នៃច្បាប់ស្តីពីម៉ាក ៖ "ក្នុងករណីដែលលំនៅដ្ឋានអចិន្ត្រៃយ៍ ឬទីតាំងប្រកបអាជីវកម្មសំខាន់របស់អ្នកស្នើសុំស្ថិតនៅក្រៅព្រះរាជាណាចក្រកម្ពុជា អញ្ញអ្នកស្នើសុំនោះត្រូវមានតំណាងជាភ្នាក់ងារដែលមានទីលំនៅ និងកំពុងប្រកបវិជ្ជាជីវៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជា"។

បានចែងថា ៖ ក្រៅពីមេធាវី ដែលជាសមាជិកនៃគណៈមេធាវី គ្មានជនណាម្នាក់អាចប្រកបមុខរបរយកកម្រៃក្នុងការពិគ្រោះច្បាប់ ឬតាក់តែងលិខិតស្នាមគតិយុត្តបានឡើយ ដោយយោងតាមមាត្រានេះ គឺរាល់សកម្មភាពក្នុងការផ្តល់សេវាកម្មច្បាប់ រួមបញ្ចូលទាំងប្រឹក្សាយោបល់ផ្នែកច្បាប់ ការចុះហត្ថលេខាលើលិខិតស្នាមគតិយុត្តផ្សេងៗ ឬសេវាពាក់ព័ន្ធផ្នែកច្បាប់ក្នុងគោលដៅយកកម្រៃ ជាសិទ្ធិ និងសមត្ថកិច្ចរបស់មេធាវីតែមួយគត់។ ក្នុងករណីចុះបញ្ជីម៉ាក ការបំពេញពាក្យស្នើសុំចុះបញ្ជីម៉ាក ឬការចុះហត្ថលេខាលើពាក្យស្នើសុំចុះបញ្ជីម៉ាក និងសេវាពិគ្រោះយោបល់ផ្សេងៗ ពាក់ព័ន្ធនឹងការចុះបញ្ជីម៉ាក ជាប្រភេទនៃសេវាកម្មច្បាប់ដែលអនុញ្ញាតឲ្យមេធាវីមានសិទ្ធិធ្វើកិច្ចការដែលបានរៀបរាប់ខាងលើ ក្នុងគោលដៅយកប្រាក់កម្រៃស្របតាមមាត្រា៩ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។

នៅខែកុម្ភៈ ឆ្នាំ២០១១ ប្រកាសស្តីពី "ភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាកក្នុងព្រះរាជាណាចក្រកម្ពុជា" ត្រូវបានអនុម័តដោយក្រសួងពាណិជ្ជកម្ម។[59] ប្រកាសនេះមានគោលបំណងកំណត់នូវលក្ខណៈសម្បត្តិ និងនីតិវិធីទទួលស្គាល់បុគ្គលធ្វើជាអ្នកតំណាងស្របច្បាប់នៃម្ចាស់ម៉ាកនៅកម្ពុជា ដោយអនុលោមតាមមាត្រា៥៨ និងមាត្រា៥៩ នៃច្បាប់ស្តីពីម៉ាក និងបទប្បញ្ញាត្តិនៃម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ។[60]

ការចាត់តាំងអ្នកតំណាងមួយ ត្រូវធ្វើឡើងដោយមានលិខិតប្រគល់សិទ្ធិដែល ត្រូវបញ្ជាក់ភាពស្របច្បាប់ និងចុះហត្ថលេខា ដោយអ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក ឬប្រសិនបើអ្នកដាក់ពាក្យសុំចុះបញ្ជីម៉ាកច្រើននាក់ ការចុះហត្ថលេខាត្រូវធ្វើឡើងដោយអ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកទាំងនោះ។ អាសយដ្ឋានរបស់ភ្នាក់ងារតំណាង ត្រូវបានចាត់ទុកថាជាអាសយដ្ឋានប្រើប្រាស់សម្រាប់ទាក់ទងរវាងបុគ្គលម្នាក់ ឬច្រើននាក់ដែលត្រូវបានចាត់តាំងជាភ្នាក់ងារតំណាង ហើយព័ត៌មានផ្សេងៗ ត្រូវធ្វើតាមរយៈភ្នាក់ងារតំណាងនោះ។ ភ្នាក់ងារតំណាងវិញ គឺត្រូវមានលិខិតប្រគល់សិទ្ធិដែលចាត់តាំងភ្នាក់ងារតំណាងមួយឲ្យធ្វើការដាក់ពាក្យ អាចភ្ជាប់មកជាមួយនឹងពាក្យស្នើសុំចុះបញ្ជី ឬត្រូវប្រគល់លិខិតប្រគល់សិទ្ធិនោះទៅឲ្យមន្ត្រីកាន់កាប់បញ្ជី ក្នុងរយៈពេល ០២(ពីរ) ខែ គិតចាប់ពីកាលបរិច្ឆេទនៃការដាក់ពាក្យ។ ប្រសិនបើការប្រគល់សិទ្ធិនេះមិនត្រូវធ្វើឡើង និងធ្វើឡើងមិនសមស្របតាមមាត្រា៥៨ និងមាត្រា៥៩ នៃច្បាប់ និងមាត្រា២៨ នៃអនុក្រឹត្យ ទេនោះ ចំណាត់ការតាមនីតិវិធីណាមួយ ក្នុងការចុះបញ្ជីនឹងមិនត្រូវធ្វើឡើងឡើយ។[61]

---

[59] ប្រកាសលេខ០៩៥ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១១ ស្តីពី "ភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាកក្នុងព្រះរាជាណាចក្រកម្ពុជា" ។

[60] ប្រកាសលេខ១០៥ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៩ ស្តីពី "អំពីនីតិវិធីណែនាំការចុះបញ្ជី និងការការពារម៉ាកសម្រាប់ភូមិសាស្ត្រទំនិញ"។

[61] អនុក្រឹត្យស្តីពី ការអនុវត្តច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើប្រកួតប្រជែងមិនស្មោះត្រង់ ឆ្នាំ២០០៦, មាត្រា៧

### ១.១.២ ការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកតាមរយៈប្រព័ន្ធអេឡិចត្រូនិច

ការចុះបញ្ជីម៉ាក គឺអាចធ្វើទៅបាននៅតាមប្រព័ន្ធអេឡិចត្រូនិចផងដែល ដោយការធ្វើបែបនេះគឺក្នុងគោលដៅមួយដើម្បី ពង្រឹងនិងបង្កើនប្រសិទ្ធិភាពនៃការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកនិងសេវាផ្សេងៗពាក់ពន្ធនឹងម៉ាក ដើម្បីឲ្យការផ្តល់សេវាកាន់តែល្អប្រសើរ ហើយវាក៏បានសម្រួលដល់ការគ្រប់គ្រងទិន្នន័យ ការផ្តល់លិខិត និងឯកសារដែលពាក់ពន្ធផ្សេងៗ ព្រមទាំងគ្រប់គ្រងលើការប្រមូលកម្រៃសេវាផ្សេងៗ ដែលពាក់ព័ន្ធទៅនឹងកិច្ចការពារម៉ាកឲ្យបានកាន់តែមានប្រសិទ្ធភាពបន្ថែមទៀត។

#### ក. អ្នកដាក់ពាក្យស្នើសុំ

អ្នកដាក់ពាក្យសុំដែលមានលំនៅដ្ឋានអចិន្ត្រៃយ៍ ឬទីតាំងប្រកបអាជីវកម្ម ស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា អាចធ្វើឡើងតាមប្រព័ន្ធអេឡិចត្រូនិកបាន។ ការស្នើសុំតាមប្រព័ន្ធអេឡិចត្រូនិកត្រូវធ្វើឡើងដោយភ្នាក់ងារតំណាងស្របច្បាប់ដែលមានទីលំនៅ និងកំពុងប្រកបវិជ្ជាជីវៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា។[62]

អ្នកដាក់ពាក្យស្នើសុំ ឬភ្នាក់ងារតំណាងដែលដាក់ពាក្យស្នើសុំតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវភ្ជាប់មកជាមួយឯកសារតម្រូវ ដូចមានចែងក្នុងច្បាប់ និងបទប្បញ្ញាត្តិពាក់ព័ន្ធជាទម្រង់អេឡិចត្រូនិកដោយត្រូវប្រាកដថាជាឯកសារពិត និងឥតក្លែងបន្លំ។

ចំពោះជនណាដែលផ្តល់ពត៌មានមិនពិត ក្នុងការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក និងសេវាផ្សេងៗពាក់ព័ន្ធនឹងម៉ាកតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវផ្តន្ទាទោសតាមមាត្រា ៦៣ នៃច្បាប់ស្តីពីម៉ាកពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ និងច្បាប់ពាក់ព័ន្ធជាធរមាន។

#### ខ. ការដាក់ពាក្យស្នើសុំ

ការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក និងសេវាផ្សេងៗពាក់ព័ន្ធនឹងម៉ាកតាមប្រព័ន្ធអេឡិចត្រូនិកតម្រូវឲ្យមានឈ្មោះគណនី និងលេខកូដសម្ងាត់ ដែលកំណត់ដោយនាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្ម។ ហើយក្រោយការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក និងសេវាផ្សេងៗពាក់ព័ន្ធនឹងម៉ាកតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវផ្តល់ឯកសារតម្រូវជាទម្រង់ច្បាប់ដើម ឬទម្រង់ច្បាប់ចម្លងដោយមានបញ្ជាក់ពីភាពត្រឹមត្រូវ ទៅនាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្ម តាមកាលកំណត់ដូចមានចែងក្នុងច្បាប់ និងបទប្បញ្ញាត្តិពាក់ព័ន្ធ។[63]

[62] ប្រកាសលេខ១២៥ ព.ណ កសប ស្តីពី នីតិវិធីនៃការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកតាមប្រព័ន្ធអេឡិចត្រូនិក, ៤ ឧសភា ២០១៧

[63] ប្រកាសលេខ១២៥ ព.ណ កសប ស្តីពី នីតិវិធីនៃការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកតាមប្រព័ន្ធអេឡិចត្រូនិក, ៤ ឧសភា ២០១៧

#### ១.១.៣ ការដកពាក្យស្នើសុំ

អ្នកដែលបានដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក អាចដកពាក្យស្នើសុំរបស់ខ្លួនមកវិញបាន។ ការដកពាក្យស្នើសុំចុះបញ្ជីម៉ាក ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ដែលត្រូវចុះហត្ថលេខាដោយអ្នកដាក់ពាក្យស្នើសុំ ឬភ្នាក់ងារតំណាងស្របច្បាប់ ហើយត្រូវដាក់ជូនទៅមន្ត្រីកាន់កាប់បញ្ជី។[64] ប៉ុន្តែទោះបីមានការដកពាក្យស្នើសុំវិញក៏ដោយ ក៏កម្រៃនៃការដាក់ពាក្យស្នើសុំចុះបញ្ជីមិនត្រូវប្រគល់ជូនវិញនោះដែល។

### ១.២ សំណុំឯកសារចាំបាច់ក្នុងការដាក់ពាក្យស្នើសុំ

អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកទាំងឡាយ ត្រូវបំពេញនូវពាក្យស្នើសុំចុះបញ្ជីមួយច្បាប់ ផ្តល់ជូនមន្ត្រីកាន់កាប់បញ្ជីនូវគំរូម៉ាកដែលស្នើសុំចុះបញ្ជី និងបញ្ជាក់នូវយថាប្រភេទទំនិញ ឬសេវាដែលត្រូវបិទម៉ាកនោះ នៅក្រោមទម្រង់ជាបញ្ជីមួយផងទៀត។ អ្នកដាក់ពាក្យស្នើសុំ ក៏ត្រូវតែបញ្ជាក់ជាមុនផងដែរ អំពីការប្រើប្រាស់ ឬការមិនប្រើប្រាស់ ចំពោះម៉ាកដែលខ្លួនស្នើសុំចុះបញ្ជីនេះ នាពេលដាក់ពាក្យស្នើសុំនោះដែរ។[65]

#### ១.២.១ ពាក្យសុំ

ការផ្តល់គំរូពាក្យសុំចុះបញ្ជីម៉ាកមួយ ត្រូវធ្វើឡើងតាមរយៈគំរូពាក្យស្នើសុំ ដូចមានចែងក្នុងប្រកាសរបស់ក្រសួងពាណិជ្ជកម្ម ហើយត្រូវចុះហត្ថលេខាដោយអ្នកស្នើសុំ ឬភ្នាក់ងារតំណាងស្របច្បាប់។ ពាក្យស្នើសុំមួយ អាចធ្វើឡើងសម្រាប់ការស្នើសុំចុះបញ្ជីម៉ាកមួយ ចំពោះទំនិញ ឬសេវាក្នុងចំណាត់ថ្នាក់មួយ ឬច្រើននៃចំណាត់ថ្នាក់អន្តរជាតិ។ ការប្រើប្រាស់ម៉ាកពុំមែនជាលក្ខខណ្ឌដែលតម្រូវ នៅពេលដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកឡើយ។[66]

##### ក. គំរូពាក្យស្នើសុំ

ជាទូទៅអ្នកដាក់ពាក្យស្នើសុំចុះបញ្ជី នឹងទទួលបានគំរូនៃពាក្យស្នើសុំមួយច្បាប់ ដោយឥតគិតថ្លៃ ពីមន្ត្រីកាន់កាប់បញ្ជី នៃអាជ្ញាធរទទួលបន្ទុកចុះបញ្ជីម៉ាក (មាត្រា៣នៃអនុក្រឹត្យ)។ ក្រោយពីទទួលបានពាក្យស្នើសុំនេះហើយ អ្នកស្នើសុំត្រូវបំពេញពាក្យស្នើសុំនេះ រួចចុះហត្ថលេខាបញ្ជាក់ មុននឹងដាក់ត្រឡប់ទៅកាន់មន្ត្រីកាន់កាប់បញ្ជីវិញ។ បន្ទាប់មកនៅពេលដែលអ្នកបំពេញពាក្យស្នើសុំចុះបញ្ជីម៉ាកដូចដែលមាននៅក្នុងគំរូនៃពាក្យស្នើសុំ ហើយពាក្យដែលបានបំពេញនោះត្រូវតែបំពេញ និងភ្ជាប់មកជាមួយនូវ[67]៖

[64] អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើប្រកួតប្រជែងមិនស្មោះត្រង់ ឆ្នាំ២០០៦ មាត្រា ១៥
[65] សៀវភៅ នីតិកម្មសិទ្ធិបញ្ញា លោកកាន់ សុទ្ធប៉ូលីន, បោះពុម្ពលើកទី២, ឆ្នាំ២០១៤, ទំព័រ១០៨
[66] អនុក្រឹត្យ ស្តីពីការអនុវត្តច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើប្រកួតប្រជែងមិនស្មោះត្រង់, ឆ្នាំ២០០៦ មាត្រា១០
[67] អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើប្រកួតប្រជែងមិនស្មោះត្រង់, ឆ្នាំ២០០៦

- ឈ្មោះរបស់អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក
- អាសយដ្ឋានទំនាក់ទំនង
- គំរូម៉ាកដែលស្នើសុំចុះបញ្ជី
- យថាប្រភេទរបស់ទំនិញ ឬសេវាដែលស្នើសុំចុះបញ្ជីក្នុងចំណាត់ថ្នាក់នីមួយៗ
- កម្រៃនៃការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក ដែលតម្រូវសម្រាប់ ចំណាត់ថ្នាក់នីមួយៗនៃទំនិញ ឬសេវា ដែលស្នើសុំចុះបញ្ជីម៉ាក។

**ខ. ភាសាប្រើប្រាស់ក្នុងឯកសារដាក់ពាក្យស្នើសុំ**

ភាសាប្រើប្រាស់ក្នុងការដាក់ពាក្យសុំ ត្រូវតែធ្វើតាមតម្រូវនៃច្បាប់ ឬអនុក្រឹត្យ ពាក្យស្នើសុំត្រូវធ្វើជាភាសាខ្មែរ ឬជាភាសាអង់គ្លេស។ ឯកសារណាមួយ ដែលប្រើប្រាស់អមភ្ជាប់ជាមួយពាក្យស្នើសុំ ដែលបង្កើតជាផ្នែកមួយ នៃពាក្យស្នើសុំនោះ ឬឯកសារដែលបានដាក់ជូនទៅមន្ត្រីកាន់កាប់បញ្ជី ដែលប្រើប្រាស់ភាសាមួយ ក្រៅពីភាសាខ្មែរ ឬភាសាអង់គ្លេស ត្រូវភ្ជាប់មកជាមួយ នូវការបកប្រែជាភាសាខ្មែរ ឬភាសាអង់គ្លេស។[68]

**១.២.២ ឯកសារចាំបាច់ផ្សេងទៀត**

ក្រៅពីបណ្ដាឯកសារចាំបាច់ដូចបានរៀបរាប់នៅខាងលើនេះ អ្នកដាក់ពាក្យសុំទាំងអស់ក៏ត្រូវ ភ្ជាប់ទៅជាមួយនូវឯកសារដែលចាំបាច់មួយចំនួនផ្សេងទៀតផងដែរ ដែលក្នុងនោះដែលមានដូចជា គំរូម៉ាក សម្លេងអាននិងការបកប្រែអត្ថន័យរបស់ម៉ាក និងបញ្ជីទំនិញ ឬសេវានៃម៉ាកដែលស្នើសុំចុះបញ្ជី។

**ក. គំរូម៉ាក**

ពាក្យស្នើសុំចុះបញ្ជី ត្រូវភ្ជាប់មកជាមួយនូវគំរូម៉ាក ក្រោមរូបភាព គំរូម៉ាកច្បាស់ និងមិនរលប់ដែលមានទំហំមិនលើសពី ៨សង្ទីម៉ែត្រ គុណ ៨សង្ទីម៉ែត្រ។[69] អ្នកដាក់ពាក្យស្នើសុំទាំងឡាយ ត្រូវផ្ដល់ជូនមន្ត្រីកាន់កាប់បញ្ជី នូវគំរូម៉ាក ដែលខ្លួនមានប្រាថ្នាចង់ទទួលបានកិច្ចការពារ ក្រោយពេលចុះបញ្ជីរួច។ គំរូម៉ាកដែលត្រូវផ្ដល់នេះគឺត្រូវតែគោរពនូវលក្ខខណ្ឌនៃទំហំ សណ្ឋាន សម្លេងអាន ការបកប្រែ និងចំនួនកំណត់ ដូចដែលមានចែងក្នុងអនុក្រឹត្យ។[70] គ្រប់ករណីទាំងអស់ គំរូម៉ាកនេះ នឹងត្រូវប្រើប្រាស់ជាមធ្យោបាយភ័ស្តុតាង ដើម្បីបញ្ជាក់នូវសិទ្ធិ របស់ម្ចាស់ម៉ាកដែលបានចុះបញ្ជីរួចប្រឆាំងទល់នឹងការក្លែងបន្លំម៉ាកទាំងឡាយនាពេលដែលម៉ាកនោះត្រូវបានរំលោភបំពាន គឺត្រូវទទួលបានការពារដោយច្បាប់។

---

[68] អនុក្រឹត្យស្ដីពី ការអនុវត្តច្បាប់ស្ដីពីម៉ាក ពាណិជ្ជនាម និងអំពើប្រកួតប្រជែងមិនស្មោះត្រង់, ឆ្នាំ២០០៦ មាត្រា៤

[69] អនុក្រឹត្យស្ដី ការអនុវត្តច្បាប់ស្ដីពីម៉ាក ពាណិជ្ជនាម និងអំពើប្រកួតប្រជែងមិនស្មោះត្រង់, ២០០៦ មាត្រា១១ ចំណុច ១

[70] អនុក្រឹត្យស្ដី ការអនុវត្តច្បាប់ស្ដីពីម៉ាក ពាណិជ្ជនាម និងអំពើប្រកួតប្រជែងមិនស្មោះត្រង់, ២០០៦ មាត្រា១១

**ខ. សម្លេងអាន និងការបកប្រែអត្ថន័យរបស់ម៉ាក**

តាមការតម្រូវរបស់មន្រ្តីកាន់កាប់បញ្ជី ក្នុងករណីដែលម៉ាកមួយ មានពាក្យមួយព្យាង្គ ឬច្រើនព្យាង្គ ជាអក្សរ ក្រៅពីអក្សរខ្មែរ ឬអក្សរឡាតាំង ការបំពេញពាក្យស្នើសុំតាមគំរូ ដូចមានចែងក្នុងប្រកាសរបស់ក្រសួងពាណិជ្ជកម្ម ហើយនិងការផ្តល់នូវគំរូម៉ាកបន្ថែម ត្រូវភ្ជាប់មកជាមួយផងដែរនូវការសរសេរ សម្លេងអាន និងការបកប្រែអត្ថន័យរបស់ម៉ាកនោះ ឲ្យបានពេញលេញតាមពាក្យមួយព្យាង្គដោយបញ្ជាក់នូវភាសា ដែលពាក្យនីមួយៗនោះ ត្រូវបានគេប្រើ។[71]

**គ. បញ្ជីទំនិញ ឬសេវានៃម៉ាកដែលស្នើសុំចុះបញ្ជី**

ដើម្បីងាយស្រួលគោរពតាមគោលការណ៍ឯកទេសកម្មនៃម៉ាក អ្នកដាក់ពាក្យស្នើសុំត្រូវតែបញ្ជាក់ជូនដល់មន្រ្តីកាន់កាប់បញ្ជីជាមុន នូវប្រភេទនៃទំនិញ ឬសេវា ដែលខ្លួននឹងប្រើប្រាស់ជាមួយអានាគតម៉ាករបស់ខ្លួន។ ការបញ្ជាក់នេះ ត្រូវធ្វើឡើងក្រោមរូបភាពជាបញ្ជីរាយមុខទំនិញ ឬសេវា ដើម្បីឱ្យមន្រ្តីចុះបញ្ជី អាចកំណត់បានថាតើម៉ាកនៃទំនិញ ឬសេវា ដែលស្នើសុំចុះបញ្ជី នឹងត្រូវស្នើឱ្យការពារចំពោះទំនិញ ឬសេវាមួយណាដែរ។[72]

**១.៣ អាជ្ញាធរមានសមត្ថកិច្ចក្នុងការដាក់ពាក្យស្នើសុំ**

អាជ្ញាធរមានសមត្ថកិច្ចនៅក្នុងការត្រួតពិនិត្យ និងចុះបញ្ជីម៉ាក គឺជាមន្រ្តីកាន់កាប់បញ្ជីនៅក្នុងក្រសួងពាណិជ្ជកម្ម។ ក្រសួងពាណិជ្ជកម្ម មាននាយកដ្ឋានចំណុះមួយដែលមានឈ្មោះថា នាយកដ្ឋានកម្មសិទ្ធិបញ្ញា ដែលមានការិយាល័យចំណុះចំនួន៦ រួមទាំងការិយាល័យចុះបញ្ជីម៉ាកពាណិជ្ជកម្មដែលមានតួនាទីក្នុងការចុះបញ្ជីម៉ាក។

ប្រកាសស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញា បានចែងយ៉ាងច្បាស់អំពីការិយាល័យចុះបញ្ជីមានតួនាទីដូចជា[73]៖

- រៀបចំនីតិវិធី និងលិខិតបទដ្ឋានគតិយុត្តិទាក់ទងការងារចុះបញ្ជីម៉ាកពាណិជ្ជកម្ម
- រៀបចំសំណើនិងអនុវត្តគម្រោងទាក់ទងនឹងការងារបញ្ជីពាណិជ្ជកម្ម
- ស្រាវជ្រាវម៉ាកមុនការស្នើសុំចុះបញ្ជី
- ត្រួតពិនិត្យខ្លឹមសារលម្អិតរបស់ម៉ាក
- ស្រាវជ្រាវ និងវាយតម្លៃម៉ាក និងម៉ាកល្បី
- ទទួល និងដោះស្រាយបណ្តឹងតវ៉ា នឹងបណ្តឹងជំទាស់មុនពេលម៉ាកត្រូវបានចុះបញ្ជី
- ចុះបញ្ជីម៉ាក និងផ្តល់វិញ្ញាបនបត្រ

[71] អនុក្រឹត្យស្តី ការអនុវត្តច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើប្រកួតប្រជែងមិនស្មោះត្រង់, ២០០៦ មាត្រា១២

[72] សៀវភៅ នីតិកម្មសិទ្ធិបញ្ញា លោកកាន់ សុទ្ធប៉ូលីន, បោះពុម្ពលើកទី២, ឆ្នាំ២០១៤

[73] ប្រកាសស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញា, មាត្រា៤

- កត់ត្រាការប្តូរឈ្មោះ ប្តូរអាសយដ្ឋានម្ចាស់ម៉ាក ការរួមបញ្ចូលគ្នានៃម៉ាក និង ការផ្ទេរ គ្រប់គ្រងម៉ាក មុនពេលម៉ាកត្រូវបានចុះបញ្ជី
- រៀបចំការអនុវត្តការចុះបញ្ជីម៉ាកតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម
- បំពេញភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន។

**១.៤ កម្រៃសេវា**

អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក និងសេវាផ្សេងៗពាក់ព័ន្ធនឹងការចុះបញ្ជីម៉ាក ដោយផ្ទាល់ឬតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវបង់កម្រៃសេវាតាម តាមប្រកាសរួមលេខ ១២១៧ សហវ.ប្រក ចុះថ្ងៃទី២៧ ខែវិច្ឆកា ឆ្នាំ២០១៧ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម។ ចំពោះកម្រៃសេវាស្នើសុំក្រោយចុះបញ្ជីត្រូវបានកំណត់ដូចខាងក្រោម[74]៖

- ការចុះបញ្ជីម៉ាក និងបោះពុម្ពផ្សាយ ក្នុងមួយជំពូកទំនិញ ឬ សេវា ( ៤២០,០០០រៀល)
- ការដាក់ពាក្យស្នើសុំបញ្ជាក់ពីការប្រើប្រាស់ ឬមិនបានប្រើប្រាស់ ម៉ាក ម៉ាកសមូហភាព ម៉ាកវិញ្ញាតកម្ម ឬម៉ាកក្នុងក្របខណ្ឌអន្តរជាតិ ក្នុងមួយជំពូកទំនិញ ឬសេវា (១០០,០០០រៀល)
- ការស្នើសុំពន្យាពេលផ្តល់ទឡ្ហីករណ៍ ឬឯកសារគាំទ្រផ្សេងៗ (ចាប់ពីការចេញលិខិតលើកទី២ របស់នាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្ម) (១០០,០០០រៀល)
- ការលុបម៉ាក ម៉ាកសមូហភាព ម៉ាកវិញ្ញាតកម្ម ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ សិទ្ធិផ្តាច់មុខ ឬអាជ្ញាប័ណ្ណ/អាជ្ញាប័ណ្ណពិសេស ចេញពីបញ្ជី និងការបោះពុម្ពផ្សាយ (៣០០,០០០រៀល)
- ការដាក់ពាក្យ ការចុះបញ្ជីសាជាថ្មី និងបោះពុម្ពផ្សាយ ម៉ាក ម៉ាកសមូហភាព ឬម៉ាកវិញ្ញាតកម្ម (៤២០,០០០រៀល)
- ការស្នើសុំកត់ត្រា និងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខ (៦០០,០០០រៀល)។

## ផ្នែកទី២ ៖ ការត្រួតពិនិត្យ និងការសម្រេចលើពាក្យស្នើសុំចុះបញ្ជីម៉ាក

មុននឹងធ្វើការសម្រេចលើពាក្យស្នើសុំចុះបញ្ជីម៉ាកណាមួយបាន គឺមន្ត្រីកាន់កាប់បញ្ជីត្រូវត្រួតពិនិត្យលើពាក្យស្នើសុំនោះដោយផ្អែកលើមូលដ្ឋាននៃច្បាប់ដែលកំពុងជាធរមាន ពុំមែនដោយឆន្ទានុសិទ្ធិរបស់មន្ត្រីកាន់កាប់បញ្ជីនោះទេ។ ក្នុងករណីមន្ត្រីកាន់កាប់បញ្ជីសម្រេចយល់ព្រមលើការស្នើសុំចុះបញ្ជី នោះនីតិវិធីនៃការប្រកាសផ្សព្វផ្សាយអំពីការយល់ព្រមចុះបញ្ជីនេះ រួចទាំងបើកផ្លូវឲ្យមានការប្តឹងជំទាស់នឹងការសម្រេចចុះបញ្ជីឲ្យ នឹងត្រូវបានដាក់ឲ្យដំណើរការ នៅមុនពេលការទទួលស្គាល់នៃអនុភាពនៃការចុះបញ្ជីម៉ាក។[75]

[74] ប្រកាសរួមលេខ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្មចុះថ្ងៃទី២៧ ខែវិច្ឆកា ឆ្នាំ២០១៧

[75] សៀវភៅ នីតិកម្មសិទ្ធិបញ្ញា លោកកាន់ សុទ្ធប៉ូលីន, បោះពុម្ពលើកទី២, ឆ្នាំ២០១៤ ទំព័រ១៣៦

### ២.១ ការត្រួតពិនិត្យលើពាក្យស្នើសុំចុះបញ្ជីម៉ាក

បន្ទាប់ពីទទួលពាក្យស្នើសុំចុះបញ្ជីម៉ាករួច មន្ត្រីកាន់កាប់បញ្ជីត្រូវតែធ្វើការត្រួតពិនិត្យលើពាក្យស្នើសុំចុះបញ្ជីទាំងអស់នោះ ដើម្បីបញ្ជាក់ថា វាត្រឹមត្រូវតាមលក្ខណៈរបស់ច្បាប់ ឬអនុក្រឹត្យ។ ការត្រួតពិនិត្យនេះផងដែរធ្វើឡើងនៅក្នុងរយៈពេលមួយក្រោយការដាក់ពាក្យស្នើសុំ។[76]

#### ២.១.២ ការត្រួតពិនិត្យមើលលក្ខខណ្ឌទម្រង់នៃពាក្យស្នើសុំចុះបញ្ជីម៉ាក

គោលដៅសំខាន់ៗ ក្នុងការត្រួតពិនិត្យលើលក្ខខណ្ឌទម្រង់នៃពាក្យស្នើសុំចុះបញ្ជីម៉ាក គឺដើម្បីត្រួតពិនិត្យលើពត៌មានសំខាន់ៗទាំងឡាយ ដែលមានកំណត់ក្នុងពាក្យស្នើសុំចុះបញ្ជីម៉ាក ថាតើវាពិតជាបានបំពេញតាមលក្ខខណ្ឌដែលបានកំណត់ក្នុងមាត្រា៨ ចំណុច "ក" នៃច្បាប់ស្តីពីម៉ាកពាណិជ្ជនាម និងអំពើប្រកួតប្រជែងមិនស្មោះត្រង់បានត្រឹមត្រូវដែរទេ។

ប្រសិនបើមន្ត្រីកាន់កាប់បញ្ជីយល់ឃើញថា ពាក្យស្នើសុំចុះបញ្ជីម៉ាកមិនមានពត៌មានគ្រប់គ្រាន់តាមច្បាប់បានកំណត់នោះទេ មន្ត្រីកាន់កាប់បញ្ជី នឹងជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីភាពខ្វះខាតចន្លោះរបស់ពាក្យសុំ ហើយនឹងបង្គាប់ឲ្យម្ចាស់ម៉ាកធ្វើការបំពេញបន្ថែមភាពខ្វះចន្លោះក្នុងរយៈពេល៤៥ថ្ងៃ។ ក្នុងករណីម្ចាស់ម៉ាកមិនបានឆ្លើយតបទៅមន្ត្រីកាន់កាប់បញ្ជីក្នុងរយៈពេលកំណត់ខាងលើនោះទេ ម្ចាស់ម៉ាកត្រូវចាត់ទុកថាបោះបង់សិទ្ធិចោលក្នុងការស្នើសុំចុះបញ្ជីម៉ាក។[77]

#### ២.១.៣ ការត្រួតលើខ្លឹមសារនៃម៉ាក

បន្ទាប់ពីធ្វើការត្រួតពិនិត្យលើលក្ខខណ្ឌទម្រង់នៃពាក្យស្នើសុំរួចហើយ មន្ត្រីកាន់កាប់បញ្ជីត្រូវធ្វើការត្រួតពិនិត្យបន្តលើខ្លឹមសារនៃម៉ាក។ មន្ត្រីកាន់កាប់បញ្ជីត្រូវកត់ត្រាលើសំណុំឯកសារនៃពាក្យស្នើសុំចុះបញ្ជីទាំងនោះ ថាតើវាត្រឹមត្រូវទៅតាមការកំណត់ ហើយឬនៅ។ បន្ទាប់មកមន្ត្រីកាន់កាប់បញ្ជីត្រូវត្រួតពិនិត្យបញ្ជីដូចខាងក្រោម៖

**ក. ការត្រួតពិនិត្យខ្លឹមសារនៃម៉ាក (ជោគជ័យ)**

នៅពេលដែលមន្ត្រីកាន់កាប់បញ្ជីទទួលពាក្យសុំចុះបញ្ជីនីមួយៗ គេត្រូវកត់ត្រានៅលើសំណុំឯកសារ នៃពាក្យស្នើសុំចុះបញ្ជីម៉ាកនីមួយៗ នូវកាលបរិច្ឆេទពិតប្រាកដ និងលេខរៀងនៃការដាក់ពាក្យស្នើសុំចុះបញ្ជីត្រួតពិនិត្យលើពាក្យស្នើសុំរួចហើយ ដោយអនុវត្តតាមមាត្រា៨ ចំណុច ខ នៃច្បាប់ស្តីពីម៉ាក។ មន្ត្រីកាន់កាប់បញ្ជីត្រូវពិនិត្យមើលនូវពត៌មានថាគ្រប់គ្រាន់ និងត្រឹមត្រូវហើយឬនៅ នឹងពិនិត្យចំណុចដូចខាងក្រោម៖

- ឈ្មោះរបស់អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក

---

[76] តា ប៊ុនរិទ្ធ ប្រធានការិយាល័យចុះបញ្ជីម៉ាក នាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្ម

[77] អនុក្រឹត្យស្តីពី ការអនុវត្តច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើប្រកួតប្រជែងមិនស្មោះត្រង់, មាត្រា១៧(១)

- អាសយដ្ឋានទំនាក់ទំនង
- គំរូម៉ាកដែលស្នើសុំចុះបញ្ជី
- យថាប្រភេទរបស់ទំនិញ ឬសេវាដែលស្នើសុំចុះបញ្ជីក្នុងចំណាត់ថ្នាក់នីមួយៗ
- កម្រៃនៃការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក ដែលតម្រូវសម្រាប់ចំណាត់ថ្នាក់នីមួយៗ នៃទំនិញឬសេវាដែលស្នើសុំចុះបញ្ជីម៉ាក។

បន្ទាប់ពីបានត្រួតពិនិត្យពាក្យស្នើសុំចុះបញ្ជីចប់សព្វគ្រប់រួចមក និងយល់ឃើញថាម៉ាកនោះពិតជាត្រឹមត្រូវតាមទម្រង់និងបែបបទខាងលើ ហើយមន្ត្រីកាន់កាប់បញ្ជីម៉ាកយល់ព្រមចុះបញ្ជីម៉ាកនោះហើយ មន្ត្រីកាន់កាប់បញ្ជីត្រូវចុះបញ្ជីម៉ាក និងចេញវិញ្ញាបនបត្រ នៃការចុះបញ្ជីម៉ាកជូនអ្នកដាក់ពាក្យស្នើសុំចុះបញ្ជី ហើយត្រូវបោះពុម្ពផ្សាយការចុះបញ្ជីម៉ាកនោះ នៅក្នុងព្រឹត្តបត្រផ្លូវការរបស់ក្រសួងពាណិជ្ជកម្ម។[78]

### ខ. ការត្រួតពិនិត្យខ្លឹមសារដែលមានបញ្ហា

ប្រសិនបើមន្ត្រីកាន់កាប់បញ្ជី បានពិនិត្យឃើញថាពាក្យស្នើសុំចុះបញ្ជីមិនទាន់បានបំពេញបានត្រឹមត្រូវ ឬក៏មានចំណុចណាដែលមិនសមស្របនឹងមាត្រា៨ ចំណុច ខ នៃច្បាប់ស្តីពីម៉ាក ឬក៏មានចំណុចណាដែលត្រូវកែសម្រួល មន្ត្រីកាន់កាប់បញ្ជីត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ម្ចាស់ម៉ាកអំពីមូលហេតុនៃការច្រានចោលនោះ ដោយភ្ជាប់នូវពត៌មានលំអិតទាំងអស់ ដែលពាក់ព័ន្ធនឹងសេចក្តីសម្រេចរបស់ខ្លួន ហើយស្នើឲ្យអ្នកដាក់ពាក្យធ្វើការកែតម្រូវពាក្យស្នើសុំចុះបញ្ជីរបស់ខ្លួន និងផ្ញើចម្លើយតបទៅកាន់មន្ត្រីកាន់កាប់បញ្ជីជាលាយលក្ខណ៍អក្សរក្នុងរយៈពេល៩៥ថ្ងៃ បន្ទាប់ពីបានសេចក្តីជូនដំណឹងរបស់មន្ត្រីកាន់កាប់បញ្ជី។ ក្នុងករណីនេះម្ចាស់ម៉ាកមានសិទ្ធិកែសម្រួលពាក្យស្នើសុំចុះបញ្ជីម៉ាករបស់ខ្លួន ក្នុងរយៈពេល៩៥ថ្ងៃ បើផុតរយៈពេល៩៥ថ្ងៃនេះហើយម្ចាស់ម៉ាកនៅតែមិនកែតម្រូវពាក្យស្នើសុំរបស់ខ្លួនទៀត មន្ត្រីកាន់កាប់បញ្ជីមានសិទ្ធិបដិសេធការចុះបញ្ជីម៉ាកនោះ។

ករណីដែលអ្នកដាក់ពាក្យស្នើសុំចុះបញ្ជីបានឯកភាពគ្នាជាមួយ និងមន្ត្រីកាន់កាប់បញ្ជីអ្នកស្នើសុំត្រូវតែជូនដំណឹងទៅកាន់មន្ត្រីកាន់កាប់បញ្ជីវិញ ជាលាយលក្ខណ៍អក្សរ ហើយធ្វើការកែតម្រូវពាក្យស្នើសុំរបស់ខ្លួន ទៅតាមសេចក្តីជូនដំណឹងរបស់មន្ត្រីកាន់កាប់បញ្ជីម៉ាកខាងលើ។ ប៉ុន្តែផ្ទុយទៅវិញប្រសិនបើអ្នកដាក់ពាក្យស្នើសុំចុះបញ្ជី មិនយល់ស្របនឹងសេចក្តីជូនដំណឹងរបស់មន្ត្រីកាន់កាប់បញ្ជី ហើយមិនបានឆ្លើយតបតាមការកំណត់របស់មន្ត្រីកាន់កាប់បញ្ជី នោះអាចសន្មត់បានថាអ្នកដាក់ពាក្យស្នើសុំចុះបញ្ជីបានបោះបង់ចោលពាក្យស្នើសុំចុះបញ្ជីម៉ាករបស់ខ្លួនហើយ។

[78] សារណាបញ្ចប់ការសិក្សា កិច្ចការពារម៉ាក និងយន្តការនៃការដោះស្រាយវិវាទម៉ាកនៅកម្ពុជា ស្រាវជ្រាវដោយ ប៉ាត ណាវី និង ឆាយ សុភាព ជំនាន់ទី១៣, ឆ្នាំសរសេរសារណា ២០១៣, ទំព័រទី១៨

នៅក្នុងករណីមួយទៀតប្រសិនបើអ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកមិនយល់ស្រប មិនឯកភាព ឬចង់បដិសេធទៅនឹងសេចក្តីសម្រេចរបស់មន្ត្រីកាន់កាប់បញ្ជី ម្ចាស់ម៉ាកមានសិទ្ធិដាក់ពាក្យស្នើសុំសវនាការមួយ ឬផ្តល់នូវការយល់ឃើញរបស់ខ្លួនជាលាយលក្ខណ៍អក្សរទៅមន្ត្រីកាន់កាប់បញ្ជីក្នុងរយៈពេល៦០ថ្ងៃ បន្ទាប់ពីបានទទួលសេចក្តីសម្រេចរបស់មន្ត្រីកាន់កាប់បញ្ជី។ បន្ទាប់ពីបានទទួលពាក្យបណ្តឹងរបស់អ្នកដាក់ពាក្យស្នើសុំបើកសវនាការហើយ មន្ត្រីកាន់កាប់បញ្ជីត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ទៅអ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកយ៉ាងយូរ ១ខែ មុនកាលបរិច្ឆេទដែលអ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកចូលក្នុងសវនាការ។

បន្ទាប់ពីមានសវនាការ ហើយមន្ត្រីកាន់កាប់បញ្ជីនៅតែបដិសេធមិនព្រមទទួលចុះបញ្ជី ហើយច្រានចោលពាក្យ ចុះបញ្ជីនោះទៀតមន្ត្រីកាន់កាប់បញ្ជីត្រូវតែជូនដំណឹងអំពីសេចក្តីបដិសេធរបស់ខ្លួន ជាលាយលក្ខណ៍អក្សរទៅអ្នកដាក់ពាក្យស្នើសុំ។ លើសពីនេះទៅទៀត អ្នកដាក់ពាក្យស្នើសុំមានសិទ្ធិទាមទារឲ្យមន្ត្រីកាន់កាប់បញ្ជីបញ្ជាក់ពីមូលហេតុ និងឯកសារដែលពាក់ព័ន្ធដែលមន្ត្រីកាន់កាប់បញ្ជីសម្រេចមិនព្រមចុះបញ្ជី ក្នុងរយៈពេល១ខែ បន្ទាប់ពីទទួលបានសេចក្តីសម្រេច។

លើសពីនេះទៅទៀត ប្រសិនបើមន្ត្រីកាន់កាប់បញ្ជីនៅតែបដិសេធមិនព្រមទទួលចុះបញ្ជីទៀត ហើយអ្នកដាក់ពាក្យស្នើសុំចុះបញ្ជីនៅតែមិនឯកភាពនឹងសេចក្តីសម្រេចរបស់មន្ត្រីកាន់កាប់បញ្ជី អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីមានសិទ្ធិប្តឹងទៅក្រុមប្រឹក្សាដោះស្រាយបណ្តឹងតវ៉ា ឬក៏ប្តឹងទៅតុលាការក៏បានដែរ ក្នុងរយៈពេល៣ខែ គិតចាប់ពីថ្ងៃដែលគាត់ទទួលបានសេចក្តីសម្រេចរបស់មន្ត្រីកាន់កាប់បញ្ជី។ ប្រសិនបើ ក្រុមប្រឹក្សាដោះស្រាយបណ្តឹងតវ៉ា នៅតែបដិសេធការចុះបញ្ជីនោះទៀត អ្នកដាក់ពាក្យស្នើសុំចុះបញ្ជី មានសិទ្ធិប្តឹងតវ៉ានឹងសេចក្តីសម្រេច របស់ក្រុមប្រឹក្សាដោះស្រាយវិវាទទៅតុលាការដែលមានសមត្ថកិច្ច ក្នុងរយៈពេល៣ខែ គិតពីថ្ងៃដែលចេញសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាបណ្តឹងតវ៉ា (ដោយសារតែនៅកម្ពុជាយើងមិនទាន់មានក្រុមប្រឹក្សាដោះស្រាយបណ្តឹងតវ៉ានៅឡើយទេ ដូចនេះនីតិវិធីនៃការដាក់ពាក្យបណ្តឹងតវ៉ា គឺអ្នកដាក់ពាក្យបណ្តឹងទៅតុលាការដើម្បីជំទាស់ជាមួយនឹងសេចក្តីសម្រេចរបស់មន្ត្រីកាន់កាប់បញ្ជី)។[79]

## ២.២ ការសម្រេចលើការស្នើសុំចុះបញ្ជីម៉ាក

ដោយផ្អែកលើមូលដ្ឋាននៃការត្រួតពិនិត្យទាំងពីរខាងលើនេះ ប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្ម ដែលជាមន្ត្រីកាន់កាប់បញ្ជី នឹងត្រូវធ្វើការសម្រេចសេចក្តីថាត្រូវបដិសេធការចុះបញ្ជី ឬក៏យល់យល់ព្រមលើពាក្យស្នើសុំចុះបញ្ជី។

[79] សារណាបញ្ចប់ការសិក្សា កិច្ចការពារម៉ាក និងយន្តការនៃការដោះស្រាយវិវាទម៉ាកនៅកម្ពុជា ស្រាវជ្រាវដោយ ប៉ាត ណារី និង ឆាយ សុភាព ជំនាន់ទី១៣, ឆ្នាំសរសេរសារណា ២០១៣, ទំព័រទី២១

### ២.២.១ ការបដិសេធចំពោះការចុះបញ្ជី

ការជំទាស់ចំពោះការចុះបញ្ជីម៉ាក អាចបណ្តាលឲ្យម៉ាកមួយគ្មានអានុភាព ឬត្រូវផ្អាកសកម្មភាពមួយរយៈ។ មានកត្តាច្រើនដែលអាចធ្វើឲ្យម៉ាកមិនអាចចុះបញ្ជីបានដូចជា ម៉ាកដែលបានហាមឃាត់ដោយមាត្រា ៩ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ដែលជាដើមហេតុ នាំឲ្យមានការជំទាស់ទៅនឹងការចុះបញ្ជីម៉ាកពីសំណាក់មន្រ្តីកាន់កាប់បញ្ជី។[80]

#### ក. ការជំទាស់លើពាក្យស្នើសុំ

មន្រ្តីកាន់កាប់បញ្ជី នឹងធ្វើការបដិសេធចុះបញ្ជីដល់ម៉ាកទាំងឡាយដែលអ្នកស្នើសុំ ពុំអាចបំពេញតាមបាននូវរាល់លក្ខខណ្ឌតម្រូវដោយច្បាប់។ បើតាមមាត្រា ១០ចំណុច "ខ" នៃច្បាប់ស្តីពីម៉ាក មន្រ្តីកាន់កាប់បញ្ជីមានសិទ្ធិចាត់ឲ្យអ្នកស្នើសុំចុះបញ្ជីធ្វើការកែតម្រូវក្នុងរយៈពេល ៩៥ថ្ងៃ បន្ទាប់ពីថ្ងៃជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការកែតម្រូវដោយមន្រ្តីកាន់កាប់បញ្ជីមក។ ទោះជាយ៉ាងណាបើផ្អែកតាមមាត្រា ៥៦ នៃច្បាប់ស្តីពីម៉ាក រយៈពេល៩៥ថ្ងៃនេះ អាចនឹងត្រូវពន្យារឲ្យបាន ដោយអំណាចឆន្ទានុសិទ្ធិរបស់ម្រ្តីកាន់កាប់បញ្ជី។ ដោយឡែកការមិនព្រមធ្វើការកែតម្រូវកំហុសឆ្គងក្នុងរយៈពេលកំណត់ខាងលើ មន្រ្តីកាន់បញ្ជីអាចចាត់ទុកថាអ្នកដាក់ពាក្យសុំនោះ បានបោះបង់ចោលពាក្យស្នើសុំចុះបញ្ជីម៉ាករបស់ខ្លួនទៅវិញហើយ។ ម្យ៉ាងទៀត តាមសំណើសុំជាលាយលក្ខណ៍អក្សររបស់អ្នកដាក់ពាក្យស្នើសុំ មន្រ្តីកាន់កាប់បញ្ជី អាចទទួលព្រមឲ្យមានសវនាការមួយ មុននឹងសម្រេចបដិសេធការដាក់ពាក្យស្នើសុំចុះបញ្ជីនេះផងទៀតក៏បាន។[81]

#### ខ. ការអនុវត្តជំទាស់ក្នុងការចុះបញ្ជីដោយម្ចាស់ម៉ាក

បណ្តឹងជំទាស់ ត្រូវបានធ្វើឡើងដោយតតិយជន ដើម្បីប្រឆាំងជំទាស់នឹងការចុះបញ្ជីម៉ាកនេះ ហើយការធ្វើបណ្តឹងប្រភេទនេះ គឺត្រូវធ្វើឡើងចំពោះមុខមន្រ្តីដែលបានចុះបញ្ជី។ ប្រសិនបើអ្នកសុំចុះបញ្ជីធ្វើពាក្យជំទាស់ មន្រ្តីកាន់កាប់បញ្ជីត្រូវផ្តល់ចម្លើយមួយច្បាប់ទៅអ្នកដែលបានប្តឹងជំទាស់។ ប្រសិនបើភាគីម្ខាង ឬភាគីទាំងសងខាងមានបំណងឲ្យមានសវនាការ នោះមន្រ្តីកាន់កាប់បញ្ជីត្រូវរៀបចំឲ្យមានសវនាការនោះ។ បន្ទាប់ពីបានស្តាប់ភាគីទាំងសងខាង និងពិចារណាលើពាក្យតវ៉ា មន្រ្តីកាន់កាប់បញ្ជីត្រូវសម្រេចថា ម៉ាកដែលបានចុះបញ្ជីនេះ ត្រូវរក្សាទុក ឬបដិសេធ។ បញ្ជាក់បានថាម្ចាស់ម៉ាកអាចធ្វើការជំទាស់ និងម៉ាករបស់បុគ្គលណាម្នាក់ទៅមន្រ្តីកាន់កាប់បញ្ជី ឬស្នើសុំឲ្យមានការរៀបចំសវនាការដើម្បីវិនិច្ឆ័យ ថាតើម៉ាកនោះត្រូវរក្សាទុក ឬបដិសេធចំពោះការចុះបញ្ជី ឬការជំទាស់របស់ម្ចាស់ម៉ាកនោះត្រឹមត្រូវដែរ ឬទេ។

[80] សៀវភៅ នីតិកម្មសិទ្ធិបញ្ញាកម្ពុជា លោកនី វិចិត្រ, បោះពុម្ពលើកទី១, ឆ្នាំ២០១៣, ទំព័រ ២១៦
[81] សៀវភៅ នីតិកម្មសិទ្ធិបញ្ញា លោកកាន់ សុទ្ធប៊ូលីន, បោះពុម្ពលើកទី២, ឆ្នាំ២០១៤ ទំព័រ១៤០

### គ. ការជំទាស់ក្នុងការចុះបញ្ជីម៉ាកដោយអ្នកទទួលសិទ្ធិ

ការជំទាស់ក្នុងការចុះបញ្ជីម៉ាកដោយអ្នកទទួលសិទ្ធិ មិនមែនមានតែម្ចាស់ម៉ាកទេដែលអាចធ្វើការជំទាស់បាន អ្នកទទួលសិទ្ធិក៏អាចធ្វើការជំទាស់បានផងដែរ។ នៅពេលម្ចាស់ម៉ាក ផ្ទេរសិទ្ធិតាមរយៈកិច្ចសន្យាអនុប្បទាន កិច្ចសន្យាអាជ្ញាប័ណ្ណ ឬកិច្ចសន្យាខ្ចីយីហោ អ្នកទទួលសិទ្ធិមានការជំទាស់ក្នុងការចុះបញ្ជីម៉ាកនោះ "ជនណាដែលមានការពាក់ព័ន្ធ អាចស្នើសុំទៅក្រសួងពាណិជ្ជកម្មឲ្យផ្តល់មោឃភាពដល់ការចុះបញ្ជីម៉ាកបាន"។[82] មានន័យថា ម្ចាស់សិទ្ធិអាចធ្វើការជំទាស់ការចុះបញ្ជីម៉ាកបាន ពីព្រោះខ្លួនក៏ជាបុគ្គលជាប់ពាក់ព័ន្ធនឹងម៉ាក ហើយក៏អាចប៉ះពាល់ប្រយោជន៍ផ្ទាល់ខ្លួនផងដែរ ដូច្នេះទើបម្ចាស់សិទ្ធិអាចស្នើសុំក្រសួងឲ្យផ្តល់មោឃភាពចំពោះម៉ាកដែលចុះបញ្ជីនោះ។

### ឃ. ការជំទាស់ក្នុងការចុះបញ្ជីម៉ាកដោយមន្ត្រីកាន់កាប់បញ្ជី

មន្ត្រីកាន់កាប់បញ្ជី គឺជាអ្នកដែលមានសិទ្ធិជំទាស់ទៅនឹងការចុះបញ្ជីមុនគេ ពីព្រោះមន្ត្រីកាន់កាប់បញ្ជីជាអ្នកអនុវត្តច្បាប់ ហើយអាចដឹងមុនគេនៅពេលដែលមានបុគ្គលណាម្នាក់យកម៉ាករបស់គេទៅចុះបញ្ជី។ ការជំទាស់ក្នុងការចុះបញ្ជីម៉ាករបស់មន្ត្រីកាន់កាប់បញ្ជី ក៏អាចបណ្តាលមកពីពាក្យស្នើសុំចុះបញ្ជីម៉ាកមិនបានស្របទៅតាមទម្រង់ដែលបានកំណត់ ឬក៏មានចំណុចណាមួយដែលតម្រូវឲ្យមានការកែប្រែ ហើយមន្ត្រីកាន់កាប់បញ្ជីត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអ្នកស្នើសុំចុះបញ្ជីតាមការកំណត់រយៈពេល៤៥ថ្ងៃ ហើយអ្នកស្នើសុំចុះបញ្ជីមិនបានកែតម្រូវ ជាហេតុដែលធ្វើឲ្យមន្ត្រីកាន់កាប់បញ្ជីជំទាស់ក្នុងការចុះបញ្ជីម៉ាកនោះ។[83]

មន្ត្រីកាន់កាប់បញ្ជីម៉ាកនៃក្រសួងពាណិជ្ជកម្ម ក៏អាចជំទាស់ចំពោះការចុះបញ្ជីម៉ាកដែលបានចុះបញ្ជីរួចផងដែរ នៅពេលម្ចាស់ម៉ាកមិនបានដាក់ពាក្យសុំចុះសារជាថ្មី នូវម៉ាកដែរបានចុះបញ្ជីរួចហើយ តាមរយៈពេលដែលបានកំណត់ ម្ចាស់ម៉ាកដែលបានចុះបញ្ជីម៉ាករួចហើយ ស្នើសុំលុបម៉ាកម្ចាស់ម៉ាកដែរបានចុះបញ្ជីរួចហើយ ក្នុងរយៈពេល៩០ថ្ងៃ មិនគោរពលក្ខខណ្ឌនៃការផ្តល់ឯកសារគាំទ្រ ឬការកម្រិតដែលបានកំណត់ ម្ចាស់ម៉ាកដែលបានចុះបញ្ជីរួចហើយ លែងមានអាសយដ្ឋានទាក់ទងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងករណីជឿជាក់ដោយផ្អែកលើភស្តុតាងថាម្ចាស់ម៉ាកដែលបានចុះបញ្ជីម៉ាករួច ហើយមិនមែនជាម្ចាស់ម៉ាកស្របច្បាប់ និងជឿជាក់ថា ម៉ាកដែលបានចុះបញ្ជីម៉ាករួចហើយប្រហាក់ប្រហែល ឬស្រដៀងទៅនឹងម៉ាកល្បី ដែលជាកម្មសិទ្ធិរបស់ម៉ាកល្បី។[84]

---

[82] ច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាមនិងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, ៧ កុម្ភៈ ឆ្នាំ២០០២, មាត្រា១០(ក)

[83] ច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាមនិងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, ៧ កុម្ភៈ ឆ្នាំ២០០២, មាត្រា១០(ខ)

[84] ច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាមនិងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, ៧ កុម្ភៈ ឆ្នាំ២០០២, មាត្រា១៤

**២.២.៣ ការយល់ព្រមចុះបញ្ជីម៉ាក**

យោងតាមមាត្រា ១០ចំណុច "ក" នៃច្បាប់ស្តីពីម៉ាកកាលបើមន្ត្រីកាន់កាប់បញ្ជីពិនិត្យឃើញថាពាក្យស្នើសុំបានបំពេញតាមត្រឹមត្រូវនូវរាល់លក្ខខណ្ឌតម្រូវនានាដោយច្បាប់ មន្ត្រីកាន់កាប់បញ្ជីត្រូវធ្វើការចុះបញ្ជីម៉ាក និងចេញវិញ្ញាបនបត្រចុះបញ្ជីជូនដល់អ្នកដាក់ពាក្យស្នើសុំ រួចត្រូវធ្វើការចុះផ្សាយនៅក្នុងព្រឹត្តិប័ត្រផ្លូវការរបស់ក្រសួងពាណិជ្ជកម្មស្តីពីការចុះបញ្ជីម៉ាកថ្មីនេះ។[85] ចំពោះការយល់ព្រមចុះបញ្ជីនេះដែរ មន្ត្រីកាន់កាប់បញ្ជី ក៏មានសិទ្ធិអំណាចក្នុងការសម្រេចយល់ព្រមដោយមានភ្ជាប់នូវលក្ខខណ្ឌ ពោលគឺលក្ខខណ្ឌឲ្យមានការកែតម្រូវ ការកែសម្រួល ការឈប់ទាមទារសិទ្ធិ ឬការកម្រិតសិទ្ធិណាមួយ។ បើលក្ខខណ្ឌភ្ជាប់នេះពុំត្រូវបានយល់ព្រមគោរពតាមដោយអ្នកស្នើសុំចុះបញ្ជីទេនោះ មន្ត្រីកាន់កាប់បញ្ជីអាចសម្រេចច្រានចោលការស្នើសុំចុះបញ្ជីម៉ាកនោះវិញបាន។[86]

**ក. ការចេញវិញ្ញាបនបត្រចុះបញ្ជីម៉ាក**

វិញ្ញាបនបត្រនៃការចុះបញ្ជីមានពីរប្រភេទគឺ វិញ្ញាបនបត្រមានលក្ខខណ្ឌ និងវិញ្ញាបនបត្រធម្មតា។ វិញ្ញាបនបត្រធម្មតា គឺម្ចាស់ម៉ាកមានសិទ្ធិពេញលេញក្នុងការប្រើប្រាស់ម៉ាកស្របច្បាប់នៅក្នុងប្រទេសកម្ពុជា។ បើម្ចាស់ម៉ាកបានទទួលវិញ្ញាបនបត្រនេះ ម្ចាស់ម៉ាកមានសិទ្ធិប្រើប្រាស់សេវាគ្រប់ទីកន្លែងដោយមិនមានការកម្រិតសិទ្ធិនោះទេ។ <u>ឧទាហរណ៍</u> ៖ លោក "ក" គាត់បង្កើតម៉ាកមួយជាប្រេនខ្សែក្រវាត់ មានឈ្មោះថា "Tiger" ហើយគាត់បានចុះបញ្ជីនៅក្នុងប្រទេសកម្ពុជា ដូច្នេះគាត់មានសិទ្ធិប្រើប្រាស់វាដោយពុំមានកម្រិតព្រំដែន ការកំណត់នៃផលិតផល ឬសេវាណាមួយជាដើម។

រីឯ វិញ្ញាបនបត្រមានលក្ខខណ្ឌ មានន័យថា ម៉ាកដែលបានចុះបញ្ជីការពារនៅក្នុងប្រទេសកម្ពុជាយើងគឺមានការអនុញ្ញាតប្រើប្រាស់ក្នុងលក្ខខណ្ឌកំណត់មួយចំនួន ដែលមានព្រំដែនកំណត់នៃម៉ាក។

វិញ្ញាបនបត្រចុះបញ្ជីម៉ាក នឹងចេញដោយនាយកដ្ឋានកម្មសិទ្ធិបញ្ញា បន្ទាប់ពីការត្រួតពិនិត្យលើពាក្យស្នើសុំហើយ នឹងត្រូវបានបោះផ្សាយជាសាធារណៈ នៅក្នុងប្រតិបត្តិចុះបញ្ជីម៉ាកប្រចាំខែរបស់ក្រសួងពាណិជ្ជកម្ម។ ទោះមានការចេញនូវវិញ្ញាបនបត្រដោយមន្ត្រីកាន់កាប់បញ្ជីក៏ដោយ ក៏មិនមានន័យថា អ្នកដាក់ពាក្យស្នើសុំនោះជាម្ចាស់ម៉ាកដែល។ ជាហេតុនេះហើយ តតិយជននៅតែមានសិទ្ធិនៅក្នុងការប្តឹងលុបម៉ាកពីបញ្ជីម៉ាកវិញបាន បន្ទាប់ពីមានការបោះពុម្ពផ្សាយជាសាធារណៈនៅក្នុងព្រឹត្តិបត្ររបស់ក្រសួងពាណិជ្ជកម្ម នៅក្រោមមូលហេតុកំណត់ដោយច្បាប់។[87]

[85] សៀវភៅ នីតិកម្មសិទ្ធិបញ្ញា លោកកាន់ សុទ្ធប៉ូលីន, បោះពុម្ពលើកទី២, ឆ្នាំ២០១៨ ទំព័រ ១៨១

[86] អនុក្រឹត្យ ស្តីពីការអនុវត្តច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ២០០៦, មាត្រា១៨(១)

[87] សៀវភៅ នីតិកម្មសិទ្ធិបញ្ញាកម្ពុជា លោកនី វិចិត្រ, បោះពុម្ពលើកទី១, ឆ្នាំ២០១៣, ទំព័រ ២១៦

**ខ. ការផ្សព្វផ្សាយជាសាធារណៈ**

គ្រប់ម៉ាកដែលបានចុះបញ្ជីនៅនាយកដ្ឋានកម្មសិទ្ធិបញ្ញា នឹងត្រូវធ្វើការផ្សព្វផ្សាយនៅក្នុងប្រតិបត្តិប្រចាំខែរបស់ក្រសួងពាណិជ្ជកម្ម។ គោលបំណងនៃការផ្សព្វផ្សាយនេះ គឺដើម្បីជូនដំណឹងដល់សាធារណៈជន ឬបុគ្គលដែលពាក់ព័ន្ធអំពីវត្តមាននៃការចុះបញ្ជីម៉ាកនៅក្នុងប្រទេសកម្ពុជា។ តែនៅក្នុងករណីដែលម្ចាស់ម៉ាកបានចុះបញ្ជីរួច ឬបុគ្គលពាក់ព័ន្ធនោះបានយល់ឃើញថាមានលក្ខណៈភ័ន្តច្រឡំជាមួយនឹងម៉ាករបស់ខ្លួន បុគ្គលនោះអាចធ្វើពាក្យបណ្តឹងសុំលុបម៉ាកនោះចេញ ពីបញ្ជីម៉ាកផងដែរ។[88] ចំពោះម៉ាកដែលបានចុះបញ្ជីរួច ប៉ុន្តែមិនបានប្រើប្រាស់សោះនៅក្នុងរយៈពេល៥ឆ្នាំ តាមច្បាប់កម្ពុជា តាមច្បាប់ត្រូវលុបចោលចេញពីបញ្ជី។ ប៉ុន្តែក្នុងលក្ខខណ្ឌមួយដែលម្ចាស់ម៉ាកបានបង្ហាញថាមិនមានគំនិតចង់បោះបង់ទេ តែមានកាលៈទេសៈពិសេសណាមួយមករារាំង ក្នុងករណីបែបនេះម៉ាកនោះ នឹងមិនត្រូវលុបចេញពីបញ្ជីម៉ាកនោះឡើយ។ ចំពោះជនដែលពាក់ព័ន្ធអាចស្នើសុំឲ្យក្រសួងពាណិជ្ជកម្ម លុបម៉ាកចេញពីបញ្ជី មួយខែមុនកាលបរិច្ឆេទ៥ឆ្នាំ នៃការមិនប្រើប្រាស់ ឬក្រោយការប្រើប្រាស់។

ដើម្បីរក្សាសុពលភាពនៃម៉ាកមួយដែលបានចុះបញ្ជីម៉ាករួចហើយ ឬម៉ាកដែលបានចុះបញ្ជីសារឡើងវិញ ច្បាប់ម៉ាកតម្រូវឲ្យម្ចាស់ម៉ាកត្រូវដាក់ពាក្យប្រកាសអំពីការប្រើប្រាស់ ឬការមិនប្រើប្រាស់ នៃម៉ាកនោះក្នុងរយៈពេលមួយឆ្នាំ បន្ទាប់ពីមានកាលបរិច្ឆេទចុះបញ្ជីម៉ាក។[89]

**ឃ. បណ្តឹងជំទាស់លើម៉ាក**

បណ្តឹងជំទាស់នឹងសេចក្តីសម្រេចចុះបញ្ជី អាចនឹងត្រូវបានធ្វើឡើងដោយតតិយជន ដើម្បីប្រឆាំងជំទាស់នឹងការចុះបញ្ជីម៉ាកនេះ។ នីតិវិធីនៃការធ្វើបណ្តឹងប្រភេទនេះ គឺត្រូវធ្វើឡើងចំពោះមុខមន្ត្រីចុះបញ្ជីផ្ទាល់ ពុំមែនធ្វើទៅតុលាការមានសមត្ថកិច្ចនោះទេ ដោយអនុលោមតាមមាត្រា ១០នៃច្បាប់ស្តីពីម៉ាក។ ចំណុច"គ" នៃមាត្រា១០ បានបង្កើតនូវអាជ្ញាយុកាល ៩០ថ្ងៃ បន្ទាប់ពីបានចុះផ្សាយនៅក្នុងព្រឹត្តិប័ត្រផ្លូវការរបស់ក្រសួងមក សម្រាប់បើកលទ្ធភាពឲ្យដល់បណ្តឹងជំទាស់ នឹងការចុះបញ្ជីម៉ាករបស់ជនទាំងឡាយណា ដែលមានការពាក់ព័ន្ធផលប្រយោជន៍ក្នុងការចុះបញ្ជីម៉ាកនេះ។ រយៈពេលកំណត់ ៩០ (កៅសិប)ថ្ងៃនេះ ការចុះបញ្ជីម៉ាកនឹងត្រូវបានចាត់ទុកថាមានសុពល ភាពហើយ បណ្តឹងជំទាស់ណាមួយ ដើម្បីប្រឆាំងទៅនឹងម៉ាកដែលមានសុពលភាពនេះ គឺត្រូវតែជាបណ្តឹងសុំមោឃភាពម៉ាកនោះចោលតែប៉ុណ្ណោះ។[90]

[88] សៀវភៅ នីតិកម្មសិទ្ធិបញ្ញាកម្ពុជា លោកនី វិចិត្រ, បោះពុម្ពលើកទី១, ឆ្នាំ២០១៣, ទំព័រ ២១៦

[89] អនុក្រឹត្យ ស្តីអីការអនុវត្តច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើប្រកួតប្រជែងមិនស្មោះត្រង់, ២០០៦ មាត្រា២១

[90] សៀវភៅ នីតិកម្មសិទ្ធិបញ្ញា លោកកាន់ សុទ្ធប៉ូលីន, បោះពុម្ពលើកទី២, ឆ្នាំ២០១៤ ទំព័រ ១៤៣

ក្នុងរយៈពេលកំណត់៩០ (កៅសិប) ថ្ងៃនេះដែរ កាលបើមានបណ្តឹងជំទាស់មន្ត្រីកាន់កាប់បញ្ជីត្រូវបញ្ជូនជាបន្ទាន់នូវសេចក្តីជូនដំណឹងនេះ ទៅអ្នកស្នើសុំចុះបញ្ជី ដើម្បីឲ្យអ្នកស្នើសុំចុះបញ្ជីធ្វើបញ្ជាក់នូវមូលដ្ឋានបង្អែកនៃការចុះបញ្ជីម៉ាករបស់ខ្លួន។[91] អវត្តមាននៃការឆ្លើយបតរបស់អ្នកស្នើសុំចុះបញ្ជី ត្រូវចាត់ទុកថាបានបោះបង់ការចុះបញ្ជីរបស់ខ្លួនចោលទៅវិញផងដែរ។

ដោយឡែក នៅក្នុងករណីដែលអ្នកស្នើសុំចុះបញ្ជី បានបញ្ជាក់មូលដ្ឋានស្របច្បាប់របស់ខ្លួនក្នុងការចុះបញ្ជីនេះ មន្ត្រីកាន់កាប់បញ្ជីត្រូវផ្តល់ឲ្យមាននូវសវនាការមួយដើម្បីបានស្តាប់ភាគីទាំងសងខាងធ្វើការតវ៉ានោះ។ ក្នុងករណីនេះតួនាទីរបស់មន្ត្រីកាន់កាប់បញ្ជី គឺពុំមែនជាអ្នកសម្របសម្រួលនោះទេ ប៉ុន្តែគឺជាអ្នកមានសិទ្ធិសម្រេចតែម្តង ថាតើត្រូវរក្សាការចុះបញ្ជីម៉ាកនេះ ក៏ត្រូវបដិសេធការចុះបញ្ជីនោះចោល។[92]

[91] អនុក្រឹត្យស្តីពីការ អនុវត្តច្បាប់ស្តីពីម៉ាក ,មាត្រា២០

[92] សៀវភៅ នីតិកម្មសិទ្ធិបញ្ញា របស់លោកគ្រូ កាន់ សុទ្ធប៉ូលីន, ទំព័រ១៥៤

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវយ៉ាងយកចិត្តទុកដាក់អស់មួយរយៈពេលកន្លងមក លើប្រធានបទ "**ការចុះបញ្ជីម៉ាកនៅកម្ពុជា**" ធ្វើឲ្យពួកខ្ញុំបានយល់ដឹងកាន់តែច្បាស់ អំពីសារៈសំខាន់នៃ**ការចុះបញ្ជីម៉ាក** ។ ម៉ាក មានសារៈសំខាន់ណាស់បម្រាប់ពាណិជ្ជករទាំងឡាយ ម៉ាកគឺ ជាសញ្ញាណមួយដែលធ្វើឲ្យ អតិថិជន ឬ អ្នកប្រើប្រាស់ ងាយស្រួលសម្រាប់សំគាល់អំពីលក្ខណៈខុសគ្នារវាងទំនិញ ឬ សេវា របស់សហគ្រាសមួយ និងសហគ្រាសមួយផ្សេងទៀត។[93] ហើយដើម្បីឲ្យម៉ាកមួយទទួលបានការការពារយ៉ាងស្របច្បាប់បាន នោះលុះត្រាតែម្ចាស់ម៉ាក យកម៉ាករបស់ខ្លួនមកចុះបញ្ជីម៉ាកយ៉ាងត្រឹមត្រូវនៅនាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្ម។ ប៉ុន្តែមិនមែនគ្រប់ម៉ាកទាំងអស់ សុទ្ធតែអាចយកមកធ្វើការចុះបញ្ជីបាននោះទេ យោងតាមមាត្រា៤ នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើប្រកួតប្រជែងមិនស្មោះត្រង់ បានបញ្ញត្តិយ៉ាងច្បាប់អំពីប្រភេទនៃម៉ាកដែលមិនអាចចុះបញ្ជីបាន មានដូចជា ម៉ាកដែលមិនអាចសម្គាល់លក្ខណៈខុសគ្នានៃទំនិញ ឬសេវា ម៉ាកដែលនាំឲ្យសាធារណៈជន ឬមជ្ឈដ្ឋានពាណិជ្ជកម្ម មានការយល់ច្រឡំ ទៅនឹងប្រភពភូមិសាស្ត្រទំនិញ ឬសេវាពាក់ព័ន្ធ ឬធាតុដើម ឬ លក្ខណៈខាងក្រៅរបស់ទំនិញ ឬសេវានោះ។ ម៉ាកដែលដូចគ្នានឹងម៉ាកដែលបានចចុះបញ្ជីរួច ម៉ាកដែលដូច ឬប្រហាក់ប្រហែលទៅនឹងម៉ាកល្បី និងម៉ាកដែលហាមាឃាត់ដោយអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋ ឬអង្គការអន្តរជាតិដែលពាក់ព័ន្ធនានា។ ដូច្នេះគ្រប់ការចុះបញ្ជីម៉ាកទាំងអស់ត្រូវតែគោរពតាម បទបញ្ញត្តិដែឡពាក់ព័ន្ធនានា មានដូចជាច្បាប់ អនុក្រឹត្យ ប្រកាស ជាដើម។

ដូចដែលបានរៀបរាប់ខាងលើ គ្រប់ម៉ាកទាំងអស់មិនប្រាកដថាអាចចុះបញ្ជីបាននោះទេ វាគឺជាផលវិបាកមួយសម្រាប់ម្ចាស់ម៉ាក ដែលគួតែស្វែងយល់ពីម៉ាក ថាតើម៉ាកយ៉ាងដូចម្តេចដែលច្បាប់មិនហាមឃាត់ និងម៉ាកដែលមិនស្រដៀងទៅនឹងម៉ាកដែលបានចុះបញ្ជីរួច។ ទន្ទឹមនឹងនោះផងដែរ ដោយសារប្រទេសកម្ពុជាយើង កំពុងតែមានការអភិវឌ្ឍន៍ ដូច្នេះការផ្សព្វផ្សាយទៅឲ្យសាធារណៈជនដឹងពីម៉ាក គឺនៅមានកម្រិតនៅឡើយ បូករួមទាំងវិស័យបច្ចេកវិទ្យា។ ម្យ៉ាងវិញទៀត សម្រាប់ការស្រាវជ្រាវស្វែងរកម៉ាកដែលបានចុះបញ្ជីរួច គឺជាបញ្ហារបស់មន្ត្រីទទួលបន្ទុកក្នុងការចុះបញ្ជី ថាតើម៉ាកមួយណាដែលគេបានយកមកចុះបញ្ជីនេះ ត្រូវចុះបញ្ជីហើយឬនៅ? ឬក៏អាចមានការប្រហាក់ប្រហែលគ្នាទៅនឹងម៉ាកដែលគេបានចុះបញ្ជីរួចហើយ នេះជាបញ្ហាដែលកើតមាននៅពេលចុះបញ្ជីដែលម្ចាស់ម៉ាកទាំងអស់គួតែស្វែងយល់ពីបញ្ហាទាំងអស់នេះមុននឹងយកម៉ាករបស់ខ្លួនមកធ្វើការចុះបញ្ជីនៅនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម។

[93] មាត្រា២ នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើប្រកួតប្រជែងមិនស្មោះត្រង់, ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០២

ការចុះបញ្ជីម៉ាក ពិតជាមានសារៈសំខាន់ខ្លាំងណាស់ចំពោះម្ចាស់ម៉ាកទាំងអស់ ដើម្បីទទួលបានការការពារលើម៉ាកមួយយ៉ាងស្របច្បាប់ នៅពេលដែលមានការរំលោភបំពានមួយបានកើតឡើង។ ម្យ៉ាងគ្រប់ការចុះបញ្ជីម៉ាកទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជាយើង មិនបានកំណត់ថាម្ចាស់ម៉ាកទាំងអស់ ត្រូវមកធ្វើការចុះបញ្ជីម៉ាករបស់ខ្លួនជាមួយនឹងក្រសួងនោះទេ ពីព្រោះវាជាសិទ្ធិរបស់ពួកគាត់នៅក្នុងការចុះបញ្ជី ឬក៏មិនចុះម៉ាករបស់ខ្លួន ប៉ុន្តែការអាក់ខានមិនបានចុះបញ្ជីម៉ាកធ្វើឲ្យ ម្ចាស់ម៉ាកខូចខាតប្រយោជន៍នៅពេលដែលពួកគេត្រូវបាន ជនដទៃទៀតលួចយកម៉ាករបស់ខ្លួនទៅប្រើប្រាស់នៅក្នុងផ្លូវមួយផ្សេងទៀត។ ដើម្បីទទួលបានការការពារពីច្បាប់ ម្ចាស់ម៉ាកគួតែយកម៉ាករបស់ខ្លួនទៅធ្វើការចុះបញ្ជីម៉ាក ពីព្រោះបន្ទាប់ពីធ្វើការចុះបញ្ជីម៉ាករួច ម្ចាស់ម៉ាកអាចទាមទារការខាតបង់ទាំងឡាយដែលកើតចេញពីការក្លែងបន្លំម៉ាក។ បន្ទាប់ពីបានចុះបញ្ជីម៉ាករួចហើយ ម្ចាស់ម៉ាកនឹងទទួលបានសិទ្ធិប្រើប្រាស់ ម៉ាករបស់ខ្លួន សិទ្ធិអាស្រ័យផល សិទ្ធិចាត់ចែង និងសិទ្ធិទទួលបានការការពារ ក្រៅពីនេះម្ចាស់នៃម៉ាកក៏ទទួលបាននូវសិទ្ធិផ្តាច់មុខចំពោះមុខម៉ាករបស់ខ្លួនផងដែរ ដូចជាផ្ទេរសិទ្ធិលើម៉ាក ឲ្យទៅតតិយជនតាមកិច្ចសន្យាអនុប្បទាន សិទ្ធិចុះបញ្ជីសារជាថ្មី និងសិទ្ធិធ្វើបណ្តឹងតាមផ្លូវច្បាប់ចំពោះជន ដែលមានចេតនាលួចក្លែងបន្លំម៉ាកដែលបានចុះបញ្ជីរួច ប្រើប្រាស់ធ្វើជារបស់ខ្លួន ឬដើម្បីប្រយោជន៍ផ្ទាល់ខ្លួន ដោយគ្មានការអនុញ្ញាតពីម្ចាស់ដើមនៃម៉ាកនោះ។

សរុបជារួមមកបន្ទាប់ពី **ការចុះបញ្ជីម៉ាក** អាចកើតសិទ្ធិស្របច្បាប់ចំពោះម្ចាស់ម៉ាក ឲ្យទទួលបានការការពារពីការលួចបន្លំម៉ាកពីសំណាក់ជនខិលខូច ធានាបាននូវសុវត្ថិភាព និងប្រសិទ្ធិភាពក្នុងការការពារប្រឆាំងទៅនឹងការរំលោភបំពានលើម៉ាករបស់ខ្លួន។ ដោយផ្អែកទៅលើកំណើននៃការក្លែងបន្លំម៉ាក ដែលកំពុងតែកើតមានឡើងនៅក្នុងសង្គមសព្វថ្ងៃ បានជះឥទ្ធិពលជាខ្លាំងដល់ម្ចាស់ម៉ាកពិតប្រាកដ ឬអាជីវករមួយចំនួនដែលមិនទាន់បានយល់ដឹងច្បាស់ អំពីផលប្រយោជន៍ដែលពួកគាត់ទទួលបានពីការចុះបញ្ជីម៉ាក។ ដោយសារតែហេតុផលទាំងអស់នេះ ទើបបណ្តាលឲ្យមានបញ្ហាជាច្រើនកើតមានឡើងនៅក្នុងសង្គម ដើម្បីបញ្ចៀសនូវរាល់បញ្ហាទាំងអស់នេះ ម្ចាស់ម៉ាកទាំងអស់គួគប្បី យកម៉ាករបស់ខ្លួនទៅចុះបញ្ជីឲ្យបានត្រឹមត្រូវ។ ហើយការចុះបញ្ជីមិនត្រឹមតែជួយការពារ និងរក្សាសិទ្ធិរបស់ម្ចាស់ម៉ាកប៉ុណ្ណោះទេ វាថែមទាំងជួយលើក ស្ទួយកំណើនសេដ្ឋកិច្ចរួមទាំងការអភិវឌ្ឍន៍ក្នុងវិស័យ សេដ្ឋកិច្ច ឧស្សាហកម្ម សេវាកម្ម ពាណិជ្ជកម្ម និងវិស័យពាក់ព័ន្ធផ្សេងៗទៀតថែមទៀតផង។

# អនុសាសន៍

ដោយសារបច្ចុប្បន្ននៅព្រះរាជាណាចក្រកម្ពុជាយើង មានភាពរីកចម្រើនលើគ្រប់វិស័យ ជាពិសេសសេដ្ឋកិច្ច បានទាក់ទាញភ្ញៀវទេសចរណ៍ ក៏ដូចជាអ្នកវិនិយោគទន់ជាច្រើន ទាំងក្នុងស្រុក និងក្រៅស្រុកឲ្យមកចូលរួមប្រកួតប្រជែង និងនាំចូលមុខទំនិញរបស់ខ្លួន ឬសេវាកម្មជាច្រើនប្រភេទ មកចរាចរណ៍លើទីផ្សា។ ដោយសារតែមានការចរាចរណ៍ទំនិញជាច្រើនប្រភេទបែបនេះហើយ ទើបម្ចាស់មុខទំនិញនីមួយៗ បានដាក់ឈ្មោះ ឬសញ្ញា សម្គាល់ណាមួយ ដែលយើងឲ្យឈ្មោះថា ម៉ាក ដើម្បីសម្គាល់លក្ខណៈទំនិញរបស់ខ្លួនកុំឲ្យមានការភ័ន្តច្រឡំ។ ទន្ទឹមនឹងនេះដែរក៏មានទំនិញមួយចំនួនដែលបានក្លែងបន្លំម៉ាកមកធ្វើការចរាចរណ៍លើទីផ្សាដូចគ្នាដែរ ដែលធ្វើឲ្យប៉ះពាល់ និងខាតបង់ផលប្រយោជន៍ច្រើនដល់ម្ចាស់ម៉ាកពិតប្រាកដ ជាពិសេសនៅពេលម្ចាស់ម៉ាកមិនបានយកម៉ាករបស់ខ្លួនទៅចុះបញ្ជី។

ដើម្បីជៀសវាងរាល់បញ្ហាខាងលើគ្រប់ម្ចាស់ម៉ាកទាំងអស់ ត្រូវតែយកម៉ាករបស់ខ្លួនទៅចុះបញ្ជីនៅនាយកដ្ឋានកម្មសិទ្ធិបញ្ញាឲ្យបានរួចរាល់ ទើបម៉ាករបស់ខ្លួនទទួលបានការការពារយ៉ាងស្របច្បាប់នៅពេលដែលមានការរំលោភបំពានណាមួយបានកើតឡើងលើម៉ាករបស់ខ្លួន។ ម្យ៉ាងទៀតគ្រប់ទំនិញនៅលើទីផ្សាមានផលិតផលក្លែងបន្លំម៉ាក និងមានម៉ាកមួយចំនួនប្រហាក់ប្រហែលគ្នា ឬស្ទើតែដូចគ្នាជាច្រើន ដែលវាធ្វើឲ្យមជ្ឈដ្ឋានពាណិជ្ជកម្ម ឬសាធារណៈជនមានការភ័ន្តច្រឡំ និងជាពិសេសអាចបង្កផលប៉ះពាល់យ៉ាងខ្លាំងដល់សុខភាពអ្នកប្រើប្រាស់ នៅពេលដែលពួកគេទិញចំផលិតផលក្លែងក្លាយដូច្នេះគប្បី៖

- រដ្ឋាភិបាលរួមទាំងមន្ត្រីចុះបញ្ជីម៉ាក ឬក្រសួងដែលពាក់ព័ន្ធគួតែពង្រឹងអំពីវិសាលភាពនៃការផ្សព្វផ្សាយច្បាប់ដែលទាក់ទងទៅនឹងការចុះបញ្ជីម៉ាក រួមទាំងការអប់រំ ពន្យល់ណែនាំពីនីតិវិធីក្នុងការចុះបញ្ជី និងផលប្រយោជន៍ដែលកើតមានឡើងក្រោយពេលចុះបញ្ជីឲ្យទូលំទូលាយ។
- ក្រសួងគួតែមានវគ្គបណ្ដុះបណ្ដាលមន្ត្រីផ្នែកម៉ាក ឲ្យបានកាន់តែច្រើនផងដែរ ដែលជាហេតុធ្វើឲ្យមានភាពងាយស្រួល ក្នុងការស្វែងរកពត៌មានផ្សេងៗដែរទាក់ទងទៅនឹងការចុះបញ្ជី។
- ណែនាំឲ្យម្ចាស់ម៉ាក ត្រូវតែយកម៉ាករបស់ខ្លួនមកចុះបញ្ជីឲ្យបានរួចរាល់ មុននឹងយកម៉ាករបស់ខ្លួនធ្វើចរាចរណ៍លើទីផ្សារ ដើម្បីជៀសវាងការខាតបង់ផលប្រយោជន៍នានា។
- ទន្ទឹមនឹងនេះផងដែរ រដ្ឋាភិបាលគួតែលើទឹកចិត្តចំពោះអ្នកដែលបានមកចុះបញ្ជីត្រឹមត្រូវ តាមផ្លូវច្បាប់ និងលើកទឹកចិត្តប្រជាពលរដ្ឋឲ្យងាកមកគាំទ្រនូវផលិតផល ដែលបានចុះបញ្ជីយ៉ាងត្រឹមត្រូវ និងទទួលស្គាល់ដោយច្បាប់ ដែលជាហេតុធ្វើឲ្យម្ចាស់ម៉ាកនីមួយៗ យកចិត្តទុកដាក់ក្នុងការយកម៉ាករបស់ខ្លួនមកចុះបញ្ជី។

# ឯកសារយោង

❖ **ច្បាប់ជាតិ**

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- ច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើប្រពើកូតប្រជែងមិនស្មោះត្រង់ ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០២
- ច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៣

❖ **សន្ធិសញ្ញាកម្មសិទ្ធិបញ្ញាអន្តរជាតិ**

- ARISE + IPR សហការជាមួយនាយកដ្ឋានកម្មសិទ្ធិបញ្ញា, ពីធីសាទីក្រុងម៉ាឌ្រីដ ខែធ្នូ ឆ្នាំ២០១៤
- អនុសញ្ញាទីក្រុងប៉ារីសស្តីពី កិច្ចការពារសិទ្ធិឧស្សាហកម្ម ថ្ងៃទី២០ ខែមីនា ឆ្នាំ១៨៨៣
- អនុសញ្ញាទីក្រុង ហ្សឺណែវ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ១៩០៦
- កិច្ចព្រមព្រៀង ស្តីពីទិដ្ឋភាពពាណិជ្ជកម្ម ទាក់ទងនឹងកម្មសិទ្ធិបញ្ញា ឆ្នាំ១៩៩៤
- អនុសាសន៍រួមទាក់ទងនឹងបទប្បញ្ញាត្តិស្តីពីកិច្ចការពារម៉ាកល្បី ឆ្នាំ១៩៩៩

❖ **អនុក្រឹត្យ**

- អនុក្រឹត្យស្តីពី ការអនុវត្តច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើប្រកួតប្រជែងមិនស្មោះត្រង់ ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០៦
- អនុក្រឹត្យស្តីពី ការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា ចុះថ្ងៃទី២២ ខែកុម្ភៈ ១៩៩៩

❖ **ប្រកាស**

- ប្រកាសរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល លេខ១១២ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៤ ស្តីពីសញ្ញាសម្គាល់ឧស្សាហកម្មកម្ពុជា។
- ប្រកាសរបស់អន្តរក្រសួងស្តីពី តម្លៃរដ្ឋបាលក្នុងការចុះបញ្ជីម៉ាក និងកម្រៃរដ្ឋបាលពាក់ព័ន្ធនានា ឆ្នាំ២០០៧។
- ប្រកាសលេខ០៤៥ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១១ ស្តីពី "ភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាកក្នុងព្រះរាជាណាចក្រកម្ពុជា"។
- ប្រកាស ស្តីពី នីតិវិធីចុះបញ្ជីម៉ាកក្នុងក្របខ័ណ្ឌអន្តរជាតិ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៦
- ប្រកាសលេខ១២៥ ព.ណ កសប ស្តីពី នីតិវិធីនៃការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកតាមប្រព័ន្ធអេឡិចត្រូនិក ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៧

- ប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញា ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៤
- ប្រកាសរួមលេខ ១២១៧ សហវ.ប្រក ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៧

❖ **សារាចរ**

- សារាចរណែនាំស្តីពីការទទួលស្គាល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៥

❖ **សេចក្តីជូនដំណឹង និងសេចក្តីណែនាំ**

- សេចក្តីជូនដំណឹង អំពីកម្រៃសេវាការចុះបញ្ជីម៉ាក ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៥
- សេចក្តីជូនដំណឹង របស់ក្រសួងពាណិជ្ជកម្ម ស្តីពីលក្ខខណ្ឌនៃពាក្យស្នើសុំចុះម៉ាកថ្មី ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៥
- សេចក្តីជូនដំណឹងស្តីពី ការទទួលចុះបញ្ជីម៉ាកសមូហភាព ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៥

❖ **សៀវភៅដែលបានបោះពុម្ពផ្សាយ**

- សៀវភៅ នីតិកម្មសិទ្ធិបញ្ញា របស់លោក កាន់ សុទ្ធប៉ូលីន បោះពុម្ពលើកទី២ ឆ្នាំ២០១៤
- សៀវភៅ នីតិកម្មសិទ្ធិបញ្ញាកម្ពុជា, លោក នី វិចិត្រ, បោះពុម្ពលើកទី១ ឆ្នាំ២០១៣
- សៀវភៅ សារណាបញ្ចប់ការសិក្សា នីតិវិធីនៃការចុះបញ្ជី និងការដោះស្រាយវិវាទស្តីពីម៉ាក របស់លោក ប៉ែន វីរៈឧត្តម និងលោក ផន សុគន្ធា ឆ្នាំ២០១៣
- សារណាបញ្ចប់ការសិក្សា កិច្ចការពារម៉ាក និងយន្តការដោះស្រាយវិវាទម៉ាកនៅកម្ពុជា ស្រាវជ្រាវដោយ ប៉ាត ណារី និង ឆាយ សុភាព ជំនាន់ទី១៣ ឆ្នាំ២០១៣

❖ **គេហទំព័រ**

- គេហទំព័រ http://www.service.gov.kh/service/101433
- គេហទំព័រ www.wipo.int/branddb/kh/en
- គេហទំព័រ www.cambodiaip.gov.kh/tmsearch

❖ **ឯកសារពិគ្រោះផ្សេងៗ**

- សម្តីរបស់លោក ប៉ាន សូរស័ក្តិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧
- បទបង្ហាញរបស់លោក តា ប៊ុនរិទ្ធ ប្រធានការិយាល័យចុះបញ្ជីម៉ាក នាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្ម។

# តារាងឧបសម្ព័ន្ធ

| ល.រ | ឈ្មោះឯកសារ |
|---|---|
| ១ | ច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើប្រពើកូតប្រជែងមិនស្មោះត្រង់ ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០២ |
| ២ | អនុក្រឹត្យស្តីពី ការអនុវត្តច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើប្រកួតប្រជែងមិនស្មោះត្រង់ ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០៦ |
| ៣ | ប្រកាសរួមលេខ ១២១៧ សហវ.ប្រក ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៧ |
| ៤ | លិខិតប្រើសម្រាប់នីតិវិធីនៃការចុះបញ្ជីម៉ាក |
| ៥ | វិញ្ញាបនបត្រចុះបញ្ជីម៉ាកចេញដោយក្រសួងពាណិជ្ជកម្ម |

# ច្បាប់

# ស្តីពី

# ម៉ាក ពាណិជ្ជនាម និងអំពើ

# នៃការប្រកួតប្រជែងមិនស្មោះត្រង់

# ព្រះរាជក្រម

នស/រកម/០២០២/០០៦

## យើង
## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស /រកត /១១៩៨ /៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គ លើកទី ៧ នីតិកាលទី ២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី ០៨ខែមករា ឆ្នាំ ២០០២ នាសម័យប្រជុំពេញអង្គ លើកទី ៦ នីតិកាលទី ១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ:

# ច្បាប់
# ស្ដីពី
# ម៉ាក ពាណិជ្ជនាម និងអំពើ
# នៃការប្រកួតប្រជែងមិនស្មោះត្រង់

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលបំណងការពារម៉ាក ពាណិជ្ជនាម ដែលបានចុះបញ្ជីក្នុងបញ្ជីម៉ាក នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងប្រឆាំងការប្រកួតប្រជែងមិនស្មោះត្រង់ លើការបង្កើត ការប្រើប្រាស់ម៉ាក និងពាណិជ្ជនាម ។

**មាត្រា ២.-**

ក- ម៉ាក គឺជាសញ្ញាដែលមើលឃើញ ហើយអាចសំគាល់លក្ខណៈខុសគ្នានៃទំនិញ ឬសេវានៃសហគ្រាសនីមួយៗ ។ ម៉ាកដែលប្រើប្រាស់សំរាប់ទំនិញហៅថាពាណិជ្ជសញ្ញា ហើយម៉ាកដែលប្រើប្រាស់ សំរាប់សេវាហៅថា សេវាសញ្ញា ។

ខ- ម៉ាកសមូហភាព គឺជាសញ្ញាដែលមើលឃើញ សំដៅប្រើក្នុងការដាក់ពាក្យសុំចុះបញ្ជី ហើយអាចសំគាល់នូវប្រភពដើមនៃទំនិញឬសេវា ឬសំគាល់នូវចរិតលក្ខណៈរួមដទៃទៀត គិតទាំងគុណភាពនៃទំនិញ ឬសេវា របស់សហគ្រាសផ្សេងៗគ្នា ដែលប្រើសញ្ញានោះ ក្រោមការគ្រប់គ្រងរបស់ម្ចាស់ម៉ាកសមូហភាពដែលបានចុះបញ្ជី ។

គ- ពាណិជ្ជនាម គឺជាឈ្មោះ ឬសញ្ញាសំគាល់ ឬជាឈ្មោះ និងសញ្ញាសំគាល់ សំរាប់បញ្ជាក់ និងសំគាល់លក្ខណៈខុសៗគ្នានៃសហគ្រាសនីមួយៗ ។

**មាត្រា ៣.-**

សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក ត្រូវបានទទួលស្គាល់តាមរយៈការចុះបញ្ជី ដោយអនុលោមតាមបទប្បញ្ញត្តិទាំងឡាយនៃច្បាប់នេះ ។

**មាត្រា ៤.-**

ម៉ាកដែលមិនអាចចុះបញ្ជីបានមានដូចតទៅ :

ក- ម៉ាកដែលមិនអាចសំគាល់លក្ខណៈខុសគ្នានៃទំនិញ ឬសេវា របស់សហគ្រាសមួយទៅនឹងសហគ្រាសមួយផ្សេងទៀត ។

ខ- ម៉ាកដែលបណ្តាលឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ សីលធម៌ ឬប្រពៃណីល្អរបស់ជាតិ ។

គ- ម៉ាកដែលអាចនាំឱ្យសាធារណជន ឬមជ្ឈដ្ឋាន ពាណិជ្ជកម្មភ័ន្តច្រឡំទៅនឹងប្រភពភូមិសាស្ត្រនៃទំនិញ ឬសេវាពាក់ព័ន្ធ ឬធាតុដើម ឬលក្ខណៈខាងក្រៅរបស់ទំនិញ ឬសេវានោះ ។

ឃ- ម៉ាកដែលដូចគ្នានិង/ឬត្រាប់តាម ឬមានចំណុចណាមួយដូច សញ្ញាជាតិ ទង់ជាតិ និងនិមិត្តរូបផ្សេងៗ ឈ្មោះ ឬឈ្មោះសង្ខេប ឬអក្សរកាត់នៃឈ្មោះ ឬសញ្ញា ឬត្រាផ្លូវការ ដែលអនុម័តដោយរដ្ឋណាមួយ អង្គការអន្តររដ្ឋាភិបាល ឬអង្គការដែលបង្កើតដោយអនុសញ្ញាអន្តរជាតិមួយ លើកលែងតែមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច នៃរដ្ឋនោះ ឬអង្គការនោះ ។

ង- ម៉ាកដែលដូចគ្នា ឬប្រហាក់ប្រហែល ដែលនាំឱ្យច្រឡំគ្នានឹងម៉ាក ឬពាណិជ្ជនាមមួយដែលល្បីក្នុងព្រះរាជាណាចក្រកម្ពុជា ឬបង្កើតពីការបកប្រែនៃម៉ាក ឬពាណិជ្ជនាមដែលល្បីនោះ សំរាប់ទំនិញ ឬសេវាដូចគ្នា ឬប្រហាក់ប្រហែលគ្នានៃសហគ្រាសមួយទៀត ។

ច- ម៉ាកដែលដូចគ្នា ឬប្រហាក់ប្រហែល ដែលនាំឱ្យច្រឡំគ្នានឹងម៉ាក ឬពាណិជ្ជនាមមួយដែលល្បី ឬបង្កើតពីការបកប្រែនៃម៉ាក ឬពាណិជ្ជនាមដែលល្បីនោះ ហើយដែលបានចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា សម្រាប់ទំនិញ ឬសេវាដែលមិនដូចគ្នា ឬមិនប្រហាក់ប្រហែលគ្នា ដោយការប្រើប្រាស់ម៉ាកនោះធ្វើឱ្យខូចប្រយោជន៍របស់ម្ចាស់នៃម៉ាកល្បី ។

ឆ- ម៉ាកដែលដូចគ្នា ឬស្ទើរតែដូចគ្នាទាំងស្រុងទៅនឹងម៉ាក ដែលជាកម្មសិទ្ធិរបស់ម្ចាស់ផ្សេង ដែលបានចុះបញ្ជីរួចហើយ ឬបានដាក់ពាក្យស្នើសុំចុះបញ្ជីមុន ឬបានទទួលអាទិភាពចុះបញ្ជីមុន នៅឯបរទេស ចំពោះទំនិញ ឬសេវាដូចគ្នា ឬទំនិញ ឬសេវា ដែលពាក់ព័ន្ធគ្នាយ៉ាងជិតស្និទ្ធ ។

## ជំពូកទី ២
## ការចុះបញ្ជី និងសិទ្ធិដែលកើតឡើងពីការចុះបញ្ជីម៉ាក

**មាត្រា ៥.-**

បែបបទនៃការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក ការសុំប្តូរអាស័យដ្ឋាននៃម្ចាស់ម៉ាក និងការបញ្ជាក់ឡើងវិញនូវការប្រើប្រាស់ ឬមិនបានប្រើប្រាស់ម៉ាក ត្រូវបានកំណត់ដូចខាងក្រោម :

ក- ការស្នើសុំចុះបញ្ជីម៉ាក ការសុំប្តូរអាស័យដ្ឋាននៃម្ចាស់ម៉ាក និងការបញ្ជាក់ឡើងវិញនូវការប្រើប្រាស់ ឬមិនបានប្រើប្រាស់ម៉ាក ត្រូវធ្វើនៅក្រសួងពាណិជ្ជកម្ម ។

ពាក្យស្នើសុំត្រូវភ្ជាប់ :

- គំរូម៉ាក
- បញ្ជីទំនិញ ឬសេវាដែលត្រូវចុះបញ្ជី ដោយរាយលំអិត តាមក្រុមមុខទំនិញ ទៅតាមចំណាត់ថ្នាក់អន្តរជាតិ ដូចមានក្នុងឧបសម្ព័ន្ធ ។

ខ- ការសុំចុះបញ្ជីម៉ាក ការសុំប្តូរអាស័យដ្ឋាននៃម្ចាស់ម៉ាក និងការបញ្ជាក់ឡើងវិញនូវការប្រើប្រាស់ ឬមិនបានប្រើប្រាស់ម៉ាក ត្រូវបង់កម្រៃតាមការកំណត់នៅក្នុងសេចក្តីប្រកាសរួមរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម ។

**មាត្រា ៦.-**

សិទ្ធិអាទិភាពក្នុងការចុះបញ្ជីម៉ាក ត្រូវបានផ្តល់តាមលក្ខខណ្ឌ ដូចខាងក្រោម :

ក- អ្នកស្នើសុំចុះបញ្ជីអាចស្នើសុំអាទិភាព នៃការចុះបញ្ជី ដោយអមមកជាមួយនូវប្រកាសស្តីពីអាទិភាពដែលខ្លួនមានតាមរយៈការស្នើសុំចុះបញ្ជីនៅប្រទេសណាមួយ ដែលជាសមាជិកនៃអនុសញ្ញាក្រុងប៉ារីស ។

ខ- តម្លៃនៃប្រកាសស្តីពីអាទិភាពខាងលើ ត្រូវតែស្របទៅតាមលក្ខខណ្ឌ ដែលមានចែងនៅក្នុងអនុសញ្ញាទីក្រុងប៉ារីស ។

**មាត្រា ៧.-**

អ្នកស្នើសុំចុះបញ្ជីអាចដកពាក្យស្នើសុំរបស់ខ្លួននៅពេលណាក៏បាន ។

## មាត្រា ៨.-

ក្រោយពេលទទួលពាក្យស្នើសុំចុះបញ្ជី មន្ត្រីកាន់កាប់បញ្ជីត្រូវ :

ក- ពិនិត្យមើលពាក្យស្នើសុំនោះឱ្យបានត្រឹមត្រូវតាមលក្ខខណ្ឌនៃមាត្រា ៥ និងបទបញ្ជាដែលជាប់ទាក់ទង ។

ខ- ពិនិត្យ និងកំណត់ថា ម៉ាកនោះគឺជាម៉ាកស្របតាមលក្ខខណ្ឌដូចមានចែងនៅក្នុងមាត្រា ២ ចំណុច ក និងមិនអាចចុះបញ្ជីបាន តាមមាត្រា ៤ ដោយលើកលែងតែចំណុច ឆ នៃមាត្រា ៤ នេះចេញ ។

## មាត្រា ៩.-

អាទិភាពនៃការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក ត្រូវបានកំណត់ដូចតទៅ :

ក- កាលណាមានពាក្យស្នើសុំចុះបញ្ជីច្រើន ទាក់ទងនឹងម៉ាកដែលដូច ឬប្រហាក់ប្រហែលគ្នា ដែលត្រូវបានប្រើចំពោះទំនិញ ឬសេវាដូច ឬប្រហាក់ប្រហែលគ្នា ហើយបានដាក់ពាក្យស្នើសុំតាមពេលវេលាខុសគ្នា មន្ត្រីកាន់កាប់បញ្ជីអាចបដិសេធការចុះបញ្ជីម៉ាកណាមួយនៃម៉ាកទាំងនោះ រហូតដល់ពេលដែលសិទ្ធិនៃអ្នកស្នើសុំទាំងនោះ ត្រូវបានកំណត់ដោយមន្ត្រីកាន់កាប់បញ្ជី ឬត្រូវបានដោះស្រាយដោយការព្រមព្រៀងគ្នា និងមានការយល់ព្រមពីមន្ត្រីកាន់កាប់បញ្ជី ។

ខ- កាលណាមានពាក្យស្នើសុំចុះបញ្ជីច្រើន ទាក់ទងនឹងម៉ាកដែលដូច ឬប្រហាក់ប្រហែលគ្នាដែលត្រូវបានប្រើចំពោះទំនិញ ឬសេវាដូច ឬប្រហាក់ប្រហែលគ្នា ហើយបានដាក់ពាក្យស្នើសុំក្នុងពេលជាមួយគ្នា ក្រោយពីការពិគ្រោះឯកភាពគ្នាទៅវិញទៅមក ក្នុងចំណោមអ្នកស្នើសុំទាំងអស់មានអ្នកស្នើសុំតែម្នាក់គត់ដែលអាចទទួលបាននូវការចុះបញ្ជីម៉ាក ។

## មាត្រា ១០.-

សិទ្ធិរបស់មន្ត្រីកាន់កាប់បញ្ជី ក្នុងការចុះបញ្ជីម៉ាកមានដូចខាងក្រោម :

ក- ក្នុងករណីដែលមន្ត្រីកាន់កាប់បញ្ជីរកឃើញថា លក្ខខណ្ឌទាំងឡាយ ដែលមានចែងក្នុងមាត្រា ៨ និងមាត្រា ៩ បានត្រូវបំពេញ មន្ត្រីកាន់កាប់បញ្ជីត្រូវចុះបញ្ជីម៉ាក ចេញវិញ្ញាបនប័ត្រនៃការចុះបញ្ជីជូនអ្នកស្នើសុំ និងចុះផ្សាយក្នុងព្រឹត្តិប័ត្រផ្លូវការរបស់ក្រសួងពាណិជ្ជកម្ម ។

ខ- ពាក្យស្នើសុំចុះបញ្ជី ដែលមិនបានសមស្របតាមមាត្រា ៨ អ្នកស្នើសុំចុះបញ្ជី អាចកែតម្រូវក្នុងរយៈពេល ៤៥ (សែសិបប្រាំ) ថ្ងៃ បន្ទាប់ពីថ្ងៃជូនដំណឹងជាលាយលក្ខណ៍អក្សររបស់មន្ត្រីកាន់កាប់

បញ្ជី ។ ក្នុងករណីគ្មានការកែតម្រូវពាក្យស្នើសុំពីអ្នកសុំចុះបញ្ជីតាមកាលកំណត់ មន្ត្រីកាន់កាប់បញ្ជីមានសិទ្ធិបដិសេធការចុះបញ្ជីម៉ាកនោះ ។

គ- ក្នុងរង្វង់ ៩០ (កៅសិប) ថ្ងៃ បន្ទាប់ពីបានចុះផ្សាយ ក្នុងព្រឹត្តិប័ត្រផ្លូវការហើយ ជនណាដែលមានការពាក់ព័ន្ធ អាចជូនដំណឹងទៅមន្ត្រីកាន់កាប់បញ្ជីពីការជំទាស់របស់ខ្លួន ចំពោះការចុះបញ្ជីម៉ាកតាមបែបបទដែលបានកំណត់ ដោយឈរលើមូលដ្ឋាននៃការមិនបានបំពេញតាមលក្ខខណ្ឌណាមួយនៃមាត្រា ២ ចំណុច ក មាត្រា ៤ និង មាត្រា ៥ និងបទបញ្ញាទាំងឡាយដែលពាក់ព័ន្ធ ។

ឃ- មន្ត្រីកាន់កាប់បញ្ជីត្រូវបញ្ជូនជាបន្ទាន់ នូវសេចក្តីជូនដំណឹងនោះ មួយច្បាប់ ទៅអ្នកសុំចុះបញ្ជីតាមពេលវេលា និងបែបបទ ដែលបានកំណត់ ។ បន្ទាប់មក អ្នកស្នើសុំចុះបញ្ជីត្រូវបញ្ជូនទៅមន្ត្រីកាន់កាប់បញ្ជីនូវចម្លើយបញ្ជាក់ អំពីមូលដ្ឋានបង្អែកទាំងឡាយសម្រាប់ការចុះបញ្ជីរបស់ខ្លួន ។ ប្រសិនបើមិនបានឆ្លើយតបទេ ម្ចាស់ម៉ាកនោះ ត្រូវចាត់ទុកថា បានបោះបង់ចោលការចុះបញ្ជីរបស់ខ្លួន ។

ង- ប្រសិនបើអ្នកសុំចុះបញ្ជីធ្វើពាក្យជំទាស់ មន្ត្រីកាន់កាប់បញ្ជីត្រូវផ្តល់ចម្លើយមួយច្បាប់ទៅអ្នកដែលបានប្តឹងជំទាស់ ។ ប្រសិនបើភាគីម្ខាង ឬភាគីទាំងសងខាង មានបំណងចង់ឱ្យមានសវនាការ មន្ត្រីកាន់កាប់បញ្ជីត្រូវរៀបចំឱ្យមានសវនាការនោះ ។ បន្ទាប់ពីបានស្តាប់ភាគីទាំងសងខាង និងពិចារណាលើពាក្យតវ៉ា មន្ត្រីកាន់កាប់បញ្ជីត្រូវសម្រេចថា ម៉ាកដែលបានចុះបញ្ជីនេះ ត្រូវរក្សាទុក ឬបដិសេធ ។

## មាត្រា ១១.-

សិទ្ធិដែលទទួលបានតាមរយៈការចុះបញ្ជីម៉ាក មានដូចខាងក្រោម :

ក- ចំពោះម៉ាកដែលទាក់ទងនឹងទំនិញ ឬសេវា ដែលបានចុះបញ្ជីរួចហើយ ការប្រើប្រាស់ម៉ាកនោះដោយជនណាមួយក្រៅពីម្ចាស់ដើម ត្រូវមានការយល់ព្រមពីម្ចាស់ដើមជាមុនសិន ។

ខ- ម្ចាស់ដើមនៃម៉ាកមានសិទ្ធិប្តឹងទៅតុលាការ ប្រឆាំងនឹងជនណាម្នាក់ ដែលប្រើប្រាស់ដោយរំលោភនូវម៉ាករបស់ខ្លួន ដោយគ្មានការយល់ព្រមពីម្ចាស់ដើម ។ ម្ចាស់ដើមក៏មានសិទ្ធិប្តឹងផងដែរ ចំពោះការប្រើប្រាស់នូវសញ្ញា ដែលប្រហាក់ប្រហែលនឹងម៉ាកដែលខ្លួនបានចុះបញ្ជី រួចហើយ និងការប្រើប្រាស់ម៉ាកដែលទាក់ទិនទៅនឹងទំនិញ និងសេវា ដែលប្រហាក់ប្រហែលទៅនឹងទំនិញ ឬសេវានៃម៉ាកដែលចុះបញ្ជីរួចហើយ នោះហើយដែលអាចបណ្តាលឱ្យមានការភាន់ច្រឡំជាសាធារណៈ ។

គ- សិទ្ធិដែលទទួលបានតាមរយៈការចុះបញ្ជី ម៉ាកនឹងមិនរាប់បញ្ចូលនូវការដាក់លក់ទំនិញនៅលើទីផ្សារ ក្នុងព្រះរាជាណាចក្រកម្ពុជា ដោយម្ចាស់ដែលបានចុះបញ្ជី ឬដោយមានការយល់ព្រមពីម្ចាស់ម៉ាកនោះទេ ។

**មាត្រា ១២.-**

សុពលភាពក្នុងការចុះបញ្ជីម៉ាក និងការចុះបញ្ជីសាជាថ្មី ត្រូវបានកំណត់តាមលក្ខខណ្ឌដូចខាងក្រោម :

ក- ម៉ាកដែលបានចុះបញ្ជីហើយ មានសុពលភាព ១០ (ដប់) ឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃការទទួលពាក្យស្នើសុំចុះបញ្ជី ។

ខ- តាមការស្នើសុំ ការចុះបញ្ជីម៉ាកមួយ អាចធ្វើឡើងសាជាថ្មីសំរាប់រយៈពេល ១០ (ដប់) ឆ្នាំម្តងជាបន្តបន្ទាប់ ក្នុងលក្ខខណ្ឌដែលម្ចាស់ដើមបង់អាករចុះបញ្ជីជាថ្មីតាមការកំណត់ ។

គ- ក្នុងការដាក់ពាក្យស្នើសុំចុះបញ្ជីសាជាថ្មីនូវម៉ាកដែលបានចុះបញ្ជីរួចហើយ មុនពេលដែលច្បាប់នេះចូលជាធរមាន អ្នកស្នើសុំត្រូវបញ្ជាក់ឱ្យបានច្បាស់នូវប្រភេទទំនិញ ឬសេវាដែលចង់បានការការពារ ដោយផ្អែកតាមចំណាត់ថ្នាក់អន្តរជាតិ ។

ឃ- ការអនុគ្រោះចំពោះការយឺតយ៉ាវ ក្នុងការចុះបញ្ជីសាជាថ្មី ត្រូវបានអនុញ្ញាតត្រឹមតែរយៈពេល ៦ (ប្រាំមួយ) ខែ ។

## ជំពូកទី ៣
## អាជ្ញាប័ណ្ណ និងការលុបម៉ាកចេញពីបញ្ជី

**មាត្រា ១៣.-**

មោឃភាព និងអានុភាពនៃមោឃភាពត្រូវបានកំណត់ដូចខាងក្រោម :

ក- ជនណាដែលមានការពាក់ព័ន្ធ អាចស្នើសុំមកក្រសួងពាណិជ្ជកម្មឱ្យផ្តល់មោឃភាពដល់ការចុះបញ្ជីម៉ាកបាន ។

ខ- ក្រសួងពាណិជ្ជកម្មត្រូវទុកការចុះបញ្ជីជាមោឃៈ ប្រសិនបើជនដែលស្នើសុំឱ្យមានមោឃភាពនោះបង្ហាញថាមានលក្ខខណ្ឌ ណាមួយនៃមាត្រា ២ ចំណុច ក និងមាត្រា ៤ មិនត្រូវបានបំពេញ ។

គ- មោឃភាពនៃការចុះបញ្ជីម៉ាក ត្រូវមានអានុភាព ចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជី ហើយត្រូវបានកត់ត្រា និងបោះពុម្ពផ្សាយជាបន្ទាន់ ។

**មាត្រា ១៤.-**

ក្រសួងពាណិជ្ជកម្មមានសិទ្ធិលុបចោលម៉ាកដែលបានចុះបញ្ជីរួចហើយក្នុងករណីដូចខាងក្រោម :

ក- អ្នកសុំចុះបញ្ជីមិនបានដាក់ពាក្យស្នើសុំចុះ បញ្ជីសាជាថ្មីនូវម៉ាក ដែលបានចុះបញ្ជីរួចហើយ តាមរយៈពេលដែលបានកំណត់ក្នុងមាត្រា ១២ ចំណុច ខ និងចំណុច ឃ ។

ខ- ម្ចាស់ម៉ាកដែលបានចុះបញ្ជីរួចហើយ ស្នើសុំលុប ។

គ- ក្នុងរយៈពេល ៩០ (កៅសិប) ថ្ងៃ ម្ចាស់ម៉ាកដែលបានចុះបញ្ជីរួចហើយ មិនគោរពលក្ខខណ្ឌនៃការផ្តល់ឯកសារគាំទ្រ ឬការកម្រិតដែលបានកំណត់នៅក្នុងមាត្រា ៨ ។

ឃ- ម្ចាស់ម៉ាកដែលបានចុះបញ្ជីរួចហើយ លែងមានអាស័យដ្ឋានទាក់ទងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ង- ជឿជាក់ដោយផ្អែកលើភ័ស្តុតាងថា ម្ចាស់ម៉ាកដែលបានចុះបញ្ជីរួច ហើយមិនមែនជាម្ចាស់ស្របច្បាប់ ។

ច- ជឿជាក់ថា ម៉ាកដែលបានចុះបញ្ជីរួចហើយ ប្រហាក់ប្រហែល ឬដូចគ្នាទៅនឹងម៉ាកល្បី ដែលជាកម្មសិទ្ធិរបស់ភាគីទីបី ។

**មាត្រា ១៥.-**

ម៉ាកដែលបានចុះបញ្ជីរួច ប៉ុន្តែមិនបានប្រើប្រាស់សោះក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ ត្រូវបានលុបចេញពីបញ្ជី។ ប្រសិនបើម្ចាស់ម៉ាក បង្ហាញថា កាលៈទេសៈពិសេសបានរារាំងការប្រើប្រាស់ម៉ាក ហើយគ្មានបំណងមិនប្រើ ឬបោះបង់ចោលម៉ាកនោះទេ ម៉ាកនោះនឹងមិនត្រូវបានលុបចេញពីបញ្ជីឡើយ ។ ជនណាដែលពាក់ព័ន្ធអាចស្នើសុំឱ្យក្រសួងពាណិជ្ជកម្ម លុបម៉ាកចេញពីបញ្ជី ១ (មួយ) ខែ មុនកាលបរិច្ឆេទ ៥ (ប្រាំ) ឆ្នាំ នៃការមិនបានប្រើប្រាស់ ឬក្រោយកាលបរិច្ឆេទនេះ ។

## ជំពូកទី ៤
## ម៉ាកសមូហភាព

**មាត្រា ១៦.-**

បទប្បញ្ញត្តិទាំងឡាយដែលមានចែងពីមាត្រា ៣ ដល់មាត្រា ១៥ ព្រមទាំងមាត្រា ១៧ និងមាត្រា ១៨ នៃច្បាប់នេះ ត្រូវអនុវត្ត ចំពោះម៉ាកសមូហភាព ។

**មាត្រា ១៧.-**

បែបបទនៃការចុះបញ្ជីម៉ាកសមូហភាព មានដូចតទៅ :

ក- ពាក្យស្នើសុំចុះបញ្ជីម៉ាកសមូហភាព ត្រូវបញ្ជាក់ថា ជាម៉ាកសមូហភាព និងត្រូវភ្ជាប់មកជាមួយនូវបទបញ្ជារួម ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ម៉ាកសមូហភាពនោះមួយច្បាប់ ។

ខ- ម្ចាស់ម៉ាកសមូហភាព ដែលបានចុះបញ្ជី ហើយត្រូវជូនដំណឹងទៅមន្ត្រីកាន់កាប់បញ្ជីអំពីការផ្លាស់ប្តូរទាំងឡាយតាមបទបញ្ជាដែលបានយោងក្នុងកថាខ័ណ្ឌ ក ។

**មាត្រា ១៨.-**

បន្ថែមលើខ្លឹមសារដូចមានចែងក្នុងមាត្រា ១៣ ចំណុច ក និងចំណុច ខ មន្ត្រីកាន់កាប់បញ្ជីត្រូវចាត់ទុកការចុះបញ្ជីម៉ាកសមូហភាពជាមោឃៈ ប្រសិនបើជនដែលទាមទារនូវមោឃភាពនោះបង្ហាញថា មានតែម្ចាស់ដែលបានចុះបញ្ជីម្នាក់ឯងប៉ុណ្ណោះ ដែលប្រើប្រាស់ម៉ាក ឬបង្ហាញថា ម្ចាស់ដែលបានចុះបញ្ជីប្រើប្រាស់ ឬអនុញ្ញាតឱ្យប្រើប្រាស់ រំលោភទៅនឹងបទបញ្ជារួម ដែលបានបញ្ញត្តិនៅក្នុងមាត្រា ១៧ ចំណុច ក ឬបង្ហាញថា ម្ចាស់ដែលបានចុះបញ្ជីអនុញ្ញាតឱ្យប្រើប្រាស់តាមរបៀបមួយដែលអាចបំភ័ន្តមជ្ឈដ្ឋានពាណិជ្ជកម្ម ឬសាធារណជន អំពីប្រភពដើម ឬលក្ខណៈរួមផ្សេងទៀតនៃទំនិញ ឬសេវាដែលពាក់ព័ន្ធ ។

## ជំពូកទី ៥
## ការផ្តល់អាជ្ញាប័ណ្ណចំពោះម៉ាក

**មាត្រា ១៩.-**

ការផ្តល់អាជ្ញាប័ណ្ណចំពោះម៉ាកត្រូវបានកំណត់ដូចខាងក្រោម :

ក- កិច្ចសន្យាអាជ្ញាប័ណ្ណណាមួយអំពីការចុះ បញ្ជីម៉ាក ឬពាក្យស្នើសុំទទួលស្គាល់កិច្ចសន្យាអាជ្ញាប័ណ្ណនោះ ត្រូវចែងអំពីការត្រួតពិនិត្យដោយមានប្រសិទ្ធភាព ពីសំណាក់អ្នកប្រគល់អាជ្ញាប័ណ្ណ ចំពោះគុណភាពទំនិញ ឬសេវារបស់អ្នកទទួលអាជ្ញាប័ណ្ណដែលម៉ាកនោះ ត្រូវបានប្រើប្រាស់ ។ ប្រសិនបើកិច្ចសន្យាអាជ្ញាប័ណ្ណមិនបានចែងអំពីការត្រួតពិនិត្យគុណភាពនោះ ឬប្រសិនបើការត្រួតពិនិត្យគុណភាពនោះមិនត្រូវបានអនុវត្ត ដោយមានប្រសិទ្ធភាពទេ កិច្ចសន្យាអាជ្ញាប័ណ្ណនោះនឹងត្រូវចាត់ទុកជាមិនបានការ ។

ខ- ការចុះបញ្ជីម៉ាកសមូហភាពមួយ ឬពាក្យស្នើសុំចុះបញ្ជីម៉ាកសមូហភាពនោះ មិនអាចជាកម្មវត្ថុនៃកិច្ចសន្យាអាជ្ញាប័ណ្ណបានឡើយ ។

## ជំពូកទី ៦
## ពាណិជ្ជនាម

**មាត្រា ២០.-**

នាម ឬសញ្ញាសំគាល់ មិនអាចត្រូវបានប្រើប្រាស់ជាពាណិជ្ជនាមឡើយ ប្រសិនបើសារជាតិ ឬការប្រើប្រាស់នាម ឬសញ្ញាសំគាល់ដែលបានកំណត់នោះ ប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ឬសីលធម៌ និងជាពិសេសអាចបំភ័ន្តដល់មជ្ឈដ្ឋានពាណិជ្ជកម្ម ឬសាធារណជន អំពីប្រភេទនៃសហគ្រាស ដែលកំណត់ដោយនាមនោះ ។

**មាត្រា ២១.-**

ការការពារ និងការរំលោភលើពាណិជ្ជនាម ត្រូវបានចែងដូចខាងក្រោម :

ក- ទោះជាច្បាប់ ឬបទបញ្ជាទាំងឡាយចែងអំពីកាតព្វកិច្ចក្នុងការចុះបញ្ជីពាណិជ្ជនាមក៏ដោយ ក៏នាមទាំងនោះត្រូវបានការពារ ប្រឆាំងនឹងទង្វើមិនស្របច្បាប់របស់ភាគីទីបី ទោះមុនការចុះបញ្ជី ឬគ្មានការចុះបញ្ជីក៏ដោយ ។

ខ- ការប្រើប្រាស់ពាណិជ្ជនាមជាបន្តបន្ទាប់ ដោយភាគីទីបី ទោះបីជាពាណិជ្ជនាម ឬម៉ាក ឬជាម៉ាកសមូហភាព ឬការប្រើប្រាស់ណាមួយ ដែលអាចធ្វើឱ្យសាធារណជនភ័ន្តច្រឡំ ត្រូវចាត់ទុកថាមិនស្របច្បាប់ ។

## ជំពូកទី ៧
## អំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់

**មាត្រា ២២.-**

អំពើនៃការប្រកួតប្រជែងណា ដែលផ្ទុយពីគោលការណ៍នៃការអនុវត្តន៍ទៀងត្រង់នៅក្នុងវិស័យឧស្សាហកម្ម ពាណិជ្ជកម្ម សេវាកម្ម ត្រូវចាត់ទុកថា ជាការប្រកួតប្រជែងមិនស្មោះត្រង់ ។

**មាត្រា ២៣.-**

ទង្វើទាំងឡាយដូចខាងក្រោម ត្រូវចាត់ទុកថា បានបង្កើតនូវអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ :

ក- ការបង្កើតឱ្យមានការភ័ន្តច្រឡំតាមមធ្យោបាយណាមួយ ជាមួយសហគ្រាស ជាមួយទំនិញ ឬជាមួយសកម្មភាពឧស្សាហកម្ម ពាណិជ្ជកម្ម ឬសេវាកម្មនៃគូប្រកួតប្រជែង ។

ខ- ការពោលអះអាងមិនត្រឹមត្រូវក្នុងពាណិជ្ជកម្ម ដែលធ្វើឱ្យខូចកេរ្តិ៍ឈ្មោះ សហគ្រាស ទំនិញ ឬ សកម្មភាពឧស្សាហកម្ម ពាណិជ្ជកម្ម ឬសេវាកម្មនៃគូប្រកួតប្រជែង ។

គ- ការបញ្ជាក់ ឬការពោលអះអាងដែលបានប្រើប្រាស់នៅក្នុងពាណិជ្ជកម្ម ហើយដែលអាចធ្វើឱ្យសាធារណជនភ័ន្តច្រឡំ អំពីប្រភេទ ដំណើរការផលិត លក្ខណៈ ភាពសមស្រប សំរាប់គោលបំណងរបស់គេ ឬបរិមាណនៃទំនិញ ។

# ជំពូកទី ៨
# ការរំលោភ និងវិធានការដោះស្រាយ

**មាត្រា ២៤.-**

ដោយផ្អែកតាមមាត្រា ១២ ខាងលើ ការរំលោភលើម៉ាក គឺជាការប្រព្រឹត្ត ដែលទាក់ទងទៅនឹងមាត្រា ១១ នៃច្បាប់នេះ ដោយជនណាម្នាក់ក្រៅពីម្ចាស់ម៉ាក ដែលបានចុះបញ្ជីរួចហើយ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយដែលពុំមានការយល់ព្រមពីម្ចាស់ម៉ាក ។

**មាត្រា ២៥.-**

ការប្រើប្រាស់នូវសញ្ញាដូច ឬប្រហាក់ប្រហែល ដែលធ្វើឱ្យភ័ន្តច្រឡំទៅនឹងម៉ាកល្បី ដែលបានចុះបញ្ជីរួចហើយ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយគ្មានការយល់ព្រមពីម្ចាស់នៃម៉ាកល្បី ជាការរំលោភលើម៉ាកល្បីនោះ ប្រសិនបើសញ្ញាទាំងនោះត្រូវបានយកមកប្រើប្រាស់ :

ក- ទាក់ទងទៅនឹងទំនិញ និងសេវា ដែលដូច ឬប្រហាក់ប្រហែលនឹងទំនិញ និងសេវានៃម៉ាកល្បី ដែលបានចុះបញ្ជីរួច ។

ខ- ទាក់ទងទៅនឹងទំនិញ និងសេវា ដែលមិនដូច ឬមិនប្រហាក់ប្រហែលនឹងទំនិញនិងសេវានៃម៉ាកល្បី ដែលបានចុះបញ្ជីរួច ហើយការប្រើប្រាស់នូវសញ្ញាទាក់ទងនឹងទំនិញ ឬសេវានោះ បញ្ជាក់នូវការ

ពាក់ព័ន្ធគ្នារវាងទំនិញ និងសេវានោះជាមួយនឹងម្ចាស់នៃម៉ាកល្បី ហើយដែលផលប្រយោជន៍នៃម្ចាស់ម៉ាកល្បី អាចនឹងត្រូវខូចខាតដោយការប្រើប្រាស់នោះ ។

**មាត្រា ២៦.-**

ការប្រើប្រាស់នូវសញ្ញាដែលដូច ឬប្រហាក់ប្រហែលនឹងម៉ាកល្បី ដែលមិនបានចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយគ្មានការយល់ព្រមពីម្ចាស់នៃម៉ាកល្បី ជាការរំលោភលើម៉ាកល្បីនោះ ប្រសិនបើសញ្ញានោះត្រូវបានប្រើប្រាស់ទាក់ទងទៅនឹងទំនិញ ឬសេវាដូច ឬប្រហាក់ប្រហែលនឹងទំនិញ ឬសេវានៃម៉ាកល្បីនោះ ។

**មាត្រា ២៧.-**

តាមសំណើរបស់ម្ចាស់ម៉ាក ឬអ្នកទទួលអាជ្ញាប័ណ្ណ តុលាការ អាចចេញនូវសេចក្តីសម្រេចបណ្តោះអាសន្នមួយ ដើម្បីទប់ស្កាត់ការរំលោភ ការដែលនឹងមានការរំលោភ ឬទង្វើដែលមិនស្របច្បាប់ដូចមានចែងក្នុងមាត្រា ២១ មាត្រា ២២ និងមាត្រា ២៣ និងសម្រេចឱ្យសងការខូចខាត ហើយផ្តល់នូវដំណោះស្រាយផ្សេងៗ ដែលមានចែងក្នុងច្បាប់ជាធរមាន ។ ប្រសិនបើអ្នកទទួលអាជ្ញាប័ណ្ណបានស្នើទៅម្ចាស់ម៉ាកឱ្យប្តឹងទៅតុលាការ ដើម្បីឱ្យជួសជុលនូវសំណងដ៏ជាក់លាក់មួយ ប៉ុន្តែបើម្ចាស់ម៉ាក បានបដិសេធ ឬខកខានមិនបានធ្វើតាម អ្នកទទួលអាជ្ញាប័ណ្ណអាចប្តឹងទៅតុលាការដោយផ្ទាល់បាន ។

**មាត្រា ២៨.-**

តាមសំណើរបស់អាជ្ញាធរមានសមត្ថកិច្ចណាមួយ ឬជនណាមួយដែលមានការពាក់ព័ន្ធដូចជា សមាគម ឬសហជីពនៃផលិតករ ឧស្សាហករ ឬពាណិជ្ជករ តុលាការអាចសំរេចឱ្យមានការជួសជុលសំណង ចំពោះករណីនៃការប្រកួតប្រជែងមិនស្មោះត្រង់ ដូចមានចែងនៅក្នុងមាត្រា ២២ និងមាត្រា ២៣ ។

## ជំពូកទី ៩
## វិធានការបណ្តោះអាសន្ន

**មាត្រា ២៩.-**

តាមសំណើរបស់អ្នកប្តឹង តុលាការមានអំណាចដាក់ចេញនូវវិធានការបណ្តោះអាសន្នជាបន្ទាន់ និងមានប្រសិទ្ធភាព ដើម្បីទប់ស្កាត់ការរំលោភ ការរំលោភដែលប្រុងនឹងកើតមាន ឬរក្សាទុកនូវភ័ស្តុតាងដែលពាក់ព័ន្ធ ។

**មាត្រា ៣០.-**

នៅពេលចាំបាច់ ជាពិសេសនៅពេលការយឺតយ៉ាវ អាចបណ្តាលឱ្យមានភាពអន្តរាយ ដែលមិនអាចជួសជុលបាន ចំពោះម្ចាស់សិទ្ធិ ឬនៅពេលដែលភ័ស្តុតាងអាចនឹងត្រូវបំផ្លាញ តុលាការអាចដាក់ចេញនូវវិធានការបណ្តោះអាសន្ន ប្រសិនបើដើមចោទផ្តល់នូវ :

ក- ភ័ស្តុតាងត្រឹមត្រូវដែលមាន ដែលអាចធ្វើឱ្យតុលាការយល់ស្របក្នុងកម្រិតមួយគ្រប់គ្រាន់ សម្រាប់សន្និដ្ឋានបញ្ជាក់ថា ដើមចោទ គឺជាម្ចាស់ពិតប្រាកដ ហើយសិទ្ធិរបស់អ្នកប្តឹងកំពុងត្រូវបានគេរំលោភ ឬការរំលោភនោះ អាចនឹងកើតមានឡើងក្នុងពេលឆាប់ៗ ។

ខ- ប្រាក់កក់ធានាដែលតម្រូវ ឬការធានាដែលមានតម្លៃ ស្មើនៃប្រាក់កក់គ្រប់គាន់ ក្នុងការការពារចុងចម្លើយ និងទប់ស្កាត់មិនឱ្យមានការរំលោភបំពាន ។ ប្រាក់កក់ធានានេះ ត្រូវស្ថិតនៅក្រោមការកំណត់របស់តុលាការ ។

**មាត្រា ៣១.-**

នៅពេលដែលវិធានការបណ្តោះអាសន្នត្រូវបានដាក់ចេញ តុលាការត្រូវជូនដំណឹងដល់ចុងចម្លើយអំពីសេចក្តីសម្រេចស្តីពីការចាត់វិធានការបណ្តោះអាសន្ននោះ ។

**មាត្រា ៣២.-**

នៅពេលដែលវិធានការបណ្តោះអាសន្ន ត្រូវបានដាក់ចេញ តាមមាត្រា ៣០ និងមាត្រា ៣១ ចុងចម្លើយអាចដាក់ពាក្យបណ្តឹងទៅតុលាការស្នើសុំឱ្យពិនិត្យវិធានការនោះឡើងវិញ ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ គិតពីថ្ងៃបានទទួលដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការ ។ តុលាការត្រូវផ្តល់នូវឱកាសសវនាការឱ្យដល់ភាគីដែលពាក់ព័ន្ធ ហើយត្រូវពិនិត្យវិធានការនោះឡើងវិញ និងតម្កល់ កែតម្រូវ ឬលុបចោលនូវសេចក្តីសម្រេចរបស់ខ្លួន ក្នុងរយៈពេលមួយសមស្របតាមច្បាប់កំណត់ ។

**មាត្រា ៣៣.-**

ក្នុងករណីដើមចោទ នៅក្នុងរយៈពេល ២០ (ម្ភៃ) ថ្ងៃ នៃថ្ងៃធ្វើការ គិតពីថ្ងៃបានទទួលដំណឹងអំពីការដាក់ចេញនូវវិធានការបណ្តោះអាសន្នហើយ ឬនៅក្នុងរយៈពេលមួយសមស្រប ដែលកំណត់ដោយតុលាការ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន មិនបានផ្តួចផ្តើមបន្តសំណុំរឿងបណ្តឹង ដែលនាំដល់សេចក្តី

សម្រេចអំពីអង្គសេចក្តីនៃករណី តុលាការត្រូវលុបនូវវិធានការបណ្តោះអាសន្ននោះចោលវិញ ដោយផ្អែកតាមសំណើរបស់ចុងចម្លើយ ។

**មាត្រា ៣៤.-**

ក្នុងករណីដែលវិធានការបណ្តោះអាសន្នត្រូវបានលុបចោលវិញ ឬក្នុងករណីដែលតុលាការសម្រេចនូវអង្គសេចក្តីនៃករណីតាមដំណាក់ការជំរះក្តី ស្របតាមមាត្រា ៣៣ តាមការផ្តួចផ្តើមរបស់ដើមចោទ ប៉ុន្តែបែរជាគ្មានការរំលោភ ឬ ការគំរាមរំលោភវិញ ដោយយោងតាមសំណើរបស់ចុងចម្លើយ តុលាការត្រូវសម្រេចឱ្យដើមចោទសងឱ្យចុងចម្លើយនូវសំណងសមស្រប ចំពោះការខូចខាតនានា ដែលកើតមានឡើងដោយការអនុវត្តន៍នូវវិធានការបណ្តោះអាសន្ននោះ ។

## ជំពូកទី ១០
## វិធានការតាមមាត់ច្រកព្រំដែន

**មាត្រា ៣៥.-**

ម្ចាស់ម៉ាកដែលបានចុះបញ្ជីហើយ អាចធ្វើពាក្យបណ្តឹងទៅរដ្ឋបាលគយ និងរដ្ឋាករ ឬអាជ្ញាធរមានសមត្ថកិច្ច ឬតុលាការ ឱ្យព្យួរទុកនូវការធ្វើបែបបទទំនិញណា ដែលសង្ស័យថា មានម៉ាកក្លែងក្លាយ ដោយបង្ហាញនូវភ័ស្តុតាងច្បាស់លាស់ថា គាត់ជាម្ចាស់នៃម៉ាក ដែលបានចុះបញ្ជី ។

**មាត្រា ៣៦.-**

ពាក្យបណ្តឹងទាំងឡាយដែលបានលើកនៅក្នុងមាត្រា ៣៥ ត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ និងត្រូវអមដោយ :

ក- វិញ្ញាបនប័ត្រចុះបញ្ជីម៉ាក ។

ខ- សេចក្តីថ្លែងពីមូលហេតុនៃការប្តឹង និងជាពិសេស ភ័ស្តុតាងដំបូង ដែលបង្ហាញថា ទំនិញនោះពាក់ម៉ាកក្លែងក្លាយមែន ។

គ- ការរៀបរាប់ដ៏ល្អិតល្អន់ពីទំនិញដែលម៉ាករបស់វា ត្រូវបានប្រើប្រាស់ ព្រមទាំងគំរូនៃផលិតផលពិតប្រាកដផង ប្រសិនបើមានសំណូមពរ ។

ឃ- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្តឹង និងតំណាងរបស់គេ ដែលត្រូវរៀបរាប់ឱ្យបានសព្វគ្រប់តាមការកំណត់ ។

ង- លិខិតអនុញ្ញាតពីម្ចាស់ម៉ាក ដែលបានចុះបញ្ជី ប្រសិនបើពាក្យបណ្តឹងនោះត្រូវបានដាក់ដោយតំណាងដែលទទួលសិទ្ធិ ។

ច- កម្រៃរដ្ឋបាល តាមការកំណត់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## មាត្រា ៣៧.-

ក្នុងរយៈពេល ១០ (ដប់) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលនូវពាក្យបណ្តឹង តាមមាត្រា ៣៥ រដ្ឋបាលគយនិងរដ្ឋាករ ឬអាជ្ញាធរមានសមត្ថកិច្ចត្រូវជូនដំណឹងទៅអ្នកប្តឹងថា ពាក្យបណ្តឹងរបស់ខ្លួនត្រូវបានទទួលស្គាល់ថា ត្រឹមត្រូវ ឬ បដិសេធ ឬមួយរក្សាទុក សម្រាប់ពិចារណានៅពេលក្រោយ ។

## មាត្រា ៣៨.-

រដ្ឋបាលគយនិងរដ្ឋាករ ឬអាជ្ញាធរមានសមត្ថកិច្ចផ្សេងៗទៀត ដែលកំណត់ដោយអនុក្រឹត្យ មានសិទ្ធិស្នើឱ្យអ្នកប្តឹងបង់ប្រាក់ធានា ឬតម្រូវឱ្យមានការធានា ដែលមានតំលៃស្មើនៃប្រាក់កក់គ្រប់គ្រាន់សម្រាប់ការពារ អ្នកនាំចូល អ្នកទទួល អ្នកនាំចេញ ឬម្ចាស់ទំនិញ និងអាជ្ញាធរមានសមត្ថកិច្ច ។ ប្រាក់ធានា ឬការធានាដែលមានតម្លៃស្មើនៃប្រាក់កក់នេះ ត្រូវបានកំណត់តាមរបៀប និងបែបបទមួយដែលមិនត្រូវឱ្យរារាំងដល់ការអនុវត្តន៍នីតិវិធីនេះដោយមិនសមហេតុផល ។

## មាត្រា ៣៩.-

ក្នុងពេលយល់ព្រមតាមពាក្យបណ្តឹងក្នុងមាត្រា ៣៥ រដ្ឋបាល គយនិងរដ្ឋាករ ត្រូវព្យួរទុកនូវការធ្វើបែបបទទំនិញ ដែលមានទាក់ទងទៅនឹងពាក្យបណ្តឹង ។ ការព្យួរទុកនេះ ត្រូវនៅជាធរមាន ក្នុងរយៈពេលដំបូង និងក្នុងរយៈពេលដែលបានពន្យារមិនលើសពី ១០ (ដប់) ថ្ងៃ នៃថ្ងៃធ្វើការ ។ រដ្ឋបាលគយនិងរដ្ឋាករ ត្រូវជូនពត៌មានភ្លាមទៅអ្នកនាំចូល និងអ្នកប្តឹង អំពីការព្យួរទុកនូវការធ្វើបែបបទទំនិញ ហើយត្រូវបញ្ជាក់ពីមូលហេតុនៃការព្យួរទុកនេះផង ។ រដ្ឋបាលគយនិងរដ្ឋាករ ត្រូវជូនដំណឹងពីឈ្មោះ និងអាសយដ្ឋាននៃអ្នកប្តឹង ដល់អ្នកនាំចូលផងដែរ ។

**មាត្រា ៤០.-**

ក្នុងរយៈពេលមិនហួសពី ១០ (ដប់) ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយពេលដែលអ្នកប្ដឹងបានទទួលនូវពត៌មានអំពីការឃាត់ទំនិញ ប្រសិនបើរដ្ឋបាលគយនិងរដ្ឋាករបានទទួលនូវពតិមានថា ចំណាត់ការដែលនាំដល់ការសម្រេចនូវអង្គសេចក្ដីនៃករណីមិនត្រូវបានផ្ដួចផ្ដើមឡើង ដោយភាគីមួយទៀតផ្សេងពីចុងចម្លើយ ឬថាអាជ្ញាធរដែលបានប្រគល់សិទ្ធិត្រឹមត្រូវ មិនបានអនុវត្តនូវវិធានការបណ្ដោះអាសន្ន ដើម្បីពន្យារការដោះលែងទំនិញទេ ទំនិញនោះនឹងត្រូវដោះលែង តែក្នុងករណីដែលលក្ខខណ្ឌផ្សេងៗទៀត សម្រាប់ការនាំចូល ឬនាំចេញត្រូវបានគោរព ។

ក្នុងករណីសមស្រប រយៈពេលនេះអាចត្រូវពន្យារ (១០ ដប់) ថ្ងៃទៀតនៃថ្ងៃធ្វើការ ។

ប្រសិនបើចំណាត់ការ ដែលនាំឱ្យមានការសម្រេចនូវអង្គសេចក្ដីនៃករណី ត្រូវបានផ្ដួចផ្ដើមឡើង ការពិនិត្យឡើងវិញ មានទាំងការធ្វើសវនាការផង ត្រូវបានរៀបចំឡើងតាមការស្នើសុំពីសំណាក់ចុងចម្លើយ ដើម្បីសម្រេចនៅក្នុងរយៈពេលមួយសមស្របថា តើវិធានការនេះត្រូវតម្កល់ កែតម្រូវ ឬលុបចោល ។

**មាត្រា ៤១.-**

អាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធ មានសិទ្ធិសម្រេចឱ្យអ្នកប្ដឹងសងទៅម្ចាស់អ្នកនាំចូល អ្នកនាំចេញ និងអ្នកទទួលទំនិញ នូវសំណងសមស្រប ចំពោះការខូចខាតរបស់គេ ដែលបណ្ដាលមកពីការឃាត់ទំនិញដោយមិនត្រឹមត្រូវ ឬការឃាត់ទំនិញដូចមានចែងក្នុងមាត្រា ៣៩ ។ ក្នុងករណីភាគីណាមួយ មិនយល់ព្រមតាមសេចក្ដីសម្រេចនោះ ភាគីនោះមានសិទ្ធិប្ដឹងទៅតុលាការ ។

**មាត្រា ៤២.-**

រដ្ឋបាលគយនិងរដ្ឋាករ ឬអាជ្ញាធរមានសមត្ថកិច្ចផ្សេងៗទៀត អាចអនុញ្ញាតឱ្យម្ចាស់សិទ្ធិអ្នកនាំចូល ឬអ្នកនាំចេញ ពិនិត្យទំនិញដែលបានព្យួរទុកតាមបែបបទគយ ដូចមានចែងក្នុងមាត្រា ៣៩ និងដកយកនូវគំរូ ដើម្បីពិនិត្យសាកល្បង និងវិភាគក្នុងគោលបំណងបញ្ជាក់ឱ្យដឹងថា ទំនិញនោះពាក់ម៉ាកក្លែងក្លាយ ឬមិនក្លែងក្លាយ ។

នៅពេលដែលទំនិញត្រូវបានបញ្ជាក់ឱ្យដឹងថាជាទំនិញពាក់ ម៉ាកក្លែងក្លាយ រដ្ឋបាលគយ និងរដ្ឋាករអាច ជូនពត៌មានទៅម្ចាស់សិទ្ធិ នូវឈ្មោះ និងអាស័យដ្ឋាននៃអ្នកនាំចេញ អ្នកនាំចូល អ្នកទទួល និងបរិមាណ ទំនិញ ។ ដោយមិនឱ្យប៉ះពាល់ដល់ការការពារនូវពត៌មានសម្ងាត់រដ្ឋបាលគយនិងរដ្ឋាករ ឬអាជ្ញាធរ មានសមត្ថកិច្ចផ្សេងៗទៀត អាចផ្ដល់ទៅឱ្យម្ចាស់ សិទ្ធិនូវច្បាប់ចម្លងនៃឯកសារទំនិញទាំងនោះ ឬនូវ ពត៌មានដែលមាន ឬឯកសារ ដែលទាក់ទងទៅនឹងការនាំចូល ឬនាំចេញ នូវទំនិញប្រហាក់ប្រហែល ពីមុន ដោយអ្នកនាំចូល ឬអ្នកនាំចេញដដែលនេះ តាមសំណូមពររបស់ម្ចាស់សិទ្ធិ ។

## មាត្រា ៤៣.-

រដ្ឋបាលគយនិងរដ្ឋាករ អាចព្យួរទុកនូវការធ្វើបែបបទទំនិញ ដែលពាក់ម៉ាកក្លែងក្លាយ ដែលខ្លួនបាន ពិនិត្យឃើញ មានភស្តុតាងជាលើកដំបូងថា កំពុងតែមាន ឬអាចនឹងមានការនាំចូលនូវទំនិញប្រភេទ នេះ ។

## មាត្រា ៤៤.-

រដ្ឋបាលគយនិងរដ្ឋាករត្រូវជូនពត៌មានភ្លាមទៅឱ្យម្ចាស់សិទ្ធិ អំពីទីកន្លែង និងថ្ងៃដែលព្យួរទុកនូវការធ្វើ បែបបទរបស់គយ ហើយរដ្ឋបាលគយនិងរដ្ឋាករ ក៏អាចស្នើឱ្យម្ចាស់សិទ្ធិផ្ដល់នូវពត៌មានទាំងឡាយ ដែលអាចជាជំនួយក្នុងការអនុវត្តន៍នូវអំណាចរបស់ខ្លួនផងដែរ ។

## មាត្រា ៤៥.-

ដោយអនុលោមទៅនឹងបញ្ញត្តិដែលមានចែងក្នុងមាត្រា ៤២ នៃច្បាប់នេះ អាជ្ញាធរសាធារណៈ និង មន្ត្រីទទួលបន្ទុកត្រូវបានលើកលែង ពីការទទួលខុសត្រូវ ចំពោះវិធានការដោះស្រាយដោយសមស្រប នៅ ពេលដែលសកម្មភាពទាំងនោះ ត្រូវបានធ្វើ ឬមានបំណងនឹងធ្វើដោយស្មោះត្រង់ ។

## មាត្រា ៤៦.-

រដ្ឋបាលគយនិងរដ្ឋាករ និងអាជ្ញាធរមានសមត្ថកិច្ច តាមរយៈសេចក្ដីសម្រេចរបស់តុលាការ មានសិទ្ធិ បំផ្លាញចោលនូវទំនិញ ដែលពាក់ម៉ាកក្លែងក្លាយនោះ ។ រដ្ឋបាលគយនិងរដ្ឋាករ មិនត្រូវអនុញ្ញាតឱ្យ ធ្វើការនាំចេញបន្តនូវទំនិញដែលមានម៉ាកក្លែងក្លាយ ឬដាក់ទំនិញនេះ ឱ្យនៅក្រោមនីតិវិធីផ្សេងទៀត របស់គយឡើយ ។

**មាត្រា ៤៧.-**

ទំនិញពាក់ម៉ាកក្លែងក្លាយដែលមិនមានលក្ខណៈពាណិជ្ជកម្ម ដែលនៅក្នុងអីវ៉ាន់ផ្ទាល់ខ្លួននៃអ្នកដំណើរ អាចស្ថិតនៅក្រៅការអនុវត្តន៍នៃច្បាប់នេះ ។

## ជំពូកទី ១១
## ការប្តូរម្ចាស់កម្មសិទ្ធិ

**មាត្រា ៤៨.-**

តាមសំណើរបស់ភាគីដែលពាក់ព័ន្ធមកមន្ត្រីកាន់កាប់បញ្ជី ការប្តូរម្ចាស់កម្មសិទ្ធិណាមួយនៃការចុះបញ្ជីម៉ាក ត្រូវសរសេរជាលាយល័ក្ខណ៍អក្សរ ហើយត្រូវបានចុះបញ្ជី និងចុះផ្សាយដោយមន្ត្រីកាន់កាប់បញ្ជី ។ ការប្តូរបែបនេះនឹងមិនមានអានុភាពចំពោះភាគីទីបីឡើយ រហូតដល់ការចុះបញ្ជីត្រូវបានធ្វើរួចជាស្ថាពរ ។

**មាត្រា ៤៩.-**

ការប្តូរម្ចាស់កម្មសិទ្ធិណាមួយនៃការចុះបញ្ជីម៉ាកសមូហភាព តម្រូវឱ្យមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មជាមុន ។

**មាត្រា ៥០.-**

ការប្តូរម្ចាស់កម្មសិទ្ធិណាមួយនៃពាណិជ្ជនាម ត្រូវធ្វើឡើង ដោយការផ្ទេរសហគ្រាសទាំងមូល ឬមួយផ្នែក ហើយត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ ។

**មាត្រា ៥១.-**

ការប្តូរម្ចាស់កម្មសិទ្ធិនៃការចុះបញ្ជីម៉ាក ត្រូវចាត់ទុកជាមោឃៈ ប្រសិនបើម៉ាកនោះទំនងជាមានលក្ខណៈបោកបញ្ឆោត ឬបណ្ដាលឱ្យមានការភាន់ច្រឡំ ជាពិសេសចំពោះប្រភេទ ប្រភពដើម ដំណើរការ ផលិតកម្ម ចរិតលក្ខណៈ ភាពសមស្រប ដើម្បីគោលបំណងនៃទំនិញ ឬសេវា ដែលម៉ាកនោះ បម្រុងប្រើប្រាស់ ឬកំពុងប្រើប្រាស់ ។

**មាត្រា ៥២.-**

កិច្ចសន្យាអាជ្ញាប័ណ្ណណាមួយពាក់ព័ន្ធនឹងម៉ាក ដែលបានចុះបញ្ជីរួចហើយ ឬពាក្យស្នើសុំទទួលស្គាល់កិច្ចសន្យា ត្រូវដាក់ជូនមន្ត្រីកាន់កាប់បញ្ជី ដែលត្រូវរក្សាការសម្ងាត់ ចំពោះខ្លឹមសារនៃកិច្ចសន្យានោះ ប៉ុន្តែត្រូវចុះបញ្ជី និងចុះផ្សាយនូវពត៌មានដែលពាក់ព័ន្ធ ។ កិច្ចសន្យាអាជ្ញាប័ណ្ណនឹងមិនមានអានុភាពចំពោះភាគីទីបីឡើយ រហូតដល់ការចុះបញ្ជីនោះ ត្រូវបានធ្វើរួចជាស្ថាពរ ។

## ជំពូកទី ១២
## ការកាន់កាប់បញ្ជីម៉ាក

**មាត្រា ៥៣.-**

ក្រសួងពាណិជ្ជកម្មមានតួនាទីបំពេញភារកិច្ច ដែលទាក់ទងទៅនឹងនីតិវិធី ដើម្បីធ្វើការចុះបញ្ជីម៉ាក និងដើម្បីធ្វើការគ្រប់គ្រងម៉ាក ដែលបានចុះបញ្ជីរួចហើយ ដូចបានបញ្ជាក់នៅក្នុងច្បាប់នេះ និងនៅក្នុងបទបញ្ជាទាំងឡាយ ។

**មាត្រា ៥៤.-**

ក្រសួងពាណិជ្ជកម្ម ជាស្ថាប័នមានសមត្ថកិច្ចកាន់កាប់ និងចុះបញ្ជីម៉ាក ។ ម៉ាកសមូហភាពនឹងត្រូវចុះបញ្ជីនៅក្នុងផ្នែកពិសេសមួយនៃបញ្ជីម៉ាក ។ គ្រប់ការកត់ត្រា ដែលមានចែងនៅក្នុងច្បាប់នេះ ត្រូវធ្វើនៅក្នុងបញ្ជីខាងលើ ។

ជនណាក៏ដោយ ក៏អាចមានសិទ្ធិសុំមើលបញ្ជីម៉ាកបានដែរ ហើយអាចដកស្រង់ចេញពីបញ្ជីនោះ នូវពត៌មានផ្សេងៗ ដែលស្របទៅតាមលក្ខខណ្ឌដែលបានកំណត់នៅក្នុងបទបញ្ជា ។

**មាត្រា ៥៥.-**

ក្រសួងពាណិជ្ជកម្មត្រូវបោះពុម្ពនៅក្នុងព្រឹត្តិប័ត្រផ្លូវការនូវគ្រប់ការចុះបញ្ជី ការចុះបញ្ជីសាឡើងវិញ ការបដិសេធ ការលុបម៉ាកចេញពីបញ្ជី និងការងារផ្សេងៗទៀត ដែលកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៥៦.-**

តាមប្រការទាំងឡាយនៃបទបញ្ជា មន្ត្រីកាន់កាប់បញ្ជីអាចកែតម្រូវកំហុសផ្សេងៗ នៅក្នុងការកត់ត្រា ដែលបានធ្វើឡើង ដោយអនុលោមតាមច្បាប់នេះ ឬតាមបទបញ្ជាទាំងឡាយ ។

នៅពេលទទួលសំណើជាលាយល័ក្ខណ៍អក្សរហើយ ប្រសិនបើមន្ត្រីកាន់កាប់បញ្ជីយល់ថា ជាការត្រឹមត្រូវ ដើម្បីធ្វើដូច្នោះ មន្ត្រីកាន់កាប់បញ្ជីអាចបន្តពេលវេលាសម្រាប់អនុវត្តសកម្មភាពណាមួយ ឬប្រកាន់យកនូវចំណាត់ការណាមួយតាមច្បាប់នេះ និងតាមបទបញ្ជាទាំងឡាយ ដោយជូនដំណឹងដល់ភាគីពាក់ព័ន្ធ និងតាមលក្ខខណ្ឌ ដែលមន្ត្រីកាន់កាប់បញ្ជីដាក់បញ្ជាឱ្យ ។ ការបន្តនេះអាចត្រូវយល់ព្រម ទោះបីរយៈពេលអនុវត្តនូវសកម្មភាព ឬប្រកាន់យកនូវចំណាត់ការត្រូវផុតកំណត់ហើយក៏ដោយ ។

**មាត្រា ៥៧.-**

មន្ត្រីកាន់កាប់បញ្ជី ត្រូវផ្តល់នូវឱកាសសម្រាប់សវនាការ ដល់ភាគីណាមួយនៃបណ្តឹងនៅចំពោះមុខខ្លួន មុនពេលអនុវត្តអំណាចឆន្ទានុសិទ្ធិ ដែលបានប្រគល់ឱ្យដោយច្បាប់នេះ និងដោយបទបញ្ជាទាំងឡាយ ប្រឆាំងចំពោះភាគីនោះ ។

## ជំពូកទី ១៣
## ភ្នាក់ងារ

**មាត្រា ៥៨.-**

ក្នុងករណីដែលលំនៅដ្ឋានអចិន្ត្រៃយ៍ ឬទីតាំងប្រកបអាជីវកម្មសំខាន់របស់អ្នកស្នើសុំ ស្ថិតនៅក្រៅព្រះរាជាណាចក្រកម្ពុជា អ្នកស្នើសុំនោះ ត្រូវមានតំណាងជាភ្នាក់ងារ ដែលមានទីលំនៅ និងកំពុងប្រកបវិជ្ជាជីវៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៥៩.-**

អ្នកតំណាងដែលជាភ្នាក់ងារក្នុងការដាក់ពាក្យសុំចុះបញ្ជីម៉ាក នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដូចមានចែងនៅក្នុងប្រកាសរបស់ក្រសួងពាណិជ្ជកម្ម ។

## ជំពូកទី ១៥
## ការអនុវត្តន៍សន្ធិសញ្ញាអន្តរជាតិ និងការបកស្រាយ

### មាត្រា ៦០.-

បទប្បញ្ញត្តិទាំងឡាយនៃសន្ធិសញ្ញាអន្តរជាតិ អំពីកម្មសិទ្ធិឧស្សាហកម្ម ដែលព្រះរាជាណាចក្រកម្ពុជាជាភាគីមួយនៃសន្ធិសញ្ញានោះ ត្រូវយកមកអនុវត្តជាមួយនឹងច្បាប់នេះបានផងដែរ ។

ក្នុងករណីមានទំនាស់ជាមួយនឹងមាត្រាទាំងឡាយនៃច្បាប់នេះ បទប្បញ្ញត្តិនៃសន្ធិសញ្ញាអន្តរជាតិទាំងនោះ ត្រូវចាត់ទុកជាបទប្បញ្ញត្តិគោល ។

### មាត្រា ៦១.-

នៅក្នុងច្បាប់នេះ :

- ចំណាត់ថ្នាក់អន្តរជាតិ មានន័យថា ចំណាត់ថ្នាក់ដែលអនុលោមតាមកិច្ចព្រមព្រៀងទីក្រុងនីស ដែលចែងអំពីចំណាត់ថ្នាក់អន្តរជាតិនៃទំនិញ និងសេវាកម្ម សម្រាប់គោលបំណងនៃការចុះបញ្ជីម៉ាក ចុះថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ១៩៥៧ ដែលបានកែសម្រួលនៅពេលចុងក្រោយ
- អនុសញ្ញាទីក្រុងប៉ារីស មានន័យថា អនុសញ្ញាដែលបានចុះហត្ថលេខា នៅទីក្រុងប៉ារីស ស្តីពីការការពារកម្មសិទ្ធិឧស្សាហកម្ម ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ១៨៨៣ ដែលបានកែសំរួល នៅពេលចុងក្រោយ
- កាលបរិច្ឆេទអាទិភាព មានន័យថា ពេលវេលានៃការស្នើសុំមុនគេ ដែលប្រើប្រាស់ជាមូលដ្ឋានសម្រាប់ទទួលនូវសិទ្ធិអាទិភាព ដូចមានចែងនៅក្នុងអនុសញ្ញា ទីក្រុងប៉ារីស
- បទបញ្ជា មានន័យថា ប្រកាស ឬសេចក្តីណែនាំ ដែលចេញដោយក្រសួងពាណិជ្ជកម្ម
- ទំនិញដែលពាក់ម៉ាកក្លែងក្លាយ មានន័យថា ទំនិញទាំងឡាយ រួមទាំងសំបកវេចខ្ចប់ផង ដែលមានម៉ាកដូចគ្នានឹងម៉ាកដែលបានចុះបញ្ជីត្រឹមត្រូវទាក់ទងទៅនឹងទំនិញនោះ ដោយគ្មានការអនុញ្ញាត ឬមិនអាចសំគាល់បាននូវលក្ខណៈខុសគ្នាពីទិដ្ឋភាពសំខាន់ៗនៃម៉ាក និងដែលរំលោភបំពានសិទ្ធិរបស់ម្ចាស់ម៉ាកស្របច្បាប់ ក្រោមច្បាប់នៃប្រទេសនាំចូល ។

# ជំពូកទី ១៥
# ទោសប្បញ្ញត្តិ

**មាត្រា ៦២.-**

សេចក្តីសម្រេចរបស់ក្រសួងពាណិជ្ជកម្ម អាចជាកម្មវត្ថុនៃការប្តឹងតវ៉ាទៅតុលាការមានសមត្ថកិច្ចបាន ដោយភាគីជំទាស់ណាមួយ ហើយបណ្តឹងតវ៉ានេះត្រូវធ្វើក្នុងរយៈពេល (៣ បី) ខែ គិតចាប់ពីថ្ងៃចេញសេចក្តីសម្រេច ។

**មាត្រា ៦៣.-**

ជនណាដែលផ្តល់ពត៌មានមិនពិតដល់មន្ត្រីកាន់កាប់បញ្ជី ក្នុងការដាក់ពាក្យស្នើសុំបណ្តឹងជំទាស់ ឬ ឯកសារដទៃ ដែលបានតម្កល់ទុក ទាក់ទិននឹងការស្នើសុំចុះបញ្ជី ការកែតម្រូវនៃការចុះបញ្ជី ការចុះបញ្ជីសាជាថ្មី ការលុបចោលនូវការចុះបញ្ជីម៉ាក ពាណិជ្ជនាម ឬកិច្ចសន្យាផ្តល់អាជ្ញាប័ណ្ណដែលទាក់ទងនឹងម៉ាក ត្រូវផ្តន្ទាទោសពិន័យជា ប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ដល់ ៥.០០០.០០០ (ប្រាំលាន) រៀល និងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ៦ (ប្រាំមួយ) ខែ ឬទោសណាមួយនៃទោសទាំងពីរនេះ ។

**មាត្រា ៦៤.-**

ជនណាដែលក្លែងបន្លំពាណិជ្ជសញ្ញា សេវាសញ្ញា ម៉ាកសមូហភាព ឬពាណិជ្ជនាមរបស់សហគ្រាសមួយផ្សេងទៀត ដែលបានចុះបញ្ជី នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដូចមានចែងនៅមាត្រា ១១ ចំណុច ខ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ដល់ ២០.០០០.០០០ (ម្ភៃលាន) រៀល និងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ដល់ ៥ (ប្រាំ) ឆ្នាំ ឬទោសណាមួយនៃទោសទាំងពីរនេះ ។

**មាត្រា ៦៥.-**

ជនណាដែលធ្វើត្រាប់តាម ពាណិជ្ជសញ្ញា សេវាសញ្ញា ម៉ាក សមូហភាព ឬពាណិជ្ជនាមរបស់សហគ្រាសមួយ ដែលបានចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងបំភ័ន្តសាធារណជន

ឱ្យជឿថា ពាណិជ្ជសញ្ញា សេវាសញ្ញា ម៉ាកសមូហភាព ឬពាណិជ្ជនាមទាំងនោះ ជារបស់សហគ្រាសមួយផ្សេងទៀត ដូចមានចែងក្នុងមាត្រា ២៣ ត្រូវផ្តន្ទាទោស ពិន័យជាប្រាក់ពី ៥.០០០.០០០ ( ប្រាំលាន) រៀល ដល់ ១០.០០០.០០០ ( ដប់លាន) រៀល និងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ ( មួយ) ខែ ដល់ ១ ( មួយ) ឆ្នាំ ឬទោសណាមួយនៃទោសទាំងពីរនេះ ។

### មាត្រា ៦៦.-

ជនណាដែលនាំចូល លក់ ប្រកាសលក់ ឬមានបំណងលក់ ដោយចេតនានូវទំនិញដែលមានម៉ាកក្លែងបន្លំ ឬមានចេតនាផ្តល់សេវា ចំពោះសេវាសញ្ញា ម៉ាកសមូហភាព ឬ ពាណិជ្ជនាមក្លែងបន្លំត្រូវផ្តន្ទាទោសតាមបទប្បញ្ញត្តិនៃមាត្រា ៦៤ នៃច្បាប់នេះ ។

ជនណាដែលនាំចូល លក់ ប្រកាសលក់ ឬមានបំណងលក់ ដោយចេតនា នូវទំនិញដែលមានម៉ាកត្រាប់តាមគេ ត្រូវផ្តន្ទាទោសតាមបទប្បញ្ញត្តិនៃមាត្រា ៦៥ នៃច្បាប់នេះ ។

### មាត្រា ៦៧.-

ក្នុងករណីមិនរាងចាលចំពោះបទល្មើសនឹងមាត្រា ៦៤ ឬ មាត្រា ៦៥ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសទ្វេឡើង ទាំងទោសពិន័យជាប្រាក់ ទាំងទោសដាក់ពន្ធនាគារ ដែលមានបញ្ញត្តិនៅក្នុងមាត្រានោះ ។

### មាត្រា ៦៨.-

ក្នុងករណីជនល្មើស ដែលទទួលខុសត្រូវចំពោះច្បាប់នេះ ជានីតិបុគ្គល នាយកគ្រប់គ្រង អ្នកចាត់ការ ឬតំណាងនៃនីតិបុគ្គលនោះ ក៏ត្រូវទទួលទណ្ឌកម្ម ដូចដែលបានចែងសម្រាប់បទល្មើសនោះដែរ លើកលែងតែគេអាចបង្ហាញភស្តុតាងតាមរយៈនីតិបុគ្គលថា គេពុំបានដឹងឮ ឬយល់ស្របនឹងបទល្មើសនោះឡើយ ។

### មាត្រា ៦៩.-

ទំនិញទាំងឡាយដែលបាននាំចូល លក់ ផ្តល់ឱ្យសម្រាប់លក់ ឬមានគោលបំណងលក់ដោយបំពានច្បាប់នេះ ដូចមានចែងក្នុងមាត្រា ៦៦ ត្រូវរឹបអូស ឬនិងបំផ្លាញចោល តាមសេចក្តីសម្រេចរបស់តុលាការ ទោះជាមាន ឬគ្មានអ្នកណាម្នាក់ ត្រូវបានជាប់ទោស ចំពោះបទល្មើសនេះក៏ដោយ ។

**មាត្រា ៧០.-**

ជនណាដែលបានជរិត ឬបានទទួលនូវរបស់ ឬប្រាក់ ដោយប្រើអំណាចនៃមុខងាររបស់ខ្លួន ជននោះត្រូវចាត់ទុកថា បានប្រព្រឹត្តបទល្មើស ហើយនឹងត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

# ជំពូកទី ១៦
# អវសានប្បញ្ញត្តិ

**មាត្រា ៧១.-**

ម៉ាកដែលបានចុះបញ្ជីហើយ ត្រូវបានទទួលនូវការចុះបញ្ជីសាជាថ្មី ដោយស្របច្បាប់ ក្នុងរយៈពេលដូចគ្នានឹងមាត្រា ១១ និងមាត្រា ១២ ។ នៅពេលចុះបញ្ជីសាជាថ្មី មុខទំនិញត្រូវតែរៀបចំឡើងវិញឱ្យស្របទៅតាមចំណាត់ថ្នាក់អន្តរជាតិ ។

ទោះបីជាបទបញ្ជាទាំងឡាយដែលមានកន្លងមក ត្រូវទុកជានិរាករណ៍ក៏ដោយ ក៏ម៉ាកដែលបានចុះបញ្ជីក្រោមបទបញ្ជាទាំងឡាយនោះ ត្រូវនៅជាធរមាន ហើយអនុលោមតាមកថាខ័ណ្ឌទី ១ នៃមាត្រានេះ ត្រូវចាត់ទុកថាបានចុះបញ្ជីតាមច្បាប់នេះ ។

**មាត្រា ៧២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០២

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហនុ

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ហត្ថលេខា

ចម ប្រសិទ្ធ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៦៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការអនុវត្តច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និង អំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦/៩៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផលទំនិញ និងសេវា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០២/០០៦ ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០០៦

# សម្រេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១. – គោលបំណង**

អនុក្រឹត្យនេះមានគោលបំណងកំណត់ នីតិវិធីនៃការចុះបញ្ជីម៉ាក ការបដិសេធ ភ្នាក់ងារតំណាង ការប្រកាសសិទ្ធិជាអាទិភាព ការលុបម៉ាកចេញពីបញ្ជី និងវិធានការតាមមាត់ច្រកព្រំដែន សំដៅអនុវត្តច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២. – និយមន័យ**

វាក្យស័ព្ទដែលប្រើក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់និយមន័យដូចក្នុងឧបសម្ព័ន្ធភ្ជាប់ ។

## ជំពូកទី ២
## លក្ខខណ្ឌទូទៅ នៃការស្នើសុំចុះបញ្ជីម៉ាក

**មាត្រា ៣. – គំរូពាក្យស្នើសុំ**

គំរូពាក្យស្នើសុំ ដែលបោះពុម្ពរួចត្រូវចែកជូន ដល់អ្នកដាក់ពាក្យស្នើសុំដោយឥតគិតថ្លៃ ដោយមន្ត្រីកាន់កាប់បញ្ជី ។

គំរូពាក្យស្នើសុំ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងពាណិជ្ជកម្ម ។

**មាត្រា ៤. – ភាសាប្រើប្រាស់ក្នុងឯកសារដាក់ពាក្យស្នើសុំ និងការបកប្រែ**

តាមការតម្រូវនៃច្បាប់ ឬអនុក្រឹត្យនេះ ពាក្យស្នើសុំត្រូវធ្វើជាភាសាខ្មែរ ឬជាភាសាអង់គ្លេស ។ ឯកសារណាមួយ ដែលប្រើប្រាស់អមភ្ជាប់ជាមួយពាក្យស្នើសុំ ដែលបង្កើតជាផ្នែកមួយ នៃពាក្យស្នើសុំនោះ ឬ ឯកសារដែលបានដាក់ជូនទៅមន្ត្រីកាន់កាប់បញ្ជី ដែលប្រើប្រាស់ភាសាណាមួយ ក្រៅពីភាសាខ្មែរ ឬ ភាសាអង់គ្លេស ត្រូវភ្ជាប់មកជាមួយ នូវការបកប្រែជាភាសាខ្មែរ ឬ ភាសាអង់គ្លេស ។

**មាត្រា ៥. – ការបញ្ជាក់ឈ្មោះ អាសយដ្ឋាន សញ្ជាតិ និង និវេសនដ្ឋាន របស់អ្នកដាក់ពាក្យស្នើសុំ**

១-ឈ្មោះរបស់រូបវន្តបុគ្គល ត្រូវបញ្ជាក់ដោយនាមត្រកូល និងនាមខ្លួនរបស់បុគ្គលនោះ ឈ្មោះនីតិបុគ្គល ត្រូវបញ្ជាក់ដោយឈ្មោះពេញលេញ ជាផ្លូវការរបស់នីតិបុគ្គលនោះ ។

២-អាសយដ្ឋានរបស់អ្នកដាក់ពាក្យស្នើសុំ ត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់ ដើម្បីបំពេញតម្រូវការជាធម្មតាសម្រាប់សម្រួលដល់ការបញ្ជូនតាមប្រៃសណីយ៍ ។ ក្នុងករណីណាក៏ដោយ អាសយដ្ឋាន ត្រូវមានការបញ្ជាក់ផងដែរ នូវលេខផ្ទះ ទូរស័ព្ទ និង ទូរសារ ។

៣-សញ្ជាតិត្រូវបញ្ជាក់នូវឈ្មោះរដ្ឋ ឬប្រទេស ដែលបុគ្គលនោះជាពលរដ្ឋនៃរដ្ឋ ឬប្រទេសនោះ។ ចំពោះនីតិបុគ្គលត្រូវបញ្ជាក់ឈ្មោះរដ្ឋ ឬប្រទេស ដែលនីតិបុគ្គលនោះ ត្រូវបានបង្កើតឡើង តាមច្បាប់របស់រដ្ឋ ឬប្រទេសនោះ ព្រមទាំងការិយាល័យ របស់នីតិបុគ្គលនោះដែលបានចុះបញ្ជីរួច។

៤-និវេសនដ្ឋាន ត្រូវបញ្ជាក់នូវឈ្មោះរដ្ឋ ឬប្រទេស ដែលបុគ្គលនោះមានទីលំនៅជាអចិន្ត្រៃយ៍។

## មាត្រា ៦. – ហត្ថលេខាក្នុងនាមក្រុមហ៊ុនសហកម្មសិទ្ធិ ក្រុមហ៊ុនមូលធន និង សមាគម

១-ឯកសារដែលត្រូវចុះហត្ថលេខា ក្នុងនាមក្រុមហ៊ុនសហកម្មសិទ្ធិមួយ ត្រូវមានឈ្មោះរបស់ម្ចាស់ភាគហ៊ុនទាំងអស់ ជាឈ្មោះពេញលេញ និងត្រូវចុះហត្ថលេខា ដោយម្ចាស់ភាគហ៊ុនទាំងអស់ ឬដោយម្ចាស់ភាគហ៊ុនណាមួយ ដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ ដើម្បីចុះហត្ថលេខា ដោយមានបញ្ជាក់ថា ម្ចាស់ភាគហ៊ុននោះចុះហត្ថលេខា ក្នុងនាមក្រុមហ៊ុនសហកម្មសិទ្ធិ ឬដោយតតិយជនណាម្នាក់ដែលមន្ត្រី កាន់កាប់បញ្ជីទទួលស្គាល់ថា ជននោះត្រូវអនុញ្ញាតឱ្យចុះហត្ថលេខាលើឯកសារនោះ។ ឯកសារដែលត្រូវចុះហត្ថលេខា ក្នុងនាមក្រុមហ៊ុនមូលធន ជួសមុខឱ្យនីតិបុគ្គលមួយ ត្រូវចុះហត្ថលេខាដោយអភិបាលមួយរូប ឬដោយលេខាធិការ ឬមន្ត្រីសំខាន់ដទៃទៀត របស់នីតិបុគ្គលនោះ ឬចុះហត្ថលេខាដោយតតិយជនណាម្នាក់ ដែលមន្ត្រីកាន់កាប់បញ្ជីទទួលស្គាល់ថា ជននោះត្រូវអនុញ្ញាតឱ្យធ្វើការចុះហត្ថលេខាលើឯកសារនោះ ហើយឯកសារនោះត្រូវមានប្រថាប់ត្រា របស់នីតិបុគ្គលនោះផង។ ឯកសារដែលត្រូវចុះហត្ថលេខា ក្នុងនាមសមាគមមួយ ត្រូវចុះហត្ថលេខាដោយបុគ្គលណាម្នាក់ ដែលមន្ត្រីកាន់កាប់បញ្ជីទទួលស្គាល់ថា បុគ្គលនោះបានទទួលសិទ្ធិស្របច្បាប់ ដើម្បីចុះហត្ថលេខា ហើយត្រូវប្រថាប់ត្រារបស់សមាគមនោះផង។

២-នៅពេលចាំបាច់ មន្ត្រីកាន់កាប់បញ្ជី អាចស្នើសុំឱ្យផ្តល់ភស្តុតាងនៃការប្រគល់សិទ្ធិ ក្នុងការចុះហត្ថលេខានោះ ។

## មាត្រា ៧. – ភ្នាក់ងារតំណាង

លិខិតប្រគល់សិទ្ធិ ដែលចាត់តាំងភ្នាក់ងារតំណាងមួយឱ្យធ្វើការដាក់ពាក្យ អាចភ្ជាប់ជាមួយនឹងពាក្យស្នើសុំចុះបញ្ជី ឬ ត្រូវប្រគល់លិខិតប្រគល់សិទ្ធិនោះ ទៅឱ្យមន្ត្រីកាន់កាប់បញ្ជី ក្នុងរយៈពេល ០២ (ពីរ)ខែ គិតចាប់ពីកាលបរិច្ឆេទនៃការដាក់ពាក្យ។ ប្រសិនបើការប្រគល់សិទ្ធិនេះ មិនត្រូវបានធ្វើឡើង

និង ធ្វើឡើងមិនសមស្របតាមមាត្រា៥៨ និង មាត្រា៥៩ នៃច្បាប់ និង មាត្រា២៨ នៃអនុក្រឹត្យនេះទេនោះ ចំណាត់ការតាមនីតិវិធីណាមួយ ក្នុងការចុះបញ្ជី នឹងមិនត្រូវធ្វើឡើងឡើយ ។

**មាត្រា ៨. – កម្រៃផ្សេងៗ**

កម្រៃផ្សេងៗ ដែលតម្រូវតាមច្បាប់ ឬតាមអនុក្រឹត្យនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួង របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងពាណិជ្ជកម្ម ។

# ជំពូកទី ៣

# នីតិវិធីនៃការចុះបញ្ជីម៉ាក

# ការបដិសេធការចុះបញ្ជីម៉ាក និងការលុបម៉ាកចេញពីបញ្ជី

## ផ្នែកទី ១

## ពាក្យស្នើសុំចុះបញ្ជីម៉ាក នីតិវិធីនៃការចុះបញ្ជីម៉ាក និងការបោះពុម្ពផ្សាយ

**មាត្រា ៩. – ចំណាត់ថ្នាក់នៃម៉ាក**

ក្នុងការចុះបញ្ជី និងការបោះពុម្ពផ្សាយម៉ាក មន្ត្រីកាន់កាប់បញ្ជីត្រូវអនុវត្តតាម "ចំណាត់ថ្នាក់អន្តរជាតិ នៃទំនិញ និង សេវា នៃការចុះបញ្ជីម៉ាក" ដែលអនុម័តដោយកិច្ចព្រមព្រៀងទីក្រុង នីស ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ១៩៥៧ ហើយដែលចំណាត់ថ្នាក់នេះ បានធ្វើវិសោធនកម្មជាបន្តបន្ទាប់ ។

**មាត្រា ១០. – ការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក**

ការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកមួយ ត្រូវធ្វើឡើងតាមរយៈគំរូពាក្យស្នើសុំ ដូចមានចែងក្នុងប្រកាសរបស់ក្រសួងពាណិជ្ជកម្ម ហើយត្រូវចុះហត្ថលេខាដោយអ្នកស្នើសុំ ឬភ្នាក់ងារតំណាងស្របច្បាប់។ ពាក្យស្នើសុំមួយ អាចធ្វើឡើងសម្រាប់ការស្នើសុំចុះបញ្ជីម៉ាកមួយ ចំពោះទំនិញ ឬសេវាក្នុងចំណាត់ថ្នាក់មួយ ឬច្រើននៃចំណាត់ថ្នាក់អន្តរជាតិ។

ការប្រើប្រាស់ម៉ាកពុំមែនជាលក្ខខណ្ឌដែលតម្រូវ នៅពេលដាក់ពាក្យស្នើសុំ ចុះបញ្ជីម៉ាកឡើយ ។

**មាត្រា ១១. – ការផ្តល់គំរូម៉ាក**

១-ពាក្យស្នើសុំចុះបញ្ជី ត្រូវភ្ជាប់មកជាមួយនូវគំរូម៉ាក ក្រោមរូបភាពជាគំនូសក្រាផិចច្បាស់ និងមិនរលុប ដែលមានទំហំមិនលើសពី ៨សង្ទីម៉ែត្រ គុណ ៨សង្ទីម៉ែត្រ បិទភ្ជាប់ក្នុងចន្លោះកន្លែង

ដែលបានផ្តល់ជូន នៅលើគំរូពាក្យស្នើសុំចុះបញ្ជីម៉ាក ។ គ្រប់ករណីទាំងអស់ គំរូម៉ាកត្រូវពិពណ៌នាគ្រប់ចំណុចលំអិតទាំងអស់ ដែលចំណុចលំអិតទាំងនោះ អាចនឹងត្រូវទាមទារក្នុងពេលណាមួយដែលចាំបាច់ ដោយមន្ត្រីកាន់កាប់បញ្ជី ។ ប្រសិនបើ មានលក្ខខណ្ឌតម្រូវ ចំណុចលំអិតទាំងនោះ ត្រូវចុះហត្ថលេខា ដោយអ្នកស្នើសុំ ឬដោយភ្នាក់ងារតំណាង ដែលបានទទួលសិទ្ធិ។

២-គំរូម៉ាកបន្ថែមចំនួន ១៥ (ដប់ប្រាំ) ទៀត ត្រូវភ្ជាប់ជាមួយនឹងគ្រប់ពាក្យស្នើសុំចុះបញ្ជីម៉ាក។ គំរូម៉ាក ដែលបិទភ្ជាប់នៅលើពាក្យស្នើសុំ និងគំរូម៉ាកបន្ថែម ត្រូវមានលក្ខណៈដូចគ្នាបេះបិទ ។

៣-ប្រសិនបើ មន្ត្រីកាន់កាប់បញ្ជីយល់ថា គំរូម៉ាកណាមួយនៅមិនទាន់សមស្របសម្រាប់ការចុះបញ្ជី មន្ត្រីកាន់កាប់បញ្ជី អាចទាមទារឱ្យផ្តល់គំរូម៉ាកមួយទៀត ដែលសមស្រប ដើម្បីជំនួសគំរូចាស់។

៤-នៅពេលដែលគំរូ ឬការចម្លងឡើងវិញផ្សេងទៀត ពុំបានធ្វើឡើងតាមលក្ខណៈ ដូចបានពោលខាងលើនោះ គំរូម៉ាក ឬរូបភាពចម្លងនៃម៉ាក អាចនឹងត្រូវផ្តល់ក្រោមរូបភាព ជាទំហំពេញលេញ ឬ បំព្រួញ និងតាមទម្រង់មួយ ដែលមន្ត្រីកាន់កាប់បញ្ជីយល់ថាសមស្រប។

## មាត្រា ១២. – សម្លេងអាន និងការបកប្រែអត្ថន័យរបស់ម៉ាក

តាមការតម្រូវរបស់មន្ត្រីកាន់កាប់បញ្ជី ក្នុងករណីដែលម៉ាកមួយ មានពាក្យមួយព្យាង្គ ឬច្រើនព្យាង្គ ជាអក្សរ ក្រៅពីអក្សរខ្មែរ ឬអក្សររ៉ូម៉ាំង ការបំពេញពាក្យស្នើសុំតាមគំរូ ដូចមានចែងក្នុងប្រកាសរបស់ក្រសួងពាណិជ្ជកម្ម ហើយនិងការផ្តល់នូវគំរូម៉ាកបន្ថែម ត្រូវភ្ជាប់មកជាមួយផងដែរ នូវការសរសេរ សម្លេងអាន និងការបកប្រែអត្ថន័យរបស់ម៉ាកនោះ ឱ្យបានពេញលេញតាមពាក្យមួយព្យាង្គៗ ដោយបញ្ជាក់នូវភាសា ដែលពាក្យនីមួយៗនោះ ត្រូវបានប្រើប្រាស់ ។

## មាត្រា ១៣. – ការប្រកាសសិទ្ធិអាទិភាព និងការបកប្រែពាក្យស្នើសុំលើកដំបូង

១-អនុលោមតាមមាត្រា៦ នៃច្បាប់ ពាក្យស្នើសុំចុះបញ្ជីម៉ាក អាចអមមកជាមួយសេចក្តីប្រកាសទាមទារសិទ្ធិអាទិភាព នៃការដាក់ពាក្យស្នើសុំលើកដំបូង នៅក្រៅប្រទេស ក្នុងកម្រិតជាតិ ឬកម្រិតតំបន់ ដែលបានធ្វើឡើងដោយអ្នកដាក់ពាក្យស្នើសុំ ឬអ្នកទទួលសិទ្ធិ ដូចមានចែងក្នុងអនុសញ្ញាទីក្រុង ប៉ារីស ដែលផ្តល់សិទ្ធិអាទិភាពនៅក្នុងរដ្ឋណាមួយ ជាសមាជិករបស់អនុសញ្ញានោះ។ ក្នុងករណីនេះមន្ត្រីកាន់កាប់បញ្ជី អាចតម្រូវឱ្យអ្នកដាក់ពាក្យស្នើសុំផ្តល់ នូវច្បាប់ចម្លង នៃពាក្យស្នើសុំចុះបញ្ជីលើកដំបូងមួយច្បាប់ ដែលបានបញ្ជាក់ថា ត្រឹមត្រូវពីការិយាល័យទទួលពាក្យស្នើសុំចុះបញ្ជីនោះ ក្នុងរយៈពេលដែលបានកំណត់ក្នុងកថាខ័ណ្ឌ (៣) នៃមាត្រានេះ ។ អ្នកដាក់ពាក្យស្នើសុំចុះបញ្ជី ឬអ្នកទទួលសិទ្ធិរបស់គាត់ អាចធ្វើការទាមទារសិទ្ធិអាទិភាព ពីការចុះបញ្ជីលើកដំបូង ដែលបានធ្វើឡើង នៅក្នុងរដ្ឋ ឬប្រទេសណាមួយ ជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោកផងដែរ ។

២-ការប្រកាសអំពីសិទ្ធិអាទិភាព ដែលធ្វើឡើងតាមមាត្រា៦ នៃច្បាប់ និង មាត្រា១៣ កថាខ័ណ្ឌ (១) នៃអនុក្រឹត្យនេះ ត្រូវបញ្ជាក់នូវ ៖

ក- កាលបរិច្ឆេទដែលបានដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកលើកដំបូង

ខ- លេខដាក់ពាក្យនៃការស្នើសុំចុះបញ្ជីម៉ាកលើកដំបូង អនុលោមតាមកថាខ័ណ្ឌ (៣) ខាងក្រោមនៃមាត្រានេះ

គ- ឈ្មោះប្រទេស ដែលអ្នកស្នើសុំចុះបញ្ជីម៉ាក បានដាក់ពាក្យលើកដំបូង ឬ ក្នុងករណីដែលពាក្យស្នើសុំចុះបញ្ជីម៉ាកលើកដំបូង ទៅជាការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកក្រោមរូបភាពតំបន់ ឬ អន្តរជាតិ។ អ្នកដាក់ពាក្យស្នើសុំ ត្រូវបញ្ជាក់ឈ្មោះការិយាល័យ និង ឈ្មោះប្រទេស ដែលពាក្យស្នើសុំចុះបញ្ជីម៉ាកនោះ ត្រូវដាក់ ។

៣-ប្រសិនបើនៅពេលដាក់សេចក្តីប្រកាស ដែលបានចែងក្នុងកថាខ័ណ្ឌ (១) និង (២) ខាងលើ ហើយអ្នកដាក់ពាក្យពុំទាន់ដឹងលេខដាក់ពាក្យ នៃពាក្យស្នើសុំចុះបញ្ជីម៉ាកលើកដំបូងទេ អ្នកដាក់ពាក្យស្នើសុំ ត្រូវផ្តល់លេខដាក់ពាក្យនោះ ក្នុងរយៈពេល ០៣ (បី)ខែ គិតចាប់ពីកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក ដែលបានប្រកាសសុំសិទ្ធិអាទិភាពនោះ ។ ប្រសិនបើ អ្នកដាក់ពាក្យស្នើសុំផ្តល់ នូវភស្តុតាងគ្រប់គ្រាន់ ដែលបង្ហាញថា ការដែលគាត់ពុំអាចអនុវត្តបានត្រឹមត្រូវ តាមកាលកំណត់ខាងលើ ដោយសារមានកាលៈទេសៈជាឧបសគ្គមួយចំនួន ហួសពីសមត្ថភាពគ្រប់គ្រងរបស់គាត់ មន្ត្រីកាន់កាប់បញ្ជីអាចពន្យារពេល ០៣ (បី) ខែទៀតចំពោះកាលកំណត់ នៃការផ្តល់នូវលេខដាក់ពាក្យ ដែលមានចែងក្នុងកថាខ័ណ្ឌនេះ ។

៤-ក្នុងករណីមានការស្នើសុំសិទ្ធិអាទិភាព នៃការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកលើកដំបូង ចំនួន ០២ (ពីរ) ឬ ច្រើនជាង ដែលអនុលោមតាមកថាខ័ណ្ឌ (១) ខាងលើ ការបញ្ជាក់អំពីការដាក់ពាក្យស្នើសុំសិទ្ធិអាទិភាព អាចបញ្ចូល ក្នុងប្រកាសទាមទារសិទ្ធិអាទិភាព តែមួយបាន ។

៥-ប្រសិនបើមន្ត្រីកាន់កាប់បញ្ជីរកឃើញថា លក្ខខណ្ឌតម្រូវទាំងឡាយតាមមាត្រា៦ នៃច្បាប់ និង កថាខ័ណ្ឌ (១) (២) និង (៣) ខាងលើ មិនត្រូវបំពេញគ្រប់គ្រាន់ទេនោះ ការប្រកាសទាមទារសិទ្ធិអាទិភាព នឹងមិនត្រូវចាត់ទុកថា បានធ្វើឡើងទេឡើយ ។

៦-មុនពេលធ្វើការចុះបញ្ជីម៉ាក អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក អាចធ្វើការកែតម្រូវការប្រកាសទាមទារ សិទ្ធិអាទិភាពរបស់ខ្លួន ដែលធ្វើឡើងតាមកថាខ័ណ្ឌនានាខាងលើបាន ។

## មាត្រា ១៤. – ច្បាប់ចម្លងនៃការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកលើកដំបូង

អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក ត្រូវបានអនុញ្ញាតរយៈពេល ០៣ (បី)ខែ គិតចាប់ពីកាលបរិច្ឆេទនៃការទាមទាររបស់មន្ត្រីកាន់កាប់បញ្ជី ដើម្បីផ្តល់នូវច្បាប់ចម្លង នៃការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកលើកដំបូង ដោយមានការបញ្ជាក់នូវភាពត្រឹមត្រូវ ។

## មាត្រា ១៥. – ការដកពាក្យស្នើសុំចុះបញ្ជីម៉ាក

ការដកពាក្យស្នើសុំចុះបញ្ជីម៉ាក ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ដែលត្រូវចុះហត្ថលេខាដោយអ្នកដាក់ពាក្យស្នើសុំ ឬភ្នាក់ងារតំណាងស្របច្បាប់ ហើយត្រូវដាក់ជូនទៅមន្ត្រីកាន់កាប់បញ្ជី ។

កម្រៃនៃការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក នឹងមិនត្រូវផ្តល់ជូនវិញទេ ក្នុងករណីដែលមានការដកពាក្យស្នើសុំចុះបញ្ជីម៉ាក ទៅវិញនោះ ។

## មាត្រា ១៦. – ការកត់ត្រាពាក្យស្នើសុំចុះបញ្ជីម៉ាក និងកាលបរិច្ឆេទដាក់ពាក្យស្នើសុំ

១-មន្ត្រីកាន់កាប់បញ្ជី ត្រូវកត់ត្រានៅលើសំណុំឯកសារ នៃពាក្យស្នើសុំចុះបញ្ជីម៉ាកនីមួយៗនូវកាលបរិច្ឆេទពិតប្រាកដ និង លេខរៀងដាក់ពាក្យនៃពាក្យស្នើសុំចុះបញ្ជី ដោយមានសរសេរអក្សរ KH ភ្ជាប់នឹងរបាផ្ទៀង ហើយសរសេរលេខចំនួន ០៥ (ប្រាំ) ខ្ទង់យ៉ាងតិច ដែលកំណត់តាមលំដាប់លំដោយបន្តបន្ទាប់ ព្រមទាំងលេខចុងក្រោយពីរខ្ទង់នៃឆ្នាំ ដែលទទួលបានសំណុំឯកសារ ពាក្យស្នើសុំចុះបញ្ជីម៉ាកនោះ។ នៅពេលដែលមានការកែតម្រូវណាមួយ ឬនៅពេលដែលទទួលបានឯកសារដទៃទៀត ដែលដាក់ជូនក្នុងកាលបរិច្ឆេទខុសគ្នានោះ មន្ត្រីកាន់កាប់បញ្ជីត្រូវកត់ត្រាកាលបរិច្ឆេទជាក់ស្តែង នៃការទទួលឯកសារទាំងនោះ ។

២-លេខដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក ដែលបានកំណត់នៅក្នុងកថាខ័ណ្ឌ (១) ខាងលើ ត្រូវយកមកប្រើក្នុងគ្រប់ទំនាក់ទំនង ជាបន្តបន្ទាប់ ដែលពាក់ព័ន្ធនឹងការស្នើសុំចុះបញ្ជីម៉ាក ។

៣-មន្ត្រីកាន់កាប់បញ្ជី ត្រូវផ្តល់នូវកាលបរិច្ឆេទ នៃការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក នៅពេលពាក្យស្នើសុំចុះបញ្ជី បំពេញបាននូវព័ត៌មានគ្រប់គ្រាន់ និងត្រឹមត្រូវដូចខាងក្រោម ៖

- ក- ឈ្មោះរបស់អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក
- ខ- អាសយដ្ឋានទំនាក់ទំនង
- គ- គំរូម៉ាក ដែលស្នើសុំចុះបញ្ជី
- ឃ- យថាប្រភេទរបស់ទំនិញ ឬសេវា ដែលស្នើសុំចុះបញ្ជីក្នុងចំណាត់ថ្នាក់នីមួយៗ
- ង- កម្រៃនៃការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក ដែលតម្រូវសម្រាប់ចំណាត់ថ្នាក់នីមួយៗ នៃទំនិញ ឬសេវា ដែលស្នើសុំចុះបញ្ជីម៉ាក ។

៤-មន្ត្រីកាន់កាប់បញ្ជី ត្រូវចេញលិខិតទទួលស្គាល់ការដាក់ពាក្យ ជាលាយលក្ខណ៍អក្សរ ទៅអ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក នូវលេខរៀង និងកាលបរិច្ឆេទ នៃការដាក់ពាក្យស្នើសុំ ។

**មាត្រា ១៧. – ការច្រានចោលការដាក់ពាក្យស្នើសុំចុះបញ្ជី ឬការយល់ព្រមទទួលដោយមានលក្ខខណ្ឌចំពោះការចុះបញ្ជី និងសវនាការ**

១-នៅពេលពិនិត្យសំណុំឯកសារ ពាក្យស្នើសុំចុះបញ្ជីម៉ាក ដែលធ្វើឡើងតាមមាត្រា៨ (ក) នៃច្បាប់ ប្រសិនបើ មន្ត្រីកាន់កាប់បញ្ជីសម្រេចច្រានចោល ពាក្យស្នើសុំចុះបញ្ជីម៉ាកណាមួយ មន្ត្រីកាន់កាប់បញ្ជី ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ អំពីការច្រានចោលនោះ ទៅអ្នកដាក់ពាក្យស្នើសុំដោយភ្ជាប់នូវព័ត៌មានលំអិតទាំងអស់ ដែលពាក់ព័ន្ធនឹងសេចក្តីសម្រេចរបស់ខ្លួន ហើយស្នើឱ្យអ្នកដាក់ពាក្យស្នើសុំធ្វើការកែតម្រូវពាក្យស្នើសុំចុះបញ្ជីរបស់ខ្លួន និងធ្វើចម្លើយតបទៅមន្ត្រីកាន់កាប់បញ្ជី ជាលាយលក្ខណ៍អក្សរ ឬធ្វើការដាក់ពាក្យស្នើសុំធ្វើសវនាការ ក្នុងរយៈពេល ៤៥ (សែសិបប្រាំ) ថ្ងៃ គិតចាប់ពីពេលទទួលបានសេចក្តីជូនដំណឹងអំពី ការច្រានចោលនោះ ។ ប្រសិនបើ អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកមិនបានអនុវត្តទៅតាមកាលកំណត់ នៃការជូនដំណឹងនេះទេ អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកនោះ នឹងត្រូវចាត់ទុកថា បានដកពាក្យស្នើសុំចុះបញ្ជីម៉ាករបស់ខ្លួន ។

២-នៅពេលពិនិត្យខ្លឹមសារម៉ាក ដែលបានដាក់ពាក្យស្នើសុំចុះបញ្ជី ដោយធ្វើឡើងតាមមាត្រា៨ (ខ) នៃច្បាប់ ប្រសិនបើ មន្ត្រីកាន់កាប់បញ្ជីយល់ព្រមទទួលយកពាក្យស្នើសុំ ក្នុងលក្ខខណ្ឌនៃការកែតម្រូវ ការកែសម្រួល ការប្រកាសមិនទាមទារសិទ្ធិ លើចំណុចណាមួយរបស់ម៉ាក ឬការកម្រិតកំណត់សិទ្ធិ ឬ លក្ខខណ្ឌផ្សេងៗទៀត មន្ត្រីកាន់កាប់បញ្ជី ត្រូវជូនដំណឹងអំពីការសម្រេចរបស់ខ្លួនជាលាយលក្ខណ៍អក្សរ ទៅឱ្យអ្នកដាក់ពាក្យស្នើសុំ ។ ប្រសិនបើ អ្នកដាក់ពាក្យស្នើសុំចុះបញ្ជី មិនឯកភាពចំពោះការកែតម្រូវ ការកែសម្រួល ការប្រកាសមិនទាមទារសិទ្ធិ ឬការកម្រិតកំណត់នៃសិទ្ធិ ឬលក្ខខណ្ឌផ្សេងៗទៀត អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក អាចដាក់ពាក្យស្នើសុំធ្វើសវនាការ ឬផ្តល់នូវការយល់ឃើញរបស់ខ្លួន ជាលាយលក្ខណ៍អក្សរ ក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទទទួលបានសេចក្តីជូនដំណឹងពីមន្ត្រីកាន់កាប់បញ្ជី។ ប្រសិនបើ អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកឯកភាព ទៅនឹងសំណូមពរឱ្យធ្វើការកែតម្រូវ ការកែសម្រួល ការប្រកាសមិនទាមទារសិទ្ធិ ឬការកម្រិតកំណត់ នៃសិទ្ធិ ឬលក្ខខណ្ឌផ្សេងៗទៀត អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក ត្រូវជូនដំណឹងទៅមន្ត្រីកាន់កាប់បញ្ជីវិញ ជាលាយលក្ខណ៍អក្សរ ហើយធ្វើការកែតម្រូវពាក្យស្នើសុំរបស់ខ្លួន ទៅតាមសេចក្តីជូនដំណឹងខាងលើ។ ប្រសិនបើ អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក មិនធ្វើការឆ្លើយតបតាមកាលកំណត់ និងតាមវិធីណាមួយក្នុងចំណោមវិធីខាងលើ អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក ត្រូវចាត់ទុកថា បានបោះបង់ចោលពាក្យស្នើសុំចុះបញ្ជីម៉ាករបស់ខ្លួន ។

៣-ការស្នើសុំធ្វើសវនាការមួយ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ដោយផ្ញើជូនទៅមន្ត្រីកាន់កាប់បញ្ជី។ នៅពេលដែលទទួលបានពាក្យស្នើសុំនេះ មន្ត្រីកាន់កាប់បញ្ជី ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ទៅអ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកយ៉ាងយូរ ០១ (មួយ)ខែ មុនកាលបរិច្ឆេទ ដែលអ្នកដាក់ពាក្យស្នើសុំចុះបញ្ជី ត្រូវអញ្ជើញមកចូលរួមក្នុងសវនាការ ។

## មាត្រា ១៨. – ការបដិសេធពាក្យស្នើសុំចុះបញ្ជី ឬ ការយល់ព្រម ដោយមានលក្ខខណ្ឌរបស់មន្ត្រីកាន់កាប់បញ្ជី ដែលអ្នកដាក់ពាក្យស្នើសុំធ្វើការជំទាស់

១-បន្ទាប់ពីសវនាការ ឬបន្ទាប់ពីការពិនិត្យពិចារណា លើការស្នើសុំកែតម្រូវ ឬការផ្តល់យោបល់ជាលាយលក្ខណ៍អក្សរ ពីអ្នកដាក់ពាក្យស្នើសុំចុះបញ្ជី ប្រសិនបើ មន្ត្រីកាន់កាប់បញ្ជីនៅតែបដិសេធការចុះបញ្ជី ឬយល់ព្រមចុះបញ្ជី ដោយមានលក្ខខណ្ឌឱ្យមានការកែតម្រូវ ការកែសម្រួល ការឈប់ទាមទារសិទ្ធិ ឬការកម្រិតកំណត់សិទ្ធិ ឬលក្ខខណ្ឌផ្សេងៗទៀត ហើយអ្នកដាក់ពាក្យស្នើសុំចុះបញ្ជី នៅតែមិនយល់ព្រមទៅនឹងការច្រានចោល ឬការយល់ព្រមទទួលចុះបញ្ជីជូនដោយមានលក្ខខណ្ឌ មន្ត្រីកាន់កាប់បញ្ជី ត្រូវបដិសេធជាលាយលក្ខណ៍អក្សរ ទៅអ្នកដាក់ពាក្យស្នើសុំ អំពីសេចក្តីសម្រេចរបស់ខ្លួន ។ ក្នុងរយៈពេល ០១ (មួយ) ខែ ចាប់ពីកាលបរិច្ឆេទនៃការផ្តល់សេចក្តីជូនដំណឹងនេះ អ្នកដាក់ពាក្យស្នើសុំចុះបញ្ជី អាចស្នើសុំឱ្យមន្ត្រីកាន់កាប់បញ្ជី ធ្វើការបញ្ជាក់ជាលាយលក្ខណ៍អក្សរ អំពីមូលហេតុដែលនាំឱ្យឈានដល់សេចក្តីសម្រេចរបស់ខ្លួន ព្រមទាំងឯកសារយោងទាំងឡាយ ដែលប្រើប្រាស់នៅក្នុងការធ្វើសេចក្តីសម្រេចនេះ ។

២-អ្នកដាក់ពាក្យស្នើសុំចុះបញ្ជី មានសិទ្ធិប្តឹងតវ៉ា អំពីការបដិសេធមិនព្រមចុះបញ្ជី របស់មន្ត្រីកាន់កាប់បញ្ជី ទៅក្រុមប្រឹក្សាដោះស្រាយបណ្តឹងតវ៉ា នៃក្រសួងពាណិជ្ជកម្ម ឬទៅតុលាការមានសមត្ថកិច្ច ក្នុងរយៈពេល ០៣ (បី) ខែ គិតចាប់ពីថ្ងៃចេញសេចក្តីសម្រេច របស់មន្ត្រីកាន់កាប់បញ្ជី ។

៣-អនុលោមតាមមាត្រា៦២ នៃច្បាប់ ភាគីមានផលប្រយោជន៍ មានសិទ្ធិប្តឹងតវ៉ា អំពីសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាដោះស្រាយបណ្តឹងតវ៉ា នៃក្រសួងពាណិជ្ជកម្មទៅតុលាការមានសមត្ថកិច្ច ក្នុងរយៈពេល ០៣ (បី) ខែ គិតចាប់ពីថ្ងៃចេញសេចក្តីសម្រេច របស់ក្រុមប្រឹក្សាបណ្តឹងតវ៉ា។

## មាត្រា ១៩. – ការយល់ព្រមចំពោះការដាក់ពាក្យស្នើសុំចុះបញ្ជី ការចុះបញ្ជីម៉ាក ការបោះពុម្ពផ្សាយ និង ការចេញវិញ្ញាបនបត្រ

១-ប្រសិនបើ មន្ត្រីកាន់កាប់បញ្ជីយល់ព្រម ចំពោះការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក ដោយមាន ឬ គ្មានលក្ខខណ្ឌ ឬការកម្រិតកំណត់ណាមួយ ដែលលក្ខខណ្ឌ និងការកំណត់ទាំងនោះ ត្រូវបានយល់ព្រមដោយអ្នកដាក់ពាក្យស្នើសុំចុះបញ្ជី មន្ត្រីកាន់កាប់បញ្ជីត្រូវចុះបញ្ជីម៉ាក និងចេញវិញ្ញាបនបត្រ នៃការ

ចុះបញ្ជីម៉ាកជូនអ្នកដាក់ពាក្យស្នើសុំចុះបញ្ជី ហើយត្រូវបោះពុម្ពផ្សាយការចុះបញ្ជីម៉ាកនោះ នៅក្នុងព្រឹត្តិបត្រផ្លូវការរបស់ក្រសួងពាណិជ្ជកម្ម ។

២-មន្ត្រីកាន់កាប់បញ្ជី ត្រូវផ្តល់នូវលេខរៀងមួយតាមលំដាប់លំដោយ នៃការចុះបញ្ជីម៉ាកនៅលើវិញ្ញាបនបត្រចុះបញ្ជី ។

៣-ការចុះបញ្ជីម៉ាកមួយត្រូវមាន ៖

ក- គំរូម៉ាក ដែលត្រូវបានចុះបញ្ជី

ខ- លេខដាក់ពាក្យ និង លេខចុះបញ្ជី

គ- ឈ្មោះ និង អាសយដ្ឋានរបស់ម្ចាស់ម៉ាក ដែលស្នើសុំចុះបញ្ជី

ឃ- ឈ្មោះ និង អាសយដ្ឋានរបស់ភ្នាក់ងារតំណាង ( ប្រសិនបើមាន)

ង- កាលបរិច្ឆេទនៃការដាក់ពាក្យ និងកាលបរិច្ឆេទនៃការចុះបញ្ជី

ច- ប្រសិនបើសិទ្ធិអាទិភាពត្រូវបានទាមទារ ហើយការទាមទារសិទ្ធិនោះត្រូវបានយល់ព្រម ត្រូវបញ្ជាក់ឈ្មោះ រដ្ឋ ឬប្រទេស និងលេខដាក់ពាក្យដែលបានដាក់ពាក្យស្នើសុំលើកដំបូង ។

ឆ- ចំណាត់ថ្នាក់ និង ទំនិញ ឬសេវាដែលជាកម្មវត្ថុនៃការចុះបញ្ជីម៉ាក ដោយមានបញ្ជាក់អំពីចំណាត់ថ្នាក់នៃទំនិញ ឬសេវានោះ ស្របតាមចំណាត់ថ្នាក់អន្តរជាតិ ។

៤-ការបោះពុម្ពផ្សាយការចុះបញ្ជីម៉ាកមួយ ដែលបានកំណត់ក្នុងកថាខណ្ឌ (១) ខាងលើ ត្រូវមានព័ត៌មានមួយចំនួនដូចតទៅ ៖

ក- កាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក និង កាលបរិច្ឆេទនៃសិទ្ធិអាទិភាព ( ប្រសិន បើមាន)

ខ- គំរូម៉ាក ដែលបានចុះបញ្ជី

គ- លេខដាក់ពាក្យ និង លេខចុះបញ្ជី

ឃ- ចំណាត់ថ្នាក់ និង ទំនិញ ឬ សេវា ដែលជាកម្មវត្ថុនៃការចុះបញ្ជីម៉ាក ដោយមានបញ្ជាក់អំពីចំណាត់ថ្នាក់នៃទំនិញ ឬសេវានោះ ស្របតាមចំណាត់ថ្នាក់អន្តរជាតិ

ង- ឈ្មោះ និងអាសយដ្ឋានរបស់ម្ចាស់ម៉ាក ដែលបានចុះបញ្ជី

ច- ឈ្មោះ និងអាសយដ្ឋានរបស់ភ្នាក់ងារតំណាង ( ប្រសិនបើមាន) ។

## មាត្រា ២០. – បណ្ដឹងជំទាស់

១-ក្នុងរយៈពេល ៩០ (កៅសិប) ថ្ងៃ គិតចាប់តាំងពីកាលបរិច្ឆេទ នៃការបោះពុម្ពផ្សាយ ដូចមាន ចែងក្នុងមាត្រា១៩នៃអនុក្រឹត្យនេះរាល់លិខិតជំទាស់របស់ជនណា ដែលមានការពាក់ព័ន្ធនឹងការ ចុះបញ្ជីម៉ាក តាមមាត្រា១០ (គ) នៃច្បាប់ ត្រូវធ្វើឡើងតាមគំរូដែលកំណត់ ដោយក្រសួងពាណិជ្ជកម្ម ព្រមទាំងភ្ជាប់មកជាមួយនូវឯកសារគាំទ្រនានាជាភស្តុតាងផង ។

២-អនុលោមតាមមាត្រា១០ (ង) នៃច្បាប់ ក្នុងរយៈពេល ៩០ (កៅសិប) ថ្ងៃ គិតពីកាល បរិច្ឆេទ នៃការជូនដំណឹងពីបណ្ដឹងជំទាស់ អ្នកដាក់ពាក្យស្នើសុំចុះបញ្ជី ត្រូវផ្ដល់អំណះអំណាងជាចម្លើយ តបវិញ ជាលាយលក្ខណ៍អក្សរ ដោយបញ្ជាក់ពីហេតុផលជាមូលដ្ឋាន ក្នុងការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក របស់ខ្លួន និងមានភ្ជាប់មកជាមួយនូវឯកសារគាំទ្រនានាជាភស្តុតាងផង ។

## មាត្រា ២១. – សេចក្ដីប្រកាសអំពីការប្រើប្រាស់ ឬមិនបានប្រើប្រាស់ម៉ាក និង ភស្តុតាង

១-ដើម្បីរក្សាសុពលភាពនៃការចុះបញ្ជីម៉ាក ឬការចុះបញ្ជីម៉ាកសាឡើងវិញ ម្ចាស់ម៉ាក ដែលបានចុះបញ្ជីរួច ត្រូវប្រកាសអំពីការប្រើប្រាស់ម៉ាក ឬមិនបានប្រើប្រាស់ម៉ាកក្នុងរយៈពេល ០១ (មួយ) ឆ្នាំ បន្ទាប់ពីខួបលើកទី ៥ (ប្រាំ) នៃកាលបរិច្ឆេទចុះបញ្ជីម៉ាក ។

២-នៅពេលម៉ាក ត្រូវបានចុះបញ្ជីសាឡើងវិញ ម្ចាស់ម៉ាកត្រូវប្រកាសអំពីការប្រើប្រាស់ម៉ាក ឬ មិនបានប្រើប្រាស់ម៉ាករបស់ខ្លួន ក្នុងរយៈពេល ០១ (មួយ) ឆ្នាំ បន្ទាប់ពីខួបលើកទី ០៥ (ប្រាំ) នៃកាលបរិច្ឆេទចុះបញ្ជីសាឡើងវិញ ។

៣-សេចក្ដីប្រកាសអំពីការប្រើប្រាស់ ឬមិនបានប្រើប្រាស់ម៉ាក ត្រូវធ្វើឡើងតាមគំរូដែលបាន កំណត់ ដោយក្រសួងពាណិជ្ជកម្ម និងត្រូវបង់កម្រៃតាមប្រកាសអន្តរក្រសួង របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រសួងពាណិជ្ជកម្ម ។

៤-ម៉ាកដែលបានចុះបញ្ជីរួច នឹងត្រូវលុបចេញពីបញ្ជីវិញ ក្នុងករណីដែលម្ចាស់ម៉ាក ឬភ្នាក់ងារ តំណាងខកខានមិនបានប្រកាស អំពីការប្រើប្រាស់ ឬមិនបានប្រើប្រាស់ម៉ាកនោះ ដូចដែលបានកំណត់ក្នុង កថាខណ្ឌ (១) ខាងលើ ។

## មាត្រា ២២. – ការចុះបញ្ជីម៉ាកសាជាថ្មីឡើងវិញ

១-ពាក្យស្នើសុំចុះបញ្ជីម៉ាកសាជាថ្មីឡើងវិញ តាមមាត្រា១២ (ខ) នៃច្បាប់ អាចធ្វើឡើង ក្នុងរយៈពេល ០៦ (ប្រាំមួយ) ខែ មុនពេលផុតសុពលភាព នៃការចុះបញ្ជីម៉ាក ហើយពាក្យស្នើសុំចុះបញ្ជី សាជាថ្មីឡើងវិញនេះ ត្រូវចុះហត្ថលេខាដោយម្ចាស់ម៉ាក ដែលបានចុះបញ្ជីរួច ឬដោយភ្នាក់ងារតំណាង របស់ខ្លួន ។

២-ការចុះបញ្ជីម៉ាកសាជាថ្មីឡើងវិញ អាចធ្វើឡើងបាន ដោយមានការទូទាត់កម្រៃនៃការចុះបញ្ជីម៉ាកសាជាថ្មីឡើងវិញ ដែលត្រូវធ្វើនៅក្នុងរយៈពេលកំណត់ ដូចមានចែងនៅក្នុងកថាខ័ណ្ឌ (១) ខាងលើ ឬ ធ្វើឡើងក្នុងរយៈពេលនៃការអនុគ្រោះ ដែលអនុញ្ញាតដោយមាត្រា១២ (ឃ) នៃច្បាប់ ។

៣-ការចុះបញ្ជីម៉ាកសាជាថ្មីឡើងវិញ ត្រូវតែកត់ត្រានៅក្នុងបញ្ជីម៉ាក ហើយត្រូវបោះពុម្ពផ្សាយក្នុងព្រឹត្តិបត្រផ្លូវការ ។

៤-មន្ត្រីកាន់កាប់បញ្ជីត្រូវចេញវិញ្ញាបនបត្រ នៃការចុះបញ្ជីម៉ាកសាជាថ្មីឡើងវិញ ទៅឱ្យម្ចាស់ម៉ាក ដែលបានចុះបញ្ជីរួច ហើយវិញ្ញាបនបត្រនោះត្រូវមានព័ត៌មានដូចខាងក្រោម :

ក- លេខចុះបញ្ជីដើមរបស់ម៉ាក

ខ- គំរូម៉ាក

គ- កាលបរិច្ឆេទនៃការចុះបញ្ជីម៉ាកសាជាថ្មីឡើងវិញ និងកាលបរិច្ឆេទផុតកំណត់

ឃ- ឈ្មោះ និង អាសយដ្ឋានរបស់ម្ចាស់ម៉ាក ដែលបានចុះបញ្ជីរួច

ង- ឈ្មោះ និង អាសយដ្ឋានរបស់ភ្នាក់ងារតំណាង (ប្រសិនមាន)

ច- ទំនិញ ឬសេវា ដែលជាកម្មវត្ថុនៃការចុះបញ្ជីម៉ាក ដោយមានការបញ្ជាក់អំពីចំណាត់ថ្នាក់ នៃទំនិញ ឬសេវាស្របតាមចំណាត់ថ្នាក់អន្តរជាតិ ។

## ផ្នែកទី ២

## ម៉ាកសមូហភាព និងមោឃភាពនៃការចុះបញ្ជី

### មាត្រា ២៣. – ម៉ាកសមូហភាព

មាត្រា៩ រហូតដល់មាត្រា២២ នៃអនុក្រឹត្យនេះ ត្រូវយកមកអនុវត្តចំពោះម៉ាកសមូហភាព តាមលក្ខខណ្ឌតម្រូវមួយចំនួនដូចខាងក្រោម ៖

១-ការទទួលយកពាក្យស្នើសុំចុះបញ្ជីម៉ាកសមូហភាព លុះត្រាតែនៅក្នុងពាក្យស្នើសុំចុះបញ្ជីនោះត្រូវកំណត់ថា ជាម៉ាកសមូហភាព និងមានភ្ជាប់មកជាមួយ នូវច្បាប់ចម្លងនៃបទបញ្ជារួមគ្រប់គ្រងការប្រើប្រាស់ម៉ាកនោះមួយច្បាប់ ដោយមានការបញ្ជាក់ត្រឹមត្រូវ ពីអ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក ។ ការបញ្ជាក់ ដែលធ្វើឡើង ដោយអ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក នោះពុំចាំបាច់តម្រូវឱ្យមានការធ្វើនីត្យានុកូលកម្ម ណាមួយឡើយ ។

២-បទបញ្ជារួមស្ដីពីការគ្រប់គ្រងការប្រើប្រាស់ម៉ាកសមូហភាព ត្រូវកំណត់នូវលក្ខណៈរួម ឬគុណភាពរបស់ទំនិញ ឬសេវាដែលម៉ាកសមូហភាពនោះ ត្រូវជ្រើសរើសយកទៅប្រើប្រាស់ ព្រមទាំង

លក្ខខណ្ឌទាំងឡាយ ដែលបុគ្គលប្រើប្រាស់ម៉ាកសមូហភាពនោះ ត្រូវធ្វើតាម ។ បទបញ្ជានោះត្រូវផ្តល់នូវការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាព ចំពោះការប្រើប្រាស់ម៉ាកសមូហភាព ដោយស្របទៅតាមប្រការនានានៃបទបញ្ជានោះ ហើយត្រូវកំណត់នូវទណ្ឌកម្មសមល្មម ចំពោះរាល់ការប្រើប្រាស់ដែលផ្ទុយទៅនឹងបទបញ្ជានោះ ។

៣-ច្បាប់ចម្លងមួយច្បាប់ នៃបទបញ្ជារួមស្តីពីការគ្រប់គ្រងការប្រើប្រាស់ម៉ាកសមូហភាព ត្រូវភ្ជាប់បន្ថែមមកជាមួយនឹងការចុះបញ្ជីម៉ាកសមូហភាពមួយ ។

៤-ការបោះពុម្ពផ្សាយការចុះបញ្ជីម៉ាកសមូហភាព តាមមាត្រា១៩ (១) នៃអនុក្រឹត្យនេះ ត្រូវរួមបញ្ចូលសេចក្តីសង្ខេបនៃបទបញ្ជារួម ស្តីពីការគ្រប់គ្រងការប្រើប្រាស់ម៉ាកសមូហភាព ដែលបានភ្ជាប់បន្ថែមទៅនឹងការចុះបញ្ជីម៉ាកសមូហភាព ។

៥-សេចក្តីជូនដំណឹងអំពីការផ្លាស់ប្តូរព័ត៌មាននានា ដែលប៉ះពាល់ដល់បទបញ្ជារួម ស្តីពីការគ្រប់គ្រងការប្រើប្រាស់ម៉ាកសមូហភាព ចាំបាច់ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ។

៦-គ្រប់សេចក្តីជូនដំណឹង អំពីការផ្លាស់ប្តូរព័ត៌មានបែបនេះ ចាំបាច់ត្រូវកត់ត្រានៅក្នុងបញ្ជីម៉ាក ។ រាល់ការផ្លាស់ប្តូរព័ត៌មានទាំងឡាយណា នៅក្នុងបទបញ្ជារួម ស្តីពីការគ្រប់គ្រងការប្រើប្រាស់ម៉ាក នឹងពុំមានប្រសិទ្ធភាពជាធរមានទេ រហូតទាល់តែការកត់ត្រានេះត្រូវបានធ្វើឡើង ។ សេចក្តីសង្ខេបអំពីការផ្លាស់ប្តូរព័ត៌មាន ដែលបានកត់ត្រារួច ចាំបាច់ត្រូវបោះពុម្ពផ្សាយជាសាធារណៈ ។

៧-ក្នុងគោលបំណងនៃការប្រើប្រាស់ម៉ាកសមូហភាព ដែលទាក់ទងនឹងមាត្រា១៥ និង មាត្រា១៦ នៃច្បាប់ ម្ចាស់ម៉ាកសមូហភាពដែលបានចុះបញ្ជីរួច អាចប្រើប្រាស់ម៉ាកសមូហភាពនោះ ដោយខ្លួនឯងបាន លុះត្រាតែម៉ាកនោះ ត្រូវបានប្រើប្រាស់ផងដែរដោយបុគ្គលដទៃទៀត ដែលបានទទួលសិទ្ធិតាមបទបញ្ជារួម ស្តីពីការគ្រប់គ្រងការប្រើប្រាស់ម៉ាកនេះ។ ការប្រើប្រាស់ម៉ាកសមូហភាព ដោយបុគ្គលទាំងនោះ ត្រូវបានចាត់ទុកថា ម៉ាកនោះបានប្រើប្រាស់ ដោយម្ចាស់ម៉ាកដែលបានចុះបញ្ជីរួច ។

## មាត្រា ២៤. – មោឃភាព និង ការលុបម៉ាកចេញពីបញ្ជីដោយផ្អែកលើការមិនបានប្រើប្រាស់

១-អនុលោមតាមមាត្រា១០ (គ) មាត្រា១៣ និង មាត្រា១៥ នៃច្បាប់ ភាគីដែលមានផលប្រយោជន៍ មានសិទ្ធិដាក់ពាក្យស្នើសុំមោឃភាព ចំពោះការចុះបញ្ជីម៉ាក ទោះផុតកំណត់រយៈពេល ៩០ (កៅសិប) ថ្ងៃ បន្ទាប់ពីការបោះពុម្ពផ្សាយ ក្នុងព្រឹត្តិបត្រផ្លូវការក៏ដោយ។

២-អនុលោមតាមមាត្រា១៣ (ខ) នៃច្បាប់ មន្ត្រីកាន់កាប់បញ្ជី មានសិទ្ធិលុបម៉ាកចេញពីបញ្ជី នៅពេលម្ចាស់ម៉ាកដែលបានចុះបញ្ជី មិនបានបំពេញតាមលក្ខខណ្ឌណាមួយ នៃមាត្រា២ ចំណុច "ក" និង មាត្រា៤ នៃច្បាប់។

៣-អនុលោមតាមមាត្រា១៤ (ង) មាត្រា២២ មាត្រា២៣ និង មាត្រា២៨ នៃច្បាប់ ម៉ាកមួយត្រូវបានលុបចេញពីបញ្ជី នៅពេលម្ចាស់ម៉ាក ឬអ្នកទទួលសិទ្ធិបានប្រើប្រាស់ម៉ាកនោះ ខុសទម្រង់ដើមដែលបានចុះបញ្ជី ហើយរំលោភបំពានទៅលើម៉ាករបស់អ្នកផ្សេង ដែលបានចុះបញ្ជីរួច។

៤-អនុលោមតាមមាត្រា៤ (ង) មាត្រា១៤ (ង) មាត្រា២២ មាត្រា២៣ និង មាត្រា២៨ នៃច្បាប់ ម៉ាកមួយ ត្រូវបានលុបចេញពីបញ្ជីនៅពេលម្ចាស់ម៉ាកនោះ ឬអ្នកទទួលសិទ្ធិបានបន្ថែមស្លាកសញ្ញា ដូចឬស្រដៀង ធ្វើឱ្យភន្ត័ច្រឡំ ទៅនឹងស្លាកសញ្ញាល្បីរបស់អ្នកផ្សេង ដែលបានប្រើប្រាស់មុន ។

៥-ការលុបម៉ាកមួយចេញពីបញ្ជី ចាំបាច់ត្រូវតែបោះពុម្ពផ្សាយក្នុងព្រឹត្តិបត្រផ្លូវការ។

៦-មានតែការលុបម៉ាកចេញពីបញ្ជី ដោយផ្អែកលើមូលហេតុមិនបានប្រកាស អំពីការប្រើប្រាស់ឬមិនបានប្រើប្រាស់ម៉ាកតែម្យ៉ាងគត់ ដែលត្រូវបានអនុញ្ញាតឱ្យចុះបញ្ជីឡើងវិញ តាមការស្នើសុំរបស់ម្ចាស់ម៉ាក ឬភ្នាក់ងារតំណាងក្នុងរយៈពេលមិនលើសពី ៦០ (ហុកសិប) ថ្ងៃ គិតពីថ្ងៃសម្រេចលុប។

៧-ក្រោយពីមានសេចក្តីសម្រេច របស់មន្ត្រីកាន់កាប់បញ្ជី អំពីការផ្តល់មោឃភាពនៃការចុះបញ្ជី ឬរក្សាទុកការចុះបញ្ជី ឬមួយសម្រេចឱ្យកែតម្រូវម៉ាកដែលបានចុះបញ្ជី បើភាគីណាមួយមិនយល់ព្រមនឹងសេចក្តីសម្រេចនោះ អាចប្តឹងតវ៉ាទៅក្រុមប្រឹក្សាដោះស្រាយបណ្តឹងតវ៉ា របស់ក្រសួងពាណិជ្ជកម្ម ឬប្តឹងទៅតុលាការមានសមត្ថកិច្ច ក្នុងរយៈពេល ០៣ (បី) ខែ បន្ទាប់ពីថ្ងៃចេញសេចក្តីសម្រេច។

៨-អនុលោមតាមមាត្រា៦២ នៃច្បាប់ ភាគីមានផលប្រយោជន៍ មានសិទ្ធិប្តឹងតវ៉ា អំពីសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាដោះស្រាយបណ្តឹងតវ៉ា របស់ក្រសួងពាណិជ្ជកម្ម ទៅតុលាការមានសមត្ថកិច្ច ក្នុងរយៈពេល ០៣ (បី) ខែ បន្ទាប់ពីថ្ងៃចេញសេចក្តីសម្រេច។

៩-ការបង្កើតក្រុមប្រឹក្សាប្តឹងតវ៉ា សមាសភាព និង ដែនអំណាចនៃក្រុមប្រឹក្សាប្តឹងតវ៉ា និងនីតិវិធីដោះស្រាយទំនាស់នឹងត្រូវកំណត់ ដោយប្រកាសរបស់ក្រសួងពាណិជ្ជកម្ម។

១០-អនុលោមតាមមាត្រា៦២ នៃច្បាប់ នៅពេលតុលាការសម្រេចលើបណ្តឹងតវ៉ា តម្រូវឱ្យលុបម៉ាកចេញពីបញ្ជី ឬរក្សាទុក ឬកែតម្រូវម៉ាក មន្ត្រីកាន់កាប់បញ្ជី ត្រូវអនុវត្តតាមសេចក្តីសម្រេចនោះ ។

## ផ្នែកទី ៣

## ការកំណត់បែបបទរដ្ឋបាលសម្រួលដល់ការចុះបញ្ជី និងការដោះស្រាយ វិវាទ ព្រមទាំងការផ្ទេរសិទ្ធិ

### មាត្រា ២៥. – អាសយដ្ឋានសម្រាប់ទាក់ទង

អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក ចាំបាច់ត្រូវផ្តល់មកឱ្យមន្ត្រីកាន់កាប់បញ្ជី នូវអាសយដ្ឋានសម្រាប់ទាក់ទងនៅក្នុងប្រទេសកម្ពុជា ដែលប្រើប្រាស់ក្នុងគោលបំណងនៃការដាក់ពាក្យ។

ជនទាំងឡាយណា ដែលពាក់ពន្ធ័នឹងកិច្ចការនានាទាក់ទងនឹងម៉ាក ត្រូវផ្តល់អាសយដ្ឋានទាក់ទង ក្នុងប្រទេសកម្ពុជាដល់មន្ត្រីកាន់កាប់បញ្ជី។

**មាត្រា ២៦. – ការផ្លាស់ប្តូរឈ្មោះ អាសយដ្ឋាន ឬ អាសយដ្ឋានសម្រាប់ទាក់ទង**

១-ការស្នើសុំប្តូរឈ្មោះ សញ្ជាតិ អាសយដ្ឋាន ឬអាសយដ្ឋានសម្រាប់ទាក់ទង ចំពោះពាក្យស្នើសុំចុះបញ្ជីម៉ាក ឬម៉ាកដែលបានចុះបញ្ជីរួច ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយត្រូវទូទាត់កម្រៃ ដូចមានចែងក្នុងប្រកាសអន្តរក្រសួងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម ។

២-មុនពេលអនុវត្តតាមសំណើនៃការសុំប្តូរឈ្មោះ សញ្ជាតិ អាសយដ្ឋាន ឬ អាសយដ្ឋាន ទាក់ទង មន្ត្រីកាន់កាប់បញ្ជីត្រូវទាមទាររកភស្តុតាងនៃការសុំប្តូរនោះ។

៣-ប្រសិនបើសំណើសុំប្តូរឈ្មោះ សញ្ជាតិ អាសយដ្ឋាន ឬអាសយដ្ឋានសម្រាប់ទាក់ទង ត្រូវបានអនុញ្ញាត មន្ត្រីកាន់កាប់បញ្ជី ត្រូវធ្វើការកែតម្រូវ ពាក្យស្នើសុំចុះបញ្ជីម៉ាក ឬកត់ត្រាក្នុងបញ្ជីដើមនៃម៉ាក និង កត់ត្រាក្នុងបញ្ជីម៉ាក។

**មាត្រា ២៧. – ការប្តូរម្ចាស់កម្មសិទ្ធិ កិច្ចសន្យាផ្តល់អាជ្ញាប័ណ្ណ**

១-សំណើសុំប្តូរម្ចាស់កម្មសិទ្ធិ ដែលអនុញ្ញាតដោយច្បាប់តាមមាត្រា៤៨ ត្រូវធ្វើឡើងតាមគំរូដែលមានចែងក្នុងប្រកាសរបស់ក្រសួងពាណិជ្ជកម្ម រួចផ្ញើជូនមកមន្ត្រីកាន់កាប់បញ្ជី ដោយត្រូវទូទាត់កម្រៃ ដូចមានចែងក្នុងប្រកាសអន្តរក្រសួងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម ។

២-ការបោះពុម្ពផ្សាយជាសាធារណៈ អំពីការប្តូរម្ចាស់កម្មសិទ្ធិ ត្រូវបញ្ជាក់នូវព័ត៌មានដូចតទៅ៖

- ក- ម៉ាក ដែលពាក់ព័ន្ធនឹងការប្តូរម្ចាស់កម្មសិទ្ធិនេះ
- ខ- លេខដាក់ពាក្យ និង លេខចុះបញ្ជី
- គ- កាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក កាលបរិច្ឆេទទាមទារសិទ្ធិអាទិភាព (ប្រសិនបើមាន) និងកាលបរិច្ឆេទនៃការចុះបញ្ជីម៉ាក
- ឃ- ឈ្មោះ អាសយដ្ឋានម្ចាស់ម៉ាកដើម និង ឈ្មោះ អាសយដ្ឋានម្ចាស់ម៉ាកថ្មី ដែលពាក់ព័ន្ធ នឹងការប្តូរម្ចាស់កម្មសិទ្ធិនេះ
- ង- ថ្ងៃ ខែ ឆ្នាំ ប្តូរឈ្មោះម្ចាស់កម្មសិទ្ធិ ។

៣-កិច្ចសន្យាផ្តល់អាជ្ញាប័ណ្ណ ដែលបានដាក់ជូនមន្ត្រីកាន់កាប់បញ្ជី ដើម្បីស្នើសុំធ្វើការកត់ត្រាតាមមាត្រា៥២ នៃច្បាប់ ត្រូវភ្ជាប់មកជាមួយនូវវិញ្ញាបនបត្រថតចម្លងមួយច្បាប់ និងលិខិតប្រគល់សិទ្ធិ និងកិច្ចសន្យាផ្តល់អាជ្ញាប័ណ្ណច្បាប់ដើម ឬច្បាប់ចម្លង ដែលបញ្ជាក់ភាពត្រឹមត្រូវមួយច្បាប់ ។

## មាត្រា ២៨. – ការចាត់តាំងភ្នាក់ងារតំណាង អាសយដ្ឋានសម្រាប់ទាក់ទង

ការចាត់តាំងភ្នាក់ងារតំណាងមួយ ត្រូវធ្វើឡើងដោយមានលិខិតប្រគល់សិទ្ធិ ដែលត្រូវបញ្ជាក់ភាពស្របច្បាប់ និងចុះហត្ថលេខា ដោយអ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក ឬប្រសិនបើអ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកច្រើននាក់ ការចុះហត្ថលេខាត្រូវធ្វើឡើង ដោយអ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកទាំងនោះ ។ អាសយដ្ឋានរបស់ភ្នាក់ងារតំណាង ត្រូវបានចាត់ទុកថាជាអាសយដ្ឋានប្រើប្រាស់សម្រាប់ទាក់ទងរវាងបុគ្គលម្នាក់ ឬ ច្រើននាក់ដែលត្រូវបានចាត់តាំងជាភ្នាក់ងារតំណាង ហើយព័ត៌មានផ្សេងៗត្រូវផ្ញើតាមរយៈភ្នាក់ងារតំណាងនោះ ។

## មាត្រា ២៩. – ចំនួនថ្ងៃដែលពុំត្រូវរាប់បញ្ចូល

នៅពេលដែលថ្ងៃចុងក្រោយសម្រាប់បំពេញការងារ ឬសម្រាប់ចាត់វិធានការណាមួយ ត្រូវចំថ្ងៃឈប់សម្រាក ថ្ងៃបន្ទាប់ត្រូវបានចាត់ទុកថា ស្របច្បាប់ ចំពោះការបំពេញការងារ ឬ ចាត់វិធានការ ។

## មាត្រា ៣០. – ការស្នើសុំពិនិត្យបញ្ជីម៉ាក និងការស្នើសុំដកស្រង់ព័ត៌មានពីបញ្ជីម៉ាក

ការស្នើសុំពិគ្រោះយោបល់អំពីបញ្ជីម៉ាក ត្រូវបានអនុញ្ញាត ដោយផ្អែកតាមសំណើជាលាយលក្ខណ៍អក្សរ របស់ភាគីណាមួយដែលមានផលប្រយោជន៍ មន្ត្រីកាន់កាប់បញ្ជី ត្រូវធ្វើការថតចម្លងឯកសារក្នុងបញ្ជីម៉ាក និងឯកសារដទៃទៀត ព្រមទាំងបញ្ជាក់ភាពត្រឹមត្រូវផង ។

## មាត្រា ៣១. – ការកែតម្រូវកំហុស

ការកែតម្រូវកំហុសតាមមាត្រាទី៥៦ នៃច្បាប់ អាចធ្វើឡើងដោយមន្ត្រីកាន់កាប់បញ្ជី នៅពេលបានទទួលសំណើជាលាយលក្ខណ៍អក្សរ ហើយដែលសំណើនោះបានបំពេញតាមលក្ខខណ្ឌទាំងឡាយ ដែលមន្ត្រីកាន់កាប់បញ្ជីយល់ថា សមស្រប ឬ ធ្វើឡើងតាមគំនិតផ្តួចផ្តើមផ្ទាល់របស់មន្ត្រីកាន់កាប់បញ្ជី ។ រាល់ការកែតម្រូវ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ទៅបុគ្គលទាំងអស់ដែលមានការពាក់ព័ន្ធ ហើយត្រូវបោះពុម្ពផ្សាយជាសាធារណៈ ដោយមន្ត្រីកាន់កាប់បញ្ជី បើយល់ឃើញថា ជាការចាំបាច់ ។

## មាត្រា ៣២. – សវនាការ

